# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៦ លេខ ៦ ខែ មិថុនា

ព. ស. ២៥០៦ គ. ស. ១៩៦៤

- ភ្នំពេញ -

# សេចក្ដីបួងសួង

សូមព្រះតេជៈដ៏គល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ សម្ដេចព្រះឧបយុវរាជព្រះនរោត្តមសីហនុ ព្រះប្រមុខរដ្ឋកម្ពុជា ក្រោមលម្អងធូលីព្រះបាទ

សូមទ្រង់ជ្រាប ។

ក្នុងឱកាសដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាប្រទេសបារាំង ដើម្បីព្យាបាលព្រះរោគដែលយាយីព្រះសុខភាពព្រះអង្គនោះ ទូលព្រះបង្គំទាំងឡាយ ក្រុមពុទ្ធសាសនបណ្ឌិត្យ ដោយនៅឆ្ងាយ មិនអាចគាល់បំរើផ្ទាល់បាន សូមសំបូងសម្រួងពីចម្ងាយ ដល់គុណព្រះរតនត្រ័យ ប្រកបដោយមហិទ្ធិពលក្រៃលែង និងតែសក្ដិសិទ្ធិក្នុងលោកដែលជាសម្មាទិដ្ឋិ មានទេពារក្សាព្រះមហាស្វេតច្ឆត្រជាដើម សូមជួយថែរក្សានិងការពារព្រះអង្គសម្ដេចជាទីស្នេហាស្មើជីវិតនិងសត្រូវគ្រប់យ៉ាង ព្រមទាំងសូមជួយញ៉ាំងព្រះរោគឲ្យវិនាសខ្ចាតខ្ចាយពីព្រះកាយព្រះអង្គ ក្នុងរយៈពេលដ៏ខ្លី សូមព្រះសុខភាពដ៏លើសលប់ត្រឡប់កើតមានយ៉ាងឆាប់ ចំពោះព្រះអង្គដើម្បីទ្រង់សប្បាយរីករាយ ក្នុងព្រះជីវភាពជាព្រះបរមសុខតរៀងទៅ.

សូមព្រះទស្សនកិច្ចនៃព្រះអង្គ នៅបរទេសនេះ ជួបប្រទះតែនឹងជោគជ័យដូចព្រះរាជបំណង ហើយសូមព្រះអង្គទ្រង់ព្រះនិវត្តមកមាតុប្រទេសវិញ ដោយព្រះសុវត្ថិភាព ។

ពុទ្ធសាសនបណ្ឌិត្យ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ឆ.ត្រ ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


*ផ្នែកសាសនា* — ទំព័រ

- សុវុប្បត្តិមូលកថា ព្រះមហា នៅ-ផា រៀបរៀង . . . . . ៥៨៣
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ូ តែងរៀបរៀង (ត) . . . ៦០១
- អ្នកមានគុណ តែងដោយលោក ហេង-សមអាន នៅសេនាធិការ ខេត្តកំពង់ចាម (ត) ៦០៧
- ព្រះវិធុរជាតក (ត) . . . . . . . . . . . ៦១៤

*ផ្នែកអក្សរសាស្ត្រ*

- សមត្ថភាពគឺអ្វី ព្រះមុនីកោសល ស្វ-ហាយ អធិបតីរង ក្រុមជំនុំព្រះត្រៃបិដក តែង . ៦២១
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត) . . . . ៦២៧
- រឿងអាប៊ូលហ៊ាក្សវីស៍ លោក វ៉ាយ-ល្មុត ជំណាងរាស្ត្រ ប្រែរៀបរៀង (ត) . . ៦២៩
- រឿងបងប្អូនពីរនាក់ ចែកមត៌កផ្កា លោក ផេង-ជ្រីវ និពន្ធ . . . . . . . ៦៣៥
- រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . ៦៤៣
- ព្រះរាជនិពន្ធ រាមកេរ្តិ៍ ស្រាវជ្រាវ ដោយលោក ឌ-គាម (ត) . . . . ៦៥១
- សេចក្ដីយុត្តិធម៌នឹងប្រាក់ លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង . . . . . ៦៦៧
- ទំនៀមទម្លាប់ខ្មែរៈ ប្រកាសប្រឡងទំនៀមទម្លាប់ខ្មែរ . . . . . . ៦៧៣

*ផ្នែកកំណត់ទីនប្រវត្តិការណ៍*

- ព្រះពិធីថ្វាយគ្រឿងឥស្សរិយភណ្ឌ ចំពោះសម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គ រៀបរៀងដោយ ឌឹក-គាម . . . . . . . (នៅមានត) ៦៨១
- សុត្តវកថា នៃព្រះឃោសធម្ម កៅ-សឹម ចៅអធិការវត្តលង្កា . . . ៦៨៧
- រឿងតាំងចៅអធិការ និងគ្រូសូត្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ (ត) . . ៦៩១



ឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០:០០

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក ឲ្យធ្វើល្អទៅ
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.៣.

## សុខុប្បត្តិមូលកថា

ព្រះមហា ឌៅ-ជា គង់វត្តឧណ្ណាលោម តែងរៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះភគវន្តមុនី សម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ នឹងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ។

អំពីបទនមស្ការនេះ នឹងសូមអត្ថាធិប្បាយនូវដើមកំណើត នៃសេចក្ដីសុខ តាមពុទ្ធភាសិត ដូចតទៅនេះ ៖

សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។

ប្រែថា: ការឧប្បត្តិឡើងឬកិរិយាត្រាស់ដឹងឡើង នៃព្រះពុទ្ធទាំងឡាយ ក្នុងលោក ជាហេតុនាំមកនូវសេចក្ដីសុខ ។

កិរិយាសំដែងនូវព្រះសទ្ធម្ម នៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំឲ្យកើតសេចក្ដីសុខ ។

ការប្រមូលផ្តុំគ្នាជាពួកជាក្រុម (ពួកដៃគ្នា រួបរួមគ្នា ស្រុះស្រួលគ្នា) ជាហេតុនាំឲ្យកើតសេចក្ដីសុខ ។

ក្នុងផ្ទៃនៃពុទ្ធភាសិតនេះ ចែកចេញជា ៤ ឃ្លា ក្នុងឃ្លានីមួយ ៗ សុទ្ធតែបញ្ជាក់អំពីហេតុដែលនាំឲ្យកើតសេចក្ដីសុខទាំងអស់ ។

ជាដំបូង សូមលើកយកឃ្លាទី ១ មកសំដែង ដូចតទៅ៖ ទី ១ សុខោ ពុទ្ធានមុប្បាទោ ការដែលបានត្រាស់(១)ដឹងឡើងនៃព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ជាហេតុនាំឲ្យកើតសេចក្ដីសុខ ជាច្រើនប្រការ ដល់សព្វសត្វក្នុងត្រៃភព ។

អធិប្បាយថា : ក្នុងកាលណាមួយ ៗ ដែលមានព្រះសម្ពុទ្ធបានត្រាស់ដឹងឡើង ក្នុងកាលនោះ សត្វមានសេចក្ដីចំរើនឥតគណនា តែងបានជួបប្រទះប្រយោជន៍និងសេចក្ដីសុខយ៉ាងក្រៃលែង ព្រោះព្រះអង្គបានឧប្បត្តិឡើង ទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរឲ្យស្ងើច ជាទីបូជារបស់ជនជាមនុស្ស បរិបូណ៌ដោយវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានព្រះទ័យពេញប្រៀបដោយសេចក្ដីករុណា ទៅរកសត្វទូទៅឥតរើសមុខ ព្រះជិនមារទ្រង់បានជួបប្រទះសេចក្ដីក្សេមក្សាន្ត ដ៏ខ្ពង់ខ្ពស់ផុត ក្នុងចំណោមមនុស្សដោយគោត្រត្រកូល រាជសម្បត្តិជាដើម ក៏ព្រោះកម្រៃសេចក្ដីល្អ (បុណ្យ) ដែលទ្រង់បានកសាងសន្សំជាលំដាប់ជាតិ ៗ មកដោយពិត ។

---

១) ត្រង់នេះបើថា " ការកើតឡើង ,, មានន័យទូលាយជាង ។

មហាការុណិកោ ណាថោ ព្រះលោកនាថប្រកបដោយមហាករុណាគុណ ពោះបីព្រះអង្គបានប្រកបដោយសេចក្តីសុខស្រួលយ៉ាងណាក៏ដោយ ទ្រង់ក៏មិនទម្រន់ឲ្យលង់ជក់ជាប់ព្រះទ័យ ឲ្យទាល់តែលង់គំនិតដល់ភ្លេចសេចក្តីសុខទុក្ខរបស់សត្វដែលលិចលង់ ក្នុងលោកសន្និវាសនេះទេ ព្រះអង្គមិនព្រមសោយសុខថ្កុំថ្កើង ដែលបានតាំងនៅស៊ប់ក្នុងកណ្តាលព្រះហស្តនៃព្រះអង្គតែមួយព្រះអង្គឯងប៉ុណ្ណោះទេ ទ្រង់ស៊ូលះបង់ប្រយោជន៍ទាំងនោះមិននឹកនា ចំប្រឹងបំពេញព្យាយាមទាល់តែសម្រេចប្រាជ្ញាសម្ពោធិញាណលើរតនបល្ល័ង្ក ព្រះអង្គបាននាទីជាសត្ថានាយក ដឹកនាំស្រោចស្រង់សត្វទាំងឡាយទូទៅក្នុងត្រៃភព ឲ្យរួចផុតអំពីសេចក្តីទុក្ខលំបាកកើតចាស់ឈឺស្លាប់ ។

បន្ទាប់មក ព្រះសម្មាសម្ពុទ្ធ ស្តេចយាងប្រកាសសាសនា ប្រទានឱវាទ ប្រៀនប្រដៅណែនាំពួកសត្វ មានមនុស្សនឹងទេវតាជាដើម ចំប្រឹងព្យាយាមសំដែងធម៌ពិតពន្យល់ប្រាប់បាប-បុណ្យ គុណ ទោស ល្អអាក្រក់ ខុសត្រូវ ឲ្យសត្វយល់ឃើញពិត ៗ ឥតរួញរានឹងសេចក្តីនឿយព្រួយព្រះកាយពល ក្នុងការប្រកាសប្រាប់ប្រយោជន៍ដល់សត្វទាំងនោះឡើយ ។ ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច ៥ គ្រប់គ្រាន់ សមសក្តិជាសត្ថានាយក អ្នកដឹកនាំស្រោចស្រង់ ជាពំនឹងនៃសត្វក្នុងត្រៃភពមែន ទាំងមានឥរិយាបថស្រគត់ស្រគំសមរម្យ មានព្រះអធ្យាស្រ័យទន់ភ្លន់ស្លោះស្មើស្លូតត្រង់ទៅ

រកពួកសត្វទៅកន្លៃត្រកត គួរគាប់ចិត្តលម្មឲ្យមនុស្សទេវតា ទីនសត្វគ្រប់វណ្ណៈ មានសេចក្តីសង្ឃឹមយ៉ាងកក់ក្តៅ ចូលទៅជ្រកកោនក្រោមពោធិសម្ភារ បានសន្តិសុខតាមប្រាថ្នា ព្រះអង្គមានពំនឹងឲ្យសត្វលោកយកគំរូតាម ដោយសេចក្តីពេញចិត្តមិនបាច់បង្ខំ ព្រះពុទ្ធគុណដែលសំដែងមកខាងលើនេះ បើពោលបំព្រួញឲ្យខ្លីងាយចំណាំមកទៀតថា: ព្រះសម្មាសម្ពុទ្ធ មានព្រះទ័យស្អាត មិនប្រឡាក់ដោយបាប-អំពើអាក្រក់ណាមួយហៅថា «វិសុទ្ធិគុណ» ១ ទ្រង់បំពេញប្រយោជន៍ដល់សត្វលោកតាមផ្លូវគតិលោក គតិធម៌ស្មើៗគ្នា តាមសមគួរដល់និស្ស័យនៃសត្វ មិនគិតប្រយោជន៍ផ្ទាល់ព្រះអង្គហៅថា «ករុណាគុណ» ១ ទ្រង់មានឧបាយដ៏ប្រពៃក្នុងការទូន្មានសត្វ ធ្វើសេចក្តីដែលជ្រៅឲ្យរាក់ តាចកំបាំងឲ្យងាយយល់ ងាយគិតជាដើមហៅថា «បញ្ញាគុណ» ១

ម្យ៉ាងទៀត ការកើតឡើងឬការបានត្រាស់ដឹងឡើងក្នុងលោក នៃព្រះពុទ្ធទាំងឡាយ ជាការកម្រក្រៃក្រៃថែមទៀតផង ១ ព្រោះថាព្រះពុទ្ធមួយអង្គ ១ មុននឹងបានក្លាយទៅជាព្រះពុទ្ធនោះ តែងមានការកសាងសន្សំបន្ទំបារមី អស់កប្បសុទ្ធតែអសង្ខេយ្យ និងកម្រៃកប់សែនកប្ប ទើបបានសម្រេច ១ ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់មានព្រះពុទ្ធតម្រាស់ជាមួយស្តេចនាគកជមួយឈ្មោះ ឯរកបត្ត ទុកក្នុងធម្មបទខុទ្ទកនិកាយឧទ្ធមភាគ ក្នុងពុទ្ធវគ្គ ត្រង់ទំព័រ ១៩១ ថា ម្នាលមហាកជ សត្វលោកមិនងាយ

បានកើតមកជាមនុស្សទេ កើតមកជាមនុស្សហើយ មិនងាយបានស្តាប់ព្រះសទ្ធម្ម នឹងមិនងាយបានជួបប្រទះនូវការកើតឡើង នៃព្រះពុទ្ធទាំងឡាយទេ ព្រោះថា ហេតុទាំងនេះ ជាហេតុដែលគេបានជួបប្រទះដោយកម្រក្រៃក្រពេកណាស់ រួចហើយព្រះអង្គទ្រង់សំដែងធម៌ទេសនា ជាបទព្រះគាថាតទៅទៀតថា :

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។

ប្រែថា : ការកើតមក ជាមនុស្ស ជាការក្រ ការចិញ្ចឹមជីវិតរបស់សត្វទាំងឡាយ ជាការលំបាក ការស្តាប់នូវធម៌ ជាកិច្ចដ៏កម្រ ការបានត្រាស់ដឹងឡើងនៃព្រះពុទ្ធទាំងឡាយ គឺជាការកម្រ ។

អធិប្បាយថា : សត្វទាំងឡាយកម្រនឹងបានកើតមកជាមនុស្សណាស់ លុះបានកើតមកជាមនុស្សហើយ លំបាកនឹងចិញ្ចឹមជីវិត លំបាកនឹងរស់នៅឲ្យបានស្រួល លំបាកនឹងរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីដោះស្រាយបញ្ហាជីវិត ឲ្យបានជួបប្រទះសុភមង្គល នឹងសេចក្តីចំរើនៗ មិនតែប៉ុណ្ណោះ បានរស់គួរសមល្មមហើយ មិនងាយនឹងបានស្តាប់នូវពាក្យប្រៀនប្រដៅណាមួយ ដែលប្រកបដោយហេតុផលត្រឹមត្រូវល្អ ពោលគឺព្រះសទ្ធម្មជាធម៌ពិត ព្រោះកម្រនឹងមានបុគ្គលដទៃឯណាមួយក្រៅពីព្រះពុទ្ធ អាចនឹងសំដែងឬឈ្វេងយល់ត្រាស់ដឹងពិតប្រាកដបាន ។ ព្រះសទ្ធម្ម

នេះ ជាធម៌ពិតមួយ ប្រសូតចេញពីព្រះឱស្ឋរបស់ព្រះពុទ្ធ ។ ដោយសារតែព្រះសទ្ធម្មជាធម៌ពិត ជាធម៌ដែលគេមិនងាយនឹងបានស្តាប់ ព្រមទាំងជាធម៌ដែលប្រសូតចេញពីព្រះពុទ្ធផងនោះ ដូច្នេះបានជាព្រះពុទ្ធទាំងឡាយកម្រនឹងបានត្រាស់ដឹងឡើងក្នុងលោកដែរ ។ ព្រោះហេតុនោះ បើព្រះពុទ្ធត្រាស់ដឹងឡើងក្នុងលោកហើយ សត្វលោកឈ្មោះថាបាននាចកាតសម្បើម ។

ហេតុដូចសំដែងមកខាងលើនេះ ទើបប្រាកដថាព្រះពុទ្ធគ្រប់អង្គបានត្រាស់ដឹងឡើងក្នុងលោក ជាហេតុនាំឲ្យបានសេចក្តីសុខដល់ពពួកសត្វ។

ទី ២ សុខា សទ្ធម្មទេសនា កិរិយាសំដែងនូវព្រះសទ្ធម្ម នៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំឲ្យកើតសេចក្តីសុខ ។

អធិប្បាយថា : កាលណាព្រះពុទ្ធទ្រង់បានត្រាស់ដឹងឡើងក្នុងលោកហើយ ព្រះអង្គទ្រង់សំដែងធម៌ទេសនាប្រៀនប្រដៅពពួកសត្វឲ្យបេះដឹងយល់យ៉ាងច្បាស់លាស់ថា ធម៌នេះពិត ធម៌នេះមិនពិត ធម៌នេះមានហេតុផល ធម៌នេះប្រាសចាកហេតុផល ។

ស្វាក្ខាតោ ភគវតា ធម្មោ ធម៌ដែលព្រះមានព្រះភាគ សំដែងហើយដោយប្រពៃ ជាធម៌ពិត ជាសច្ចធម៌ ព្រមទាំងមានគុណានុភាពអាចយកតយោងស្រោចស្រង់សត្វដែលកាន់តាម ប្រតិបត្តិតាម ធ្វើតាមឲ្យផុតចាកទុក្ខទោស ហើយផ្តល់ឲ្យយ៉ាងជាក់ច្បាស់នូវសេចក្តីសុខ តាម

នាទីថ្នាក់នៃសេចក្ដីប្រតិបត្តិរបស់ខ្លួន សមដូចពាក្យភាសិតថា ធម្មោ សុចិណ្ណោ សុខមាវហាតិ ធម៌ដែលសត្វបានរក្សាត្រឹមត្រូវហើយ រមែងផ្ដល់សេចក្ដីសុខមកវិញពុំខាន ។ ធម៌ក្នុងទីនេះ ប្រែថា អំពើល្អ ពោលគឺបុណ្យ អ្នកដែលប្រព្រឹត្តតាមធម៌ ឈ្មោះថាបានរក្សាធម៌ទុកដោយប្រពៃ ទើបត្រូវបានផលមកជាសេចក្ដីសុខ ។ អំពើអាក្រក់ហៅថាអធម៌ គឺមិនមែនធម៌ អ្នកដែលប្រព្រឹត្តតាមអធម៌នោះ ឈ្មោះថាបានប្រមូលមកនូវអកុសលកម្មទើបត្រូវបានផលមកជាសេចក្ដីទុក្ខ ។ ពុទ្ធបរិស័ទទាំងឡាយ ដែលគាប់អធ្យាស្រ័យចង់បានប្រយោជន៍សេចក្ដីសុខ-ចំរើន ក្នុងលោកនេះក្ដី ក្នុងបរលោកក្ដី គួរចំរក្សាទុកនូវធម៌នេះឲ្យម៉ត់ចត់ ព្រោះវិបាករបស់ការរក្សាធម៌នេះ គឺសេចក្ដីសុខចំរើន ពិតប្រាកដ ។ សេចក្ដីដែលបានពណ៌នាមកប៉ុណ្ណេះ ត្រឹមត្រង់តាមដើមនៃពុទ្ធបំណងពិត ៗ ព្រះអង្គដែលខំព្យាយាមសំដែងច្បាប់ប្រាប់ពន្យល់យ៉ាងនេះ ដោយមានព្រះទ័យករុណាចង់ដោះសត្វដែលជាប់ចំណង សេចក្ដីទុក្ខ មានជាតិ ជរា ព្យាធិ មរណៈ ជាដើម ឲ្យរួចចាកទុក្ខបាន ។

សូមពុទ្ធបរិស័ទអ្នកអាន ! អានហើយកំណត់ទុកក្នុងចិត្តចុះ ! ថា ព្រះពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្ស សត្វ កើតមកក្នុងលោក សុទ្ធសឹងប្រាថ្នាសេចក្ដីសុខ-ចំរើន-ខ្ពង់ខ្ពស់-ថ្លៃថ្នូរគ្រប់រូប ដែលថាទៅជាគាប់ទុន មិនដូចបំណងទៅវិញនោះ បណ្ដាលមកពីហេតុច្រើនយ៉ាងណាស់ ខ្លះ

កើតមកដោយសេចក្តីក្រីក្រទន់ទាបល្ងង់ខ្លៅស្រាប់ មកអំពីកំណើត ក៏មានព្រោះផលនៃអំពើល្អ មានតិចពីបុព្វជាតិ ខ្លះកើតមកបានជួបប្រទះនឹងសេចក្តីសុខ-ចំរើន ថ្កុំថ្កើងសម្បូណ៌ដោយសម្បត្តិគ្រប់គ្រាន់ស្រាប់ អំពីកំណើត តែធ្វេសប្រហែសភ្លេចគិតខ្លួន បណ្តោយចិត្តឲ្យទៅប្រព្រឹត្តតាសវែង ពានទៅលើអំពើមិនមែនជាធម៌ មានការប្តោះប្តាយធ្លាក់ខ្លួនជាអ្នកទន់ទាបអាប់ឱនខ្លួនទៅវិញក៏មាន ខ្លះខប់ខ្លួនឲ្យនៅត្រឹមតែស្មើ ៗ មិនទាបមិនខ្ពស់ក៏មាន តាមសមគួរដល់អំពើដែលសត្វធ្វើរៀង ៗ ខ្លួន ដូចពុទ្ធភាសិតថា កម្មំ សត្តេ វិភជតិ អំពើដែលសត្វធ្វើទុកមក ជាមេចំណែកចែកឲ្យបានសុខ ឬបានទុក្ខផ្សេង ៗ គ្នា មិនមានអ្វីផ្សេងពីកម្ម ឬការងាររបស់ខ្លួននោះចែកឲ្យឡើយ ។ ឯអំពើលាមកអាក្រក់ មិនត្រូវតាមធម៌ នាំឲ្យមនុស្សវិនាស បានសេចក្តីទុក្ខលំបាក ។ ដូច្នេះ សេចក្តីវិនាស លាញអន្តរាយ គឺជាសេចក្តីទុក្ខ សេចក្តីទុក្ខ គឺមិនមែនជាការស្រួល ការសប្បាយរីករាយទេ ។ ព្រោះហេតុនោះ ដើម្បីនឹងរក្សាទុកនូវសេចក្តីសុខនេះ ឲ្យបានមាំមួន តោងតែព្យាយាមលះនូវអបាយមុខធម៌ ដែលជាដើមធម៌ នៃសេចក្តីវិនាសដ៏ធំបំផុត ដូចមានសំដែងទុកក្នុងបរាភវសូត្រថា :

ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ

ប្រែថា: អ្នកចូលចិត្តនឹងមាតុគ្រាម មិនមានចិត្តសន្តោសត្រឹមតែ

កិរិយារបស់ខ្លួន អ្នកសេពគ្រឿងស្រវឹង អ្នកលេងល្បែងភ្នាល់ រមែងញុំាងវត្ថុដែលខ្លួនបានហើយ ៗ ឲ្យវិនាស អបាយមុខប្រភេទនេះ ជាប្រធាននៃសេចក្តីវិនាស ហើយជាពិសេស គឺកុំគប់រកមនុស្សអន្ធពាលលាមកជាមិត្រ ហេតុតាំងអម្បាលនេះ ជាដើមចមឬជាប្រធាននៃសេចក្តីវិនាស ដែលផ្ទុយអំពីសេចក្តីសុខនោះ ៗ មិនតែប៉ុណ្ណោះ ថែមតាំងញុំាងសង្គមមនុស្ស ទ្រព្យសម្បត្តិ ចំណេះវិជ្ជា នឹងវត្តចរិយា សណ្តាប់ធ្នាប់ ឲ្យស្រកស្រុតចុះថោកទាប ថ្លោះធ្លោយនាំឲ្យវិនាស ថ្លោះធ្លោយខូចបង់សេចក្តីសុខ-ចំរើន របស់មនុស្សគ្រប់សកលលោកជាក់ស្តែងភ្លាម ៗ មិនចាំបាច់ពោលថ្វីដល់ទៅលោកខាងមុខឡើយ ៗ អំពើនេះ បើសត្វខំប្រឹងប្រព្រឹត្តធ្វើមិនលែង លោកពោលថា ទុកដូចជាយកគប់ភ្លើងយ៉ាងធំ មកដុតកេលកម្ទេចបំផ្លិចបំផ្លាញ បង្ហិនបង្ហោច ឲ្យទ្រព្យសម្បត្តិ ចំណេះវិជ្ជា វត្តចរិយា សណ្តាប់ធ្នាប់ ឬមារយាទជាតិត្រកូល នឹងសេចក្តីសុខដ៏ចំរើនរុងរឿង ឧដុង្គឧត្តម ថ្លៃថ្លា វិសេសវិសាលឲ្យខ្ទោចបង្ក្រាសក្រិនគួច លែងលូតលាស់ទៅទៀតបាន ៗ

ពុទ្ធបរិស័ទទាំងឡាយ! កាលបើសាធុជនណា បានវៀរចាកអំពើដូចបានសំដែងមកខាងលើនេះហើយ សាធុជននោះ ឈ្មោះថាបានរក្សាធម៌ទុកដោយប្រពៃ ហើយត្រូវបានកម្រៃផលជាសុខ ៗ

បើពោលខ្លី ៗ សង្ខេបវិញគឺ ១- បានសុខព្រោះមានចិត្តស្រុះស្រួល

ស្មោះស្មើទៅរកភរិយាស្វាមី ដោយមិនជាប់ចិត្តទៅលើស្ត្រី ឬបុរសឯទៀត ។ ២- បានសុខ ព្រោះមានសំដីសុភាពរាបសារ មិននិយាយឡេះឡោះប៉ៅឡែកកែកកកោក រករឿងឈ្លោះ មិនបង់ប្រាក់បង់កាស ព្រោះតែខ្ទុនផឹកអាការសាហាវគឺស្រា បើតាមវិទ្យាសាស្ត្រ គេថាមិនខូចសរសៃប្រព័ន្ធប្រសាទ មិនខូចខួរក្បាល មិនខូចស្មារតី ឬសម្បជញ្ញៈ អភិរក្ស មានោគតិ ការនឹកឃើញឡើងវិញ ការដំទាញ ទីងមជ្ឈដ្ឋានតាំងឡាយនៃមេគំនិតបញ្ញាសំខាន់ ៗ ដោយហេតុតែមិនសេពសុរា ។ ៣- បានសុខ ព្រោះគ្មានភ័យនឹងគេចាប់ឃុំឃាំងលក់ពិន័យ ដាក់គុកប្រវាក់អន្ទាក់ណែងណង ខ្នោះឃ្នាង ដោយហេតុតែមិនលេងល្បែងភ្នាល់ ។ ៤- បានសុខ ព្រោះមានចិត្តស្លូតត្រង់ មិនចេះធ្វើអំពើអាក្រក់ ដោយហេតុតែមិនសេពគប់នូវជនពាល ។ រីឯការគប់រកជនពាលអាក្រក់ នាំឲ្យចេះចំណេះអាក្រក់ ព្រោះមនុស្សពាល មិនដែលដឹកនាំឲ្យប្រព្រឹត្តល្អទេ មិនស្គាល់ហេតុនាំឲ្យបានសេចក្ដីសុខទេ ស្ដាប់ពាក្យសំដីដែលត្រូវ ៗ មិនសូវបានឮទេ បើអ្នកដែលសេពគប់ផងនោះ មិនចេះលេងស្រី នាំឲ្យចេះលេង មិនចេះផឹកស្រា នាំឲ្យចេះផឹក មិនចេះលេងល្បែង នាំឲ្យចេះលេង រហូតដល់ចេះដើរលេងយប់ បោកប្រាស់ប្រវញ្ចគេ ធ្លាក់ដល់ចេះលួចប្លន់ចាក់កាប់សម្លាប់គេក៏សឹងមាន គឺបង្រៀនឲ្យចេះប្រព្រឹត្តអំពើអាក្រក់ទាំងអស់ ៗ ត្រូវដូចពុទ្ធភាសិតក្នុងមង្គលសូត្រថា : អសេវនា ច ពាលានំ ...

ឯតម្មង្គលមុត្តមំ ។

ការមិនគប់រកពួកជនពាល ចាត់ជាមង្គលដ៏ប្រសើរ អ្នកដែលវៀរចាក អំពើទុច្ចរិតដូចពោលមកនេះ ទុកដូចបណ្តុះប្រយោជន៍ធំទូលាយទុកសំរាប់ ខ្លួនឯងនិងទីសម្រាប់សង្គមមនុស្សជាតិ ឲ្យបានចម្រើនទៅអនាគតផង ។ សេចក្តីពណ៌នាអំពីការលះបង់អបាយមុខ ដែលជាព្រះធម្មទេសនាពិត ១ ផ្តល់ឲ្យនូវសេចក្តីសុខ-ចំរើនដល់សត្វលោកនេះ ជាសេចក្តីសង្ខេប អ្នកប្រាជ្ញជាន់ខ្ពស់ដែលមានឈ្មោះចុះជាប់គ្នានិងចំពាក់ប្រវត្តិសាស្ត្រ រៀងមកដរាប ដល់សព្វថ្ងៃនេះក្តី ដែលកំពុងមាននៅសព្វថ្ងៃនេះក្តី កាលបើលោកផុត ប្រកបកិច្ចការណាមួយ ដែលជាប្រយោជន៍ផ្ទាល់ខ្លួនក្តី សុទ្ធតែលោកលះ បង់ស្រឡះនូវអបាយមុខទាំងនេះចោលចេញ ទើបការនោះ ១ បាន សម្រេចដូចបំណង ។ ព្រះសទ្ធម្មទេសនារបស់ព្រះសម្ពុទ្ធជាម្ចាស់ទាំង អស់ ពោលគឺព្រះធម៌ ៨៤០០០ ធម្មក្ខន្ធហ្នឹងឯង ដែលជាព្រះសទ្ធម្មដ៏បរិ- សុទ្ធ ដែលជាព្រះសទ្ធម្មពិតប្រាកដ ជាសច្ចធម៌ គាបជ្រោងសត្វដែល កាន់តាម ជឿតាម ប្រព្រឹត្តតាមនិងប្រតិបត្តិតាមឲ្យលឿន ទៅរកសេចក្តី សុខ-ចំរើន ទប់សត្វដែលប្រតិបត្តិតាម មិនឲ្យធ្លាក់ទៅកាន់ទីថោកទាបមាន នរកជាដើម ទាំងធ្វើឲ្យអ្នកជឿស្តាប់ ជួបប្រទះប្រយោជន៍សេចក្តីចំរើន ដោយភោគសម្បត្តិ ជាព្រះសទ្ធម្មប្រៀនប្រដៅមនុស្សមិនឲ្យខ្ជិលច្រអូស ដេកចម្រទតាព្រេងសំណាងតែម្យ៉ាងទេ ព្រោះព្រេងសំណាង បើប្រាស

ចាកការកេសាង ការង៉ារ រៀនសូត្រ ស្រាក់ស្រាទេញ ព្រេងសំណាងមិន

ដូចទេ គឺកុំដេកចាំព្រេងសំណាងពេក ស៊ីដេក ៗ ហើយត្អូញថាក្រ ៗ សម

ដូចពុទ្ធភាសិតមានដើមថា សុសុ្ស្រុំ លភតេ បញ្ញំ អ្នកប្រាជ្ញ

រេះដឹងចំណេះវិជ្ជាគ្រប់បែប បានមកអំពីការប្រឹងស្តាប់ប្រឹងទន្ទេញ ៗ

ឧបដ្ឋាតា វិន្ទតេធនំ អ្នកមានធនធាន មកពីរវៀសរវៃប្រឹងរកប្រឹងធ្វើ

ដូចបុរាណភាសិតពោលថា «កើតមកជាមនុស្សត្រូវតែប្រឹង ព្យាយាម

ឲ្យតឹងកុំបន្ធូរ ប្រាសខ្លួនដេកទៅកុំដេកយូរ ក្រោកឡើងគិតគូររកធ្វើការ» ៗ

សេចក្តីដែលសំដែងមកទាំងប៉ុន្មាននេះ ត្រូវតាមលំអាន នៃព្រះធម្មទេសនា

របស់ព្រះពុទ្ធ ដែលជាព្រះសទ្ធម្មប្រាប់ផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនឲ្យ

សត្វអ្នកកាន់ ធ្លាក់ទៅលើផ្លូវប្រតិបត្តិដែលហៅថា អត្តាបដិបទា

សេចក្តីប្រតិបត្តិលាមក ឬសេចក្តីប្រតិបត្តិតាមធម៌អមខាង មិនមែនជា

មជ្ឈិមាបដិបទានោះ ៗ

ព្រោះហេតុនោះ កិរិយាសំដែងនូវព្រះសទ្ធម្មទេសនា នៃព្រះពុទ្ធ

ទាំងឡាយ ឬការប្រាប់នូវធម៌ពិត ជាធម៌ស្អិតស្អាងសត្វលោកឲ្យរុងរឿង

ទប់សត្វមិនឲ្យទៅកាន់ទីទុក្ខលំបាក ជាហេតុនាំឲ្យកើតសេចក្តីសុខដល់

សត្វលោក ៗ

ទី ៣- សុខា សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងគ្នា

រួបរួមគ្នា ស្រុះស្រួលគ្នា ប្រមូលគ្នាជាបាច់ រួបរួមជាធ្លុងមួយ ជាហេតុ

នាំឲ្យបានសេចក្ដីសុខ ។

អធិប្បាយថា : ពាក្យថាសាមគ្គី ប្រែថាព្រមព្រៀងគ្នា ដំណើរមិនប្រឆាំងគ្នា ដំណើរមិនបែកកន្ទែកគ្នា សេចក្ដីពេញចិត្តស្និទ្ធនឹងគ្នា ការចូលចិត្តមូលគំនិតគ្នា ការស្រុះស្រួលគ្នា ការរួបរួមចងបាច់គ្នា បានសេចក្ដីថា ការដែលស្របគ្នា ការបណ្ដោយគ្នា ការស្មើចិត្តស្មើគំនិតនឹងស្មើអធ្យាស្រ័យគ្នា ។

សាមគ្គីនេះជា ៣ ប្រភេទគឺ :

១- កាយសាមគ្គី សេចក្ដីព្រមព្រៀងគ្នាដោយកាយ

២- វចីសាមគ្គី ការព្រមព្រៀងគ្នាដោយសំដី

៣- ចិត្តសាមគ្គី ការព្រមព្រៀងគ្នាដោយចិត្ត ។

១- កាយសាមគ្គី ព្រមព្រៀងគ្នាដោយកាយ គឺព្រមព្រៀងគ្នាធ្វើការងារ ព្រមព្រៀងគ្នារៀនសូត្រ ព្រមព្រៀងគ្នាស្ដាបនា ព្រមព្រៀងគ្នាប្រតិបត្តិ ព្រមព្រៀងគ្នាអនុវត្ត ព្រមព្រៀងគ្នាសន្សំ ព្រមព្រៀងគ្នាសំចៃ ព្រមព្រៀងគ្នារក្សា ព្រមព្រៀងគ្នាស្វែងរក នឹងព្រមព្រៀងគ្នាការពារ ។

បើផ្នែកខាងបព្វជិតវិញ គឺព្រមព្រៀងគ្នាប្រតិបត្តិតាមធម៌វិន័យ ព្រមព្រៀងគ្នាធ្វើឧបោសថកម្ម ស្រុះស្រួលគ្នាប្រជុំស្ដាប់ឱវាទ ពាក្យប្រៀនប្រដៅរបស់គ្រូអាចារ្យ រួបរួមគ្នាធ្វើកិច្ចការសង្ឃជាដើម ។

ផ្នែកខាងគ្រហស្ថ ក៏ប្រហែលគ្នាដែរ ដូចជានៅក្នុងសង្គមភូមិនីមួយៗ ដើម្បីកុំឲ្យសត្រូវពីក្រៅមើលងាយ គេតែងតែពួតដៃគ្នាការពារ រក្សាទូវ អន្តរាយឬហេតុការណ៍ណាមួយ ដែលជាឧបសគ្គដល់ដំណើរជីវិតរបស់ខ្លួន ៗ ចំពោះករណីយកិច្ចទូទៅ ក៏ជួយគ្នាទៅវិញទៅមក ធ្វើការហត្ថកម្ម ដោយយកដៃគ្នា ផ្លាស់វេនគ្នា ជួយធ្វើការងារគ្នាម្នាក់ រហូតដល់ទៅជួយធ្វើការក្នុងសង្គមជាតិផង ៗ ដោយសារការផ្ដុំកម្លាំងគ្នា រួបរួមគ្នា ធ្វើឲ្យជាកម្លាំងរួម ហើយអនុវត្តឡើង ការងារទាំងឡាយដែលលំបាក ៗ នោះ រមែងដើរទៅដល់ទីដៅពោលគឺសេចក្ដីសំរេចបានយ៉ាងពិតប្រាកដ ៗ ការព្រមព្រៀងគ្នាធ្វើដោយកាយដូច្នេះ ឈ្មោះថាកាយសាមគ្គី ៗ

២– វចីសាមគ្គី ព្រមព្រៀងគ្នាដោយវាចា: សំដីដែលស្របគ្នា សំដីដែលចុះសម្រុងគ្នា សំដីដែលបណ្ដោយគ្នា មិនខ្វែងគ្នា មិនប្រឆាំងគ្នា និយាយទៅហើយប្រកបដោយហេតុផល គួរយកជាការបាន គួរយកទៅប្រតិបត្តិបាន ហើយស្រុះស្រួលអនុវត្តតាមសំដីនោះទៅ ៖

ផ្នែកខាងព្រះសង្ឃពុទ្ធសាសនិក បានដល់ការសិក្សាស្វាធ្យាយធម្មវិន័យត្រូវបែបបទគ្នា មានវាទៈប្រកបដោយធម៌ និងប្រកបដោយហេតុផលដូចគ្នា ៗ

ចំណែកខាងគ្រហស្ថ បានដល់សំដីដែលគេពោលអំពីប្រយោជន៍អ្វីមួយ ដែលអាចប្រើប្រាស់បានទាំងអស់គ្នា ជាសំដីដែលមានមតិភាគ

ច្រើនយល់ព្រមជាមួយផង ជាសំដីដែលប្រកបដោយហេតុ-ផលស្តាប់គ្នាបាន ពោលគឺសំដីដែលប្រកបដោយឧត្តមគតិពិតប្រាកដផង ឧទាហរណ៍ក្នុងសមាជជាតិ ឬប្រជុំសន្និសីទអ្វីមួយ បើសំដីរបស់សមាជិក ឬសមាជិកាណាមួយនៃអង្គប្រជុំសមស្របគួរយកជាការបាន ក៏ព្រមជឿស្តាប់តាំងអស់គ្នាទៅ ។ ការព្រមព្រៀងគ្នាដោយវាចាយ៉ាងនេះ ហៅថាវចីសាមគ្គី ។

៣- ចិត្តសាមគ្គី សេចក្តីព្រមព្រៀងគ្នាដោយចិត្ត បានសេចក្តីថា មានចិត្តស្រុះស្រួលគ្នា មានចិត្តស្មើគ្នា មានគំនិតស្មើគ្នា និងមានអធ្យាស្រ័យស្មើៗគ្នា ។

ក្នុងផែកពុទ្ធសាសនា ដូចជាភិក្ខុសង្ឃមានចិត្តចុះសម្រុងគ្នា ក្នុងការធ្វើឧបោសថកម្ម មានអធ្យាស្រ័យទន់ភ្លន់ ចេះគោរពកប់គេគ្នាទៅវិញទៅមកដោយចិត្តស្មោះស្មើ ចេះជួយធុរៈគ្នាក្នុងពេលមានជម្ងឺដម្កាត់ ដោយចិត្តស្មោះស្មើ ចេះព្រមព្រៀងគ្នាក្នុងកិច្ចប្រតិបត្តិតាមធម៌វិន័យឲ្យត្រឹមត្រូវបរោយាថល់គ្នា ក្នុងពេលមានប្រជុំអ្វីមួយ ដែលជាប្រយោជន៍ដល់ពុទ្ធសាសនាដោយចិត្តស្មោះត្រង់ពិតៗ ។

ចំណែកខាងគ្រហស្ថក៏ស្រដៀងគ្នាដែរ គឺចេះរាប់អានគ្នាដោយចិត្តដ៏ស្មោះស្មើរពងពីភូមិមួយទៅភូមិមួយ ពីគ្រួសារមួយទៅគ្រួសារមួយ ពីវណ្ណៈមួយទៅវណ្ណៈមួយ ពីសង្គមមួយទៅសង្គមមួយទៀត រហូតដល់សង្គមជាតិតាំងមូល ។ ពោលគឺចេះគោរពគ្នា ចេះទ្រាំចិត្ត ចេះរាប់អានគ្នា

បេះស្រឡាញ់ចិត្តថ្លើមគ្នាទុកដូចជាបងប្អូនបង្កើត មិនប្រទូស្តគ្នា មិនក្បត់ចិត្តគ្នា មិនប្រើអំណាចឃោរឃៅទៅលើសេរីភាពគ្នានឹងគ្នា មិនលួចប្លន់កាប់សម្លាប់គ្នា មិនឈ្លានិសប៉ះតន់គ្នាទៅវិញទៅមក ហើយមូលមតិគ្នាជាធ្លុងមួយ ប្រតិបត្តិតាមច្បាប់ធម៌វិន័យរបស់ព្រះពុទ្ធសាសនា ឬប្រតិបត្តិតាមច្បាប់សំរាប់រដ្ឋ ដោយសភាពរួបរួមមូលត្រកូលគោករពោយជាមួយគ្នា សេចក្តីព្រមព្រៀងគ្នាដោយចិត្តយ៉ាងនេះ ហៅថាចិត្តសាមគ្គី ។

៤- សមគ្គានំ តបោ សុខោ សេចក្តីព្យាយាមរបស់អ្នកព្រមព្រៀងគ្នា ជាដើមកំណើតនៃសេចក្តីសុខ ។

សេចក្តីព្យាយាមរបស់បុគ្គលអ្នកព្រមព្រៀងនេះ ព្រះអដ្ឋកថាចារ្យលោកកែទុកនៅក្នុងធម្មបទខុទ្ទកនិកាយត្រង់ពុទ្ធវគ្គថា បានដល់ពួកភិក្ខុអ្នករួបរួមគ្នា ហើយព្យាយាមរៀននូវពុទ្ធវចនៈ ឬក៏រក្សានូវធុតង្គ ពុំនោះសោតក៏ព្យាយាមធ្វើសមណធម៌ សមាធិកម្មដ្ឋាន ដោយចិត្តស្មោះស្ម័គ្រគម្រង់ទៅរកផ្លូវមួយនឹងចិត្តគំនិតមួយ ដើម្បីឈានចាប់យកអមតដ្ឋានរៀង ៗ ខ្លួន ។ នេះគឺសេចក្តីព្យាយាមរបស់ពួកភិក្ខុ អ្នកមានសាមគ្គីដើម្បីប្រតិបត្តិយកផ្លូវទៅកាន់ទីរំលត់ទុក្ខ ។

បើអធិប្បាយឲ្យពាក់សេចក្តីរាយស្តាប់មកទៀតថា : ១- ព្យាយាមលះទោសដែលកើតឡើងនៅក្នុងពួកក្រុមដែលមានសាមគ្គី ។ ២- ព្យាយាមរាំងទោសមិនឲ្យកើតឡើងក្នុងពួកក្រុមដែលមានសាមគ្គី ។ ៣- ព្យា

យាមបង្កើតសេចក្ដីល្អឲ្យកើតមានដល់ពួកក្រុមដែលមានសាមគ្គី ៗ ៤-ព្យាយាមរក្សាសេចក្ដីល្អដែលកើតមានក្នុងពួកក្រុម ប្រកបដោយសាមគ្គីហើយមិនឲ្យបាត់បង់ទៅវិញ ៗ ភាពនៃសេចក្ដីសាមគ្គីនិងសេចក្ដីព្យាយាមរបស់អ្នកមានសាមគ្គីនេះ ជាធម៌មានគុណានុភាពណាស់ កាលបើយើងប្រតិបត្តិតាមដោយហ្មត់ចត់ ៗ សូមលើកយកជាតកមួយមកសំដែងដោយសង្ខេបជាបុគ្គលាធិដ្ឋានដូចតទៅនេះ ៖

កាលកន្លងទៅហើយ ព្រះពោធិសត្វបានយកកំណើតជាសត្វតាប ៗ សម័យថ្ងៃមួយ តាបជាបរិវារបស់ពោធិសត្វ ព្រមទាំងតាបពោធិសត្វផងនោះ បាននាំគ្នាទៅរកចំណីអាហារក្នុងស្រែមួយដែលបរិបូណ៌ដោយស្រូវ ពេលនោះ មានព្រានបក្សីម្នាក់ បានយកលប់ទៅដាក់ដើម្បីឲ្យជាប់តាប ៗ ខណៈនោះ ក្រុមតាបពោធិសត្វ ក៏បានចុះទៅស៊ីស្រូវក្នុងស្រែដែលមានលប់នោះ លុះគេស៊ីបានមួយសន្ទុះ ក៏មានគ្រោះថ្នាក់មកដល់ពួកក្រុមស្រាប់តែបានចូលទៅក្នុងលប់នោះ តាបពោធិសត្វក៏និយាយថា បើយើងប្រឹងហើរទំលាយលប់នេះម្នាក់ម្ដង ៗ លប់នេះមិនធ្លាយទេ ដូច្នេះយើងទាំងអស់គ្នាត្រូវប្រឹងចំកាងហើរព្រមគ្នាតែម្ដង ទើបលប់នេះធ្លាយបាន ៗ លុះតាបជាបរិវារស្ដាប់បានដូច្នោះហើយ ក៏ព្រមព្រៀងគ្នាហើរព្រលឡើង ៗ ដោយសារកម្លាំងរបួមគ្នាភាគច្រើនរបស់តាប លប់នោះក៏ធ្លាយទៅ ៗ ពួកតាបទាំងនោះ ក៏នាំគ្នាហើរចេញរួចពីលប់ ហើយទៅដល់ទីកន្លែងរៀងៗខ្លួន

បានគេចផុតអំពីសេចក្ដីស្លាប់គ្រប់ ៗ គ្នា ៗ នេះហើយជាអានិសង្សនៃការព្រមព្រៀងគ្នា ហើយព្យាយាមទំលុះទំលាយនូវឧបសគ្គផ្សេង ៗ ដែលកើតមានដល់ពួកក្រុមរបស់ខ្លួន ៗ ត្រង់ការរួបរួមគ្នារបស់ពួកសត្វចាបនេះ ទុកជាសាមគ្គីភាព ត្រង់ការប្រឹងប្រែងទំហើរទំលាយលប់ទាំងអស់គ្នា នៃពួកសត្វចាប ទុកជាសេចក្ដីព្យាយាមរបស់អ្នកមានសាមគ្គី ហើយផលវិបាករបស់សាមគ្គីនេះ គឺសេចក្ដីសុខហ្នឹងឯង ៗ

---

ពៀរគេគបពៀរ ពាំនៀរមិនសូន្យ
ផាបផល់កូន ដូចកង់ប្រវ៉ាក់ ៗ
ឬដូចសម្ល កំពឹសប្រទាក់
ទាញទង់ឥតអាក់ គ្មានទីអវសាន ៗ
ចូរក្មេងទាំងឡាយ កំចាយពីប្រាណ
ប្រសិនបើមាន នូវពៀរចង្រៃ ៗ
កុំនោះសោកទេ អ្នកនឹងជាប់ដៃ
កុំអាចកែខៃ ដូចក្អែកនឹងមៀម ៗ

ផេង - ជ្រឹវ

# ព្រះអភិធម្មបិដក

## ( គម្ពីរព្រះមហាបដ្ឋាន )

លោក ប៊ូ - ប៊ូ រៀបរៀង

៣៥៣

---

បុគ្គលទីងធ្វើសង្ឃទានឲ្យជាសង្ឃទានល្អបរិសុទ្ធ ចូរមើលកិរិយារបស់អ្នកប្រាជ្ញអំពីមុន ផលនៃទាននោះទើបជាផលដ៏អស្ចារ្យ ។

ចំណែកផលនៃអកុសលកម្មក៏ជាបច្ច័យ ដូចផលនៃកុសលកម្មដែរ គឺបុគ្គលធ្វើបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ ពោលមុសាវាទ បេសុញ្ញវាទ ផរុសវាទ ទីងប្រព្រឹត្តមនោទុច្ចរិតបីប្រការក្តី ទុច្ចរិតទាំងដប់ប្រការនេះ បើបុគ្គលឯណាធ្វើហើយ រមែងនាំបុគ្គលនោះឲ្យទៅកាន់អបាយភូមិ ។

បុគ្គលធ្វើបាណាតិបាត ទីងធ្លាក់ទៅក្នុងសញ្ជីវនរក អស់កាលជាយូរៗ អំពីការប្រៀបរយៈកាលវិញ ៥០ឆ្នាំក្នុងមនុស្ស បានតែថ្ងៃមួយយប់មួយក្នុងចាតុមហារាជិកា ៥០ ឆ្នាំ ក្នុងចាតុមហារាជិកា បានតែថ្ងៃមួយក្នុងសញ្ជីវនរក ។ សត្វសោយផលនៃអកុសលកម្ម ទីងកើតក្នុងកំណើតដ៏លាមក គឺទីងកើតជាប្រេតប្រាំរយជាតិ ជាត្រី ជាពស់ ជានាគ ជាប្រើសក្តាន់ ជាគោក្របីទីងសុនខ ក្នុងជាតិមួយៗ ប្រាំរយៗ ដូចគ្នា ដោយអំណាចនៃបាណាតិបាតដ៏ជាកាយទុច្ចរិត ។

យោ អទិន្នាទានោ បុគ្គលឯណាមានលោភចិត្ត ច្រើនធ្វើអទិន្នាទាន គឺលួចយករបស់ទ្រព្យដែលម្ចាស់មិនបានឲ្យ ដោយថេយ្យចេតនា បុគ្គលនោះ លុះរលត់បញ្ចក្ខន្ធហើយ ក៏ទៅកើតក្នុងកាលសូតនរក កាលផុតពីនរកហើយ មកកើតជាមនុស្ស ទឹងជាអ្នកទាល់ក្រកំព្រា ទឹងជាអ្នកមានរូបរាងកាយអាក្រក់ជាទីស្អប់ខ្ពើមនៃជនទាំងឡាយ ទឹងប្រកបទៅដោយទុក្ខភយន្តរាយជាច្រើន ទឹងចាប់នូវបដិសន្ធិក្នុងត្រកូលថោកទាប ។

បុគ្គលឯណាប្រកបដោយរាគតណ្ហា ច្រើនគប់រកនូវស្ត្រីជាភរិយារបស់អ្នកដទៃ ដោយអំណាចមេថុនធម្ម ផលនៃកម្មគឺកាមេសុមិច្ឆាចារនោះ រមែងជាបច្ច័យនាំបុគ្គលនោះឲ្យទៅកើតក្នុងសង្ឃាដនរក លុះរួចពីនិរយបាយហើយ ផលនៃកាមេសុមិច្ឆាចារ ឲ្យមកកើតជាស្ត្រីប្រាំរយជាតិ ជាខ្ទើយប្រាំរយជាតិ ជាទីស្អប់ខ្ពើមដល់មនុស្សប្រុសស្រីផងទាំងពួង ។

បុគ្គលឯណាពោលមុសាវាទគឺនិយាយមិនពិត ផលនៃមុសាវាទនោះ ជាបច្ច័យដឹកនាំបុគ្គលនោះឲ្យទៅកើតក្នុងរោរុវនរក លុះរួចពីនរកហើយ មកកើតជាមនុស្សមានក្លិនមាត់ស្អុយ បក់ផ្សាយទៅដូចជាក្លិនមូត្រ ទឹងលាមក ទឹងជាមនុស្សល្ងង់ខ្លៅឥតបញ្ញា មិនបានដឹងពុទ្ធវចនៈឡើយ ។

សុរំ បិវន្តោ បុគ្គលឯណាក្រេបផឹកនូវសុរាទឹងមេរ័យ បុគ្គលនោះ លុះអស់ជីវិតហើយ ក៏ធ្លាក់ទៅសោយទុក្ខក្នុងមហារោរុវនរកអស់កាល

ជាយូរ លុះរួចពីនរកហើយ មកកើតជាយក្សប្រាំរយជាតិ ដោយអំណាចផលនៃអកុសលកម្មគឺការផឹកនូវសុរាទឹកមេរ័យនោះ ។

ផលនៃកម្មជាកុសលនឹងកម្មអកុសលទាំងពីរប្រការនេះ សម្តេចព្រះទ្រង់ព្រះគាត ត្រាស់ទេសនាថាជាវិបាកបច្ច័យ រាប់បញ្ចូលក្នុងបច្ច័យម្ភៃបួនប្រការដូច្នេះឯង ។

វិបាកបច្ច័យ ចប់ប៉ុណ្ណេះ

## អាហារបច្ច័យ

អាហារបច្ចយោតិ ឯត្ថ ចត្តារោ អាហារា កពឡីការាហារោ ផស្សាហារោ មនោសញ្ចេតនាហារោ វិញ្ញាណាហារោតិ កពឡីការោ អជ្ឈោហរិតព្វោ អាហារោ កពឡីការាហារោតិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងអាហារបច្ច័យតទៅ ដំណើរសេចក្តីថា អាហារបច្ចយោតិ ឯត្ថ ក្នុងអាហារបច្ច័យនោះ បានដល់អាហារបួនប្រការ គឺកវឡីការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។ អាហារទាំងបួនប្រការនេះឯងជាបច្ច័យឲ្យសត្វទាំងឡាយដែលមានអាហារផ្សេង ៗ ជាបច្ច័យ គឺពួកមួយមានកវឡីការាហារជាបច្ច័យ ពួកមួយមានផស្សាហារជាបច្ច័យ ពួកមួយមាន

មនោសញ្ចេតនាហារជាបច្ច័យ ពួកមួយមានវិញ្ញាណាហារជាបច្ច័យ ។

កវឡិង្ការាហារនោះ បាននឹងអាហារដែលបុគ្គលធ្វើឲ្យជាពំនូត ហើយបរិភោគ ជាឈ្មោះនៃបាយនឹងសណ្តែកជាដើម ជាអាហារដ៏គ្រោតគ្រាត ព្រោះហេតុវត្ថុកើតគ្រោតគ្រាត ជាអាហារដ៏ល្អិត ព្រោះហេតុវត្ថុកើតល្អិត ។ អាហារក្រពើគ្រោតគ្រាត ព្រោះវាលេបនូវដុំថ្ម ។ មោរានំ សុខុមោ អាហារនៃក្ងោកល្អិតជាងអាហារនៃក្រពើ ព្រោះក្ងោកទាំងឡាយស៊ីសត្វទីឃជាតិនឹងខ្ទួយជាដើម ។ អាហារនៃខ្លាល្អិតជាងអាហារនៃក្ងោក ព្រោះខ្លាទាំងឡាយស៊ីនូវកៅសត្វនឹងឆ្អឹងទាំងឡាយដែលចោលអស់បីថ្ងៃ គ្រាន់តែឆ្អឹងនោះត្រូវទឹកមាត់ខ្លាក្លាយ ក៏ទន់ដូចជាដំឡូង ។ អាហារនៃគជសារទាំងឡាយល្អិតជាងអាហារនៃខ្លា ព្រោះដំរីស៊ីស្មៅនឹងស្លឹកឈើ ។ អាហារនៃសកុណជាតិ សត្វស្វាបទាំងឡាយល្អិតជាងអាហារនៃគោនឹងម្រឹគ ព្រោះវាស៊ីគ្រាប់ស្មៅនឹងសត្វល្អិត ។ ជាដើម ។ អាហារនៃមនុស្ស ល្អិតជាងអាហារនៃសកុណជាតិ ។ អាហារនៃអមាត្យនឹងក្សត្រល្អិតជាងអាហារនៃមនុស្សធម្មតា ។ អាហារនៃព្រះបរមចក្រពត្តិ ល្អិតជាងអាហារនៃខត្តិយាធិបតី ដែលមិនមែនជាបរមចក្រពត្តិ ។ អាហារល្អិតនឹងគ្រោតគ្រាតជាងគ្នាជាជាន់ៗ ឡើងទៅ ព្រោះហេតុមានវត្ថុកើតគ្រោតគ្រាតនឹងល្អិត(១) ជាដើមដូច្នេះ ។

---

១) ពាក្យថា "អាហារគ្រោតគ្រាត" សំដៅយកអាហារមិនសូវល្អប្រណីត ។ អាហារល្អិត សំដៅយកអាហារល្អប្រណីត ។

ឧបាទិន្នកោបិ អត្ថិ អនុបាទិន្នកោបិ អ្នកប្រាជ្ញគប្បីដឹងថា កវឡីការាហារនោះមានពីរប្រការ គឺឧបាទិន្នកាហារ ១ អនុបាទិន្នកាហារ ១ ។ កវឡីការាហាររមែងនាំមកនូវរូបទាំងឡាយ មានឱជរូបជាគំរប់ ៨៨ ។

ផស្សាហារនោះ គឺផស្សៈ ៦ ប្រការ មានចក្ខុសម្ផស្សជាដើម ។ សោ អាហារោតិ ផស្សាហារនោះ រមែងនាំមកនូវវេទនា ៣ ប្រការ គឺសុខវេទនា ១ ទុក្ខវេទនា ១ ឧបេក្ខាវេទនា ១ ។

មនោសញ្ចេតនាហារនោះ រមែងនាំមកនូវភពទាំងបី គឺកាមភព ១ រូបភព ១ អរូបភព ១ ។

វិញ្ញាណាហារនោះ រមែងនាំមកនូវនាមនិងរូប ។ សត្វទាំងឡាយនឹងកើតឡើងបាន អាស្រ័យហេតុមានអាហារជាបច្ច័យ បើគ្មានអាហារជាបច្ច័យទេ នឹងកើតឡើងមិនបានឡើយ សមតាមព្រះពុទ្ធដីកាថា ផស្សវេទនាយ បច្ចយោ ផស្សៈជាបច្ច័យដល់វេទនា ។ ផស្សប្បច្ចយា វេទនានឹងកើតឡើង ព្រោះហេតុមានផស្សៈជាបច្ច័យ ។ ហេតុនោះ បានជាថាអាហារគឺផស្សៈនាំមកនូវវេទនាបីប្រការ និងអាហារគឺវិញ្ញាណ នាំមកនូវនាមនិងរូប ។

កវឡីការាហារ កាលមនុស្សគឺស្ត្រីនិងបុរសបរិភោគនោះ ធ្មេញខាងក្រោមសម្រេចកិច្ចជាត្បាល ធ្មេញខាងលើ សម្រេចកិច្ចជាអង្រែ លុះ

ទំពាររួច លេបចូលទៅក្នុងឧទរប្រទេស គឺពោះហើយ ភ្លើងធាតុដុតឲ្យឆ្អិនសព្វគ្រប់ល្អិតល្អហើយ ក៏ជ្រួតជ្រាបទៅពេញទាំងសរីរៈឥន្ទ្រីយ៍ ញុំាងអាការ ៣២ មានកេសាគឺសក់ជាដើម ឲ្យសម្រេចបរិបូណ៌ ។ អាហារនោះកាលបើភ្លើងធាតុដុតចំអិនមិនឆ្អិនសព្វគ្រប់ទេ ក៏ញុំាងរោគទាំងឡាយមានធាតុមិនប្រក្រតីជាដើម ឲ្យកើតឡើង កាលបើភ្លើងធាតុដុតឲ្យរលួយរលាយល្អិតល្អតាមប្រក្រតីហើយ បែកចេញទៅជា ៤ ចំណែក គឺសត្វទាំងឡាយស៊ី ១ ចំណែក តេជោធាតុដុតឲ្យឆេះ ១ ចំណែក ជាមូត្រគឺទឹកនោម ១ ចំណែក ជាករីសៈគឺអាចម៍ ១ ចំណែក ជារសជ្រួតជ្រាបទូទៅសព្វសរីរកាយ ១ ចំណែក ។

ហេតុនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា សត្វក្នុងភពទាំងពួងរមែងមានអាហារជាទីតាំង តាំងនៅដោយអាហារគ្រប់រូប ។ អាហារជាហេតុញុំាងសត្វទាំងឡាយឲ្យស្ថិតនៅបាន សមតាមព្រះពុទ្ធភាសិតដែលសម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ទុកថា សព្វេ សត្តា អាហារដ្ឋិតិកា សត្វទាំងឡាយ ទាំងពួងរមែងតាំងនៅដោយអាហារ បើប្រាសចាកអាហារហើយ ក៏មិនអាចតាំងនៅបានឡើយ ។

(នៅមានត)

# អ្នកមានគុណ (ត)

រៀបរៀងដោយលោក ហេង-សំអាន នៅសេនាធិការយោធភូមិភាគទី ១ ខេត្តកំពង់ចាម អតីតគ្រូបង្រៀនយុទ្ធសាស្ត្រ នៃមជ្ឈមណ្ឌលសិក្សាពលថ្មើរជើង ខេត្រពោធិសាត់

## រឿងស្វាកំផិលការតែញី

កាលពីអតីតយូរយារណាស់ ព្រៃក្រាស់ដុះក្បែរដែនកាសី
ជាព្រៃសម្បូណ៌សត្វបក្សី បក្សាប្រញីធីផ្លែស្វាយ ៗ
ពេលល្ងាចត្រជាក់ចូលសំបុក ដោយនៅស្រណុកសុខសប្បាយ
ព្រឹកឡើងនាំគ្នាហើរប្រញាយ ចឹកធីផ្លែស្វាយល្អតសេដា ៗ
ពេលនោះមានស្វាព្រៃចង្រៃ អង្គុយទុបដៃក្រោមព្រឹក្សា
គយគន់សំឡឹងរកផលា មន្ទ្យុតសេដាណាទុំទុំ ៗ
ស្ទុះលោតប្រតោងឈោងប្រឡេះ ស្រកលូកបេះផ្លែធំធំ
មន្ទ្យុតសេដាដែលទុំទុំ បែកស្វាក្រមុំធីសប្បាយ ៗ
ស្វាញីស្វាឈ្មោលពោលឆ្លងឆ្លើយ អូនអើយបងអើយហើយកៀកកាយ
ស្រឡាញ់គ្នាស្និទ្ធឥតក្លែងក្លាយ រួមរែកសប្បាយពន់ពេកក្រៃ ៗ
ស្រាប់តែខ្យល់ព្យុះបោកបក់មក បុករុញពពកមកបាំងថ្ងៃ
ងងឹតដុំជិតក្នុងព្រៃឋ្យ ខ្យល់ព្យុះខ្លាំងក្រៃបាក់មែកស្វាយ ៗ
បក្សាបក្សីឃើញខ្យល់ព្យុះ នាំគ្នាហើរចុះស្រះប្រញាយ
ចូលក្នុងសំបុកសុខសប្បាយ ផុតពីអន្តរាយខ្យល់កំណាច ៗ

កន្ទង់មួយសន្ទុះនោះភ្លៀងធ្លាក់ ខ្លោកខ្លោកឥតអាក់ធ្លាក់បាចសាច
រន្ទះបាញ់ផាំងគួរឲ្យខ្លាច ខ្យល់ព្យុះកំណាចបោកម្តងម្តង ។
ស្វាញីស្វាឈ្មោលគូរងងថ្មី ស្រុះចុះមកដីស្តីសាសង
អូនរងាណាស់ណ៎ាអ្នកបង ខ្យល់បក់ម្តងម្តងព្រឺរោមា ” ។
ស្វាឈ្មោលពោលថា “ ព្រលឹងរៀម នាងនៅឲ្យស្ងៀមណ៎ាពុំងា
រៀមបងក្រសោបឧបស្ថម្ភ ឲ្យបាត់រងាណ៎ាវរមិត្រ ” ។
ស្វាឈ្មោលកំពុងឱបញីជាប់ ឮសូរសន្ធាប់ព្យុះមកជិត
នាំគ្នារត់ជ្រកក្រោមដើមរិត ក្បែរដើមត្រើងត្រែងជិតដើមស្វាយ ។
ពេលនោះមានតាបធ្វើសំបុក ដេកនៅស្រណុកសុខសប្បាយ
គ្មានសត្រូវអ្វីបៀតបៀនកាយ សែនសុខសប្បាយឥតឧបមា ។
តាបក្រឡេកក្លែកគន់រំពៃ ឃើញសត្វស្វាព្រៃញីឈ្មោលណ៎ា
រងាញ័រខ្លួនពួនអាត្មា ជ្រកក្រោមរុក្ខាការភ្លៀងខ្យល់ ។
តាបឃើញដូច្នោះពោលថា “ បង ភ្លៀងទទឹកខ្លួនបងគ្មានសល់
ខ្ញុំសែនអាណិតគិតខ្វាយខ្វល់ សូមជូនយោបល់ដល់បងស្វា ។
បងមានកម្លាំងក្លាខ្លាំងក្រៃ មានជើងមានដៃដូចមនុស្សា
មាឌធំឧត្តមសមសក្តា ជាមហាក្សត្រាចតុប្បាទពិត ។
គួរណាស់តែបងធ្វើផ្ទះនៅ ការពារកំដៅព្រះអាទិត្យ
ភ្លៀងខ្យល់មកដល់ការពារជិត ពោះយប់ងងិតឥតគិតភ័យ ។

ចូរបងក្រឡេកមើលពួកយើង   គ្មានដៃគ្មានជើងយើងលកលៃ
ធ្វើសំបុកនៅផុតកិតភ័យ   អាស្រ័យក្នុងព្រៃយ៉ាងកក់ក្តៅ » ។
ស្ងាព្រៃកំបាំងអន្តរាយ   ឮពាក្យសំដីស្តីប្រដៅ
ក្រៅក្រោធពិពេធក្តុកក្តួលក្តៅ   មួរមៅខឹងតាបស្រែកជេរថា ។
« អញ្ចឹងអញពូជពង្សហនុមាន   ឫទ្ធិក្លាហានលើសលោកា
មិនដែលធ្វើផ្ទះដូចមនុស្សា   តាំងពីដូនតាពូជចម្បាំង ។
ហាលភ្លៀងហាលខ្យល់ពេលថ្ងៃយប់   នៅចូលឈប់យកកម្លាំង
បើមានសត្រូវនៅកកំង   តស៊ូប្រឆាំងចម្បាំងឲ្យខ្លាច ។
ចុះអាចាបឯងឈើក្បាលអី   ខ្ទមតូចកខ្វីស្តីប៉ោចប៉ោច
អញរើសំបុកគេហិនហោច   អញបោចបោះចោលឥឡូវណា ។
ឲ្យដឹងថ្វីដៃផៅសន្តាន   នៃហនុមានឫទ្ធិក្លា
ទោះគ្រុឌទោះនាគឬយក្សា   ខ្វប់ខ្លាចចេស្តានៃហនុមាន » ។
ចាបឃើញស្វាក្រោធប្រលោតខ្លាំង   ពោលអួតកម្លាំងខ្លាំងក្លាហាន
ភិតភ័យរន្ធត់ញាប់ញ័រប្រាណ   ខ្លាចស្វាសាមាន្យបានអង្វរ ។
« បងអើយបងស្វាឫទ្ធិក្លាខ្លាំង   ពួកអ្នកចម្បាំងខ្លាំងមិនមរណ៍
ពីដូនពីតាល្បីខ្ចាយខ្ចរ   ជាពូជមានធម៌ដ៏ឧត្តម ។
សូមអភ័យទោសប្រោសមេត្តា   នូវពាក្យណា ណាដែលមិនសម
សូមបងកុំបោចសំបុកខ្ញុំ   មានកូនតូច-ធំនៅនេះណា ។

បងអើយកូនខ្ទះទើបនឹងញាស់ កូនខ្ទះទៀតលាស់ដុះរោមា
មិនទាន់បេះហើរកកគ្គា ដោយខ្លួនឯងណា៎ណា៎ក្របី! » ។
ស្វាព្រៃមួរមៅក្តៅក្នុងចិត្ត គ្មានគិតអាណិតសត្វបក្សី
ស្ទុះឡើងដើមឈើរើក្រញី ទម្លាក់មកដីស្លាប់គ្រៀបគ្រា ។
មេហើរប្រញាយយំស្តាយកូន បោកខ្លួនស្លាប់សូន្យក្នុងព្រឹក្សា
ហ្វូងចាបនៅជិតគិតនឹងស្វា ផ្អើលពេញព្រឹក្សាទៅទីទៃ ។
លុះចប់អតីតនិទាន ខ្លាប្រាប់ទៅព្រានថា « កុំភ័យ
សូមបងទម្លាក់សត្វស្វាព្រៃ ទុកនាំគិតភ័យដល់ជីវិត ។
ព្រោះស្វាជាសត្វខូចចិលណាស់ ដូចរឿងរ៉ាវច្បាស់ពីអតីត
បើបងយកវាធ្វើជាមិត្រ នឹងឲ្យទោសពិតដល់មរណា » ។
ព្រានព្រៃទ្រុស្តមិត្រចិត្តគិរិយ ស្តាប់ពាក្យសំដីនៃសត្វខ្លា
គឺបែរប្រែចិត្តស្និទ្ធស្នេហា ជាមួយសត្វខ្លាយ៉ាងជិតដិត ។
គិតថា « បរបាញ់ពល់ថ្ងៃ-ខែ ខ្លាចតែសត្វខ្លាផ្តាច់ជីវិត
ឥឡូវបានខ្លាធ្វើជាមិត្រ អញលែងភ័យគិតគិតខ្លាចអ្វី » ។
គិតហើយព្រានព្រៃប្រានទម្លាក់ ស្វាសក៏ធ្លាក់ខ្ទាកដល់ដី
ខ្លាធំស្ទុះក្តែតចាប់ក្រញី ជាន់កប្រុងធំពេលនោះណា ។
ស្តេចស្វាធម្មបាលហាមាត់ស្រែញ មាត់ទើបធ្មេញបេញជ្រួញចង្កា
ដោយស្វាភ័យខ្លាចអំណាចខ្លា ញាប់ញ័រកាយាញើសហូរខ្លាយ ។

ឃើញស្វា មុខដូចផ្លែក្រូចសើច ជ្រួញខើចថាសើចលេងសប្បាយ
ក៏សួរទៅស្វាថា « អាអន្តកយ អាសើចសប្បាយដោយហេតុអ្វី? ។
អញនេះត្រូវចំកន្លែងល្អ កាច់កសម្លាប់ចាប់សាច់ខ្ចី
នឹងថ្លើមអាឯងទាន់ថ្មីថ្មី អញធីឲ្យឆ្ងាញ់មាត់អញម្តង ។
ស្វាសព្វដងពង្សពោធិសត្វ មានបារមីក្លាត់លើសសត្វផង
ប្រាជ្ញាថ្វាមុតក្រៃកន្លង និយាយសាសងនឹងខ្លាថា ។
ខ្លាអើយអើខ្លាអាសំឡាញ់ ចង់ស៊ីថ្លើមអញឆ្ងាញ់ពិសា
ថ្លើមនៅកន្ទុយឆ្ងាញ់ណាស់ណា៎ ថ្លើមឆ្ងាញ់ពីសាថ្លើមស្វាស » ។
ឮស្វាថាថ្លើមនៅកន្ទុយ មានរសជាតឈ្ងុយ ខ្លាលែងក
ស្រវាក់កន្ទុយនៃស្វាស ស្វាសែនត្រេកអរផុតឧបមា ។
ស្ទុះឡើងដើមឈើញញឹមព្រាយ ពកពាក់រុះកយនិយាយថា
« ម៉េចទៅថ្លើមអញឆ្ងាញ់ពិសា ឈ្ងុយឆ្ងាញ់យ៉ាងណាអាចង្រៃ » ។
ស្តេចខ្លាចាញ់កលធ្វើអឹមអៀន មៀមៀទៅកៀនគេចដោះដៃ
រត់បៀសកៀសខ្លួនពួនក្នុងព្រៃ ខ្មាស់ស្វាសក្រៃថ្វីនោះឯង ។
ស្វាសត្រេកអរពន់ពេកក្តាត់ ឃើញខ្លាគេចបាត់ពីកន្លែង
ចូលទៅជិតព្រានឥតគិតក្រែង សំដែងកក់ពាក់ហាក់សន្តាន ។
ពោលថា « ព្រានអើយអ្នកកុំព្រួយ ជីវិតអ្នកមួយខ្ញុំជួយបាន
អ្នកកុំគិតភ័យរន្ធត់ប្រាណ នៅឲ្យសុខសាន្តណា៎ព្រានណា៎ ។

គេនឹងយកកម្លាំងនៅទីនេះ　　ខ្ញុំទៅរកបេះខ្នុរបាយស្រា
ខ្នុរណាំងមង្ឃុតល្មុតសេដា　　ជូនអ្នកពិសាតាមសប្បាយ » ។
ថាហើយស្វាសចរចេញទៅ　　ចូលក្នុងព្រៃជ្រៅញើសហូរខ្លាយ
ស្វែងរកផលាក្នុងព្រៃឆ្ងាយ　　ដោយគ្មានដិនណាយកាយចិន្តា ។
　　ព្រានពាលកម្លៅខ្លៅទ្រុស្តមិត្ត　　ស្ទុះចូលទៅជិតកូនស្តេចស្វា
វាយវៃធាត់ធាក់បែកកាយា　　បែកក្បាលបាក់ស្មាបាក់ជើងដៃ ។
ហ្វូងស្វាផ្អើលជ្រួលទាំងតូច-ធំ　　ចោមរោមពទ្ធ័ហ៊ុំផុំព្រានព្រៃ
ស្ទុះចូលប្រុងខាំហែកជើងដៃ　　ព្រានព្រៃភ័យក្រៃទ្រហោយំ ។
ពេលនោះស្វាសចូលមកដល់　　ឃើញចលាចលផ្អើលពួកក្រុម
ស្វាឈ្មោលស្វាញីទាំងតូច-ធំ　　ពទ្ធ័ហ៊ុំប្រុងចាំខាំព្រានព្រៃ ។
ក៏ស្រែកសំឡុតឃាត់ស្វាថា　　« នែវើយក្រុមស្វាប្រញាប់ៗ
ចៀសចេញឲ្យផុតពីព្រានព្រៃ　　គ្នាភ័យរន្ធត់ព្រលឹងគ្មាន ។
តើរឿងហេតុអ្វីអ្នកកល់គ្នា　　ឆោឡោពាធាយាយីព្រាន ? »
ក្រុមស្វាទាំងឡាយថ្វាយពតិមាន　　ថា « ព្រានឈ្មានពានអនត្តិរិយ ។
វាយវៃធាត់ធាក់បុត្តធីតា　　បាក់ដៃបាក់ស្មាបែកសិរសី
ឈាមក្រហមប្រោលដាលពាសដី　　រលត់សញ្ញីសូន្យក្សីណក្ស័យ » ។
ស្វាសឃើញកូនសូន្យជីវិត　　ស្ទុះចូលទៅជិតឥតសង្ស័យ
លើកថ្នមបីបមដោយអាល័យ　　អង្អែលជើងដៃសព្វកាយា ។

កំប្រាប់ទៅថា « អ្នកទាំងឡាយ ចិត្តខ្ញុំសែនស្តាយបុត្តធីតា
ម៉ែឪក្នុងលោកជាកកាមា តែងតែស្នេហាកូនប្រុសស្រី ៗ
ខ្លួនខ្ញុំជាឪកំសត់ទូស្នេហ៍ កូនដូចដោះដៃណាក្រប៉ី
កូនខ្ញុំកំពុងពេញបេតី រលត់សញ្ញីសូន្យជីវ៍ ៗ
បើអ្នកទាំងឡាយសម្លាប់ព្រាន ត្រូវតែអ្នកហ៊ានខ្វះសន្យា
ព្រានស្លាប់ កូនខ្ញុំរស់វិញណា សឹមផ្តាច់ជីវ៍នៃព្រានព្រៃ ៗ
បើកូនខ្ញុំមិនរស់វិញទេ ត្រូវអ្នករិះរេគិតលកលៃ
ខ្លួនអ្នកមានទុក្ខជាប់ទោសពៃរ៍ យាមខ្មោចព្រានព្រៃតកូន-ចៅ » ៗ
ក្រុមស្វាទាំងឡាយថ្វាយបង្គំ លើកដៃប្រណម្យលុតលើស្មៅ
ទូលព្រះបង្គំល្មិតល្មន់ខ្លៅ សូមស្តេចប្រដៅច្បាប់បណ្ឌិត » ៗ
ស្តេចស្វាពោលថា « អ្នកទាំងឡាយ កុំក្តៅក្រហាយស្តាយជីវិត
របស់កូនខ្ញុំណា៎ ណាមិត្រ ព្រោះកម្មអតីតរបស់វា ៗ
បើយើងសម្លាប់ព្រានព្រៃទៅ កម្មពៀរជាប់នៅគ្រប់វេលា
តាមជាប់គ្រប់ជាតិឥតឃ្លាតឃ្លា សោយទុក្ខវេទនាជាអង្វែង ៗ
ដូចមានព្រះពុទ្ធភាសិត៖ កម្មតាមជាប់ស្អិតឥតកោតក្រែង
ដូចកង់រទេះគ្រប់កន្លែង កង់តែងវិលតាមជើងគោណា៎ ៗ

(នៅមានត)

# វិធុរជាតក (ត)

ទៅហលកណ្ដុំទិដ្ឋិកំ ។ យើងស្រដកណ្ដាចំណាន់ពីរប្រការ នៃនាងវិមលាទេវីនោះមិញ ស្រេចនូវប្រការអម្បាលនេះហោង ។ សោ វញ្ញកចំ សុត្វា ។ វិបុណ្ណកយក្ខនោះ ស្ដាប់ព្រះបន្ទូល ព្រះមហាក្សត្រនោះហើយ ទើបទូលថា បពិត្រមហាពជ ព្រះអង្គមានព្រះបន្ទូលម្ដេចដូច្នោះ វិសេះខ្ញុំតែ ១ នេះ មានកំលាំង មានលក្ខណៈប្រសើរលើស ឥឌសេះព្រះអង្គជារយជាពាន់ ១ ទឹងស្មើសេះខ្ញុំតែមួយនោះពុំបានឡើយ សូមពានព្រះអង្គទតកំលាំងសេះខ្ញុំហោង បុណ្ណកយក្ខ ទូលមហាក្សត្រ នូវប្រការអម្បាលនោះហើយ ផែលព្រួចរួចឡើងលើខ្នងសេះមនោម័យ ប្រពៃបរទៅលើកាតបន្ទាយ សឹងដ៏មានទំហំនោះ ៧ យោជន៍យល់មិនហាក់ជាសេះតែមួយឡើយ ហាក់យល់ដូចសេះជារយជាពាន់ ប្រកិត ។ នឹងគ្នា វិស័យ. ហាក់ដូចអ្នកដំកន្ទុយសេះនឹងគ្នា យល់ពាសពេញ លើកាតបន្ទាយហោង វិត្ថុបុណ្ណកយក្ខនោះ មិនយល់ប្រាកដឡើយ យល់ប្រាកដប៉ុន្ដែសំពត់ជម្ពូ បុណ្ណកយក្ខ ពោមពុន់នោះ យល់ហាក់ដូចអ្នកយកភ្លើងគ្រវីលើកាតបន្ទាយនោះហោង បុណ្ណកយក្ខបរសេះចុះមកហើយ ក្រាបទូលព្រះធនញ្ជយកោរព្យរាជថា បពិត្រមហារាជ ព្រះអង្គទតយល់ កំលាំងសេះមនោ-ម័យនេះ តើយល់ជាម្ដេចទៅព្រះអង្គ ព្រះបាទធនញ្ជយកោរព្យរាជមានព្រះបន្ទូលថា ហៃហៅកំពាយមាណពអើយ យើងយល់កំលាំងសេះទៅខ្លាំងហោង ឥតសេះឯណាទឹងផ្ទឹមសេះទៅបានឡើយ បុណ្ណកយក្ខ

ទូលថាមហារាជ ព្រះអង្គ មួយវិញទៀត កាលមុននោះ ខ្ញុំជិះបរផង ឥឡូវនេះខ្ញុំឲ្យប៉ុន្តែតួមនោម័យនោះទៅតែឯង បុណ្ណកយក្ខថាម៉្លោះហើយ ស្រដីទៀនមនោម័យថាហៃមនោម័យ ចូរព្រះស្ដៃងរត់ទៅ លើខ្នងទឹកស្រះមាននាក្នុងព្រះនគរ កណ្ដាលមុខព្រះលាន ព្រះមហាក្សត្រនោះៗ រីឯមនោម័យនោះ លុះឮពាក្យបុណ្ណកយក្ខ ទៀនជូញោះហើយស្ទុះហៀរហោះទៅមួយរំពេចលើទឹកស្រះនោះសោត នាបីរលក់ទឹកនឹងជិតក្រចកជល់តិចនោះគ្មានឡើយ មួយសោត ទោះបីស្លឹកឈូកក្រុមទេត្យលក្តីនឹងមានស្នាមស្នាកជាប់ជាបជល់តិចនោះគ្មានឡើយ ទើបបុណ្ណកយក្ខលាបាតដៃ ស្រែកហៅទៅមនោម័យថាហៃមនោម័យ ព្រះស្ដៃងមកឈរលើបាតដៃអញឥឡូវនេះឯង ឯមនោម័យឮពាក្យបុណ្ណកយក្ខ ស្រែកហៅជូញោះ ហើយកូវ ក្រជូវរត់អំពីនាយមកឈរលើបាតដៃ បុណ្ណកយក្ខមួយរំពេចនោះផង មិនយល់ជាបុណ្ណកយក្ខស្ទួយសេះមនោម័យឡើយយល់ហាក់ដូចកល់គេសូនក្រមួន ជារូបសេះ ហើយយកមកដាក់លើបាតដៃ បុណ្ណកយក្ខស្ទួយមនោម័យ ហើយចូលមកទូលមហាក្សត្រថា បពិត្រមហារាជ ព្រះអង្គទតសេះមនោម័យខ្ញុំនេះ តើយល់ជាម្ដេចព្រះអង្គ ជាសេះព្រះអង្គជារយជាពាន់ តើបាននឹងសេះខ្ញុំតែមួយឬទេព្រះអង្គ ? រីមហាក្សត្រស្ដាប់ហើយឆ្លើយថា ចៅកំចាយមាណពអើយ នាពាក្យចៅស្រដីនោះពិរោះគាប់ពិតហោង យើងរកសេះឯណាមកផ្ទឹមនឹងសេះចៅនេះមិន

បានឡើយ ទៅបុណ្ណកយក្ខទូលថា បពិត្រមហារាជ តែសេះមនោម័យ មិនទីនរកឲ្យស្មើគ្មាន ចំណាន់បើកែវមណីរត្នខ្ញុំនេះ នឹងជាល្អលើសអស់ កែវផងទាំងឡាយអេះ រីសេះមនោម័យនេះ ខ្ញុំទុកស្មេះនៅនេះ សូមទាន ឥឡូវនេះ ព្រះអង្គទតឯស្មើមណីរត្ននេះវិញ បុណ្ណយក្ខស្ដាយកែវមណីរត្ន នោះឡើង នឹងសំដែងថ្លែង ស្មើកែវមណីរត្ននោះហើយ ទើបទូលទៅព្រះ មហាក្សត្រ សូត្រជាបទព្រះគាថា: ឥទញ្ច មណិរតនំ ។ ថាបពិត្រ មហារាជដ៏ជាធំឧត្តមកន្ទង់ក្រៃលែងនឹងក្សត្រផងទាំងឡាយអើយ អញ្ជើញ ព្រះអង្គទតស្មើកែវមណីរត្ននេះមានជាដំពូក ។ មានស្រីផងសឹងមានគ្រឿង ប្រដាប់ សំពប់អាភ្នាទទៃ ។ ហើយមានសត្វម្រឹគបក្សី ខាគទ្វៃគ្រុឌរាជ យល់ប្រាកដ ក្នុងកែវមណីរត្ននេះ សូមព្រះអង្គទតមើលមានសេនាទាំង ៤ ដំពូក សេនាដំរី សេនាសេះ សេនារទេះ សេនាពលថ្មើរជើង សឹងកាន់ គ្រឿងអាវុធ ប្រកិតឈររៀងត្រូវផង សូមទានមហារាជ អញ្ជើញទត រមិលមើល មានទាំងទំពពាយល់ហានាន់ប្រាលពិតណិ នូវគ្រូត្រៃលែងកែង កំពែងក្លោងទ្វារ ប្រាការ ច្រើនសិងយល់ជាក់ច្បាស់ក្នុងមណីខ្ញុំនេះហោង មហារាជ សូមទានព្រះអង្គទតរមិលមើល មានទាំងពពួកសត្វបក្សីបក្សាផង ច្រើនផ្សេងៗ មានទាំងក្ងានក្ងោកបោលគោក តាវ៉ៅហង្ស ក្រៀលចង្កៀល ខ្យង ត្រយ៉ង កង់កេង ក្ងុំ ត្រុំ តាដក ចាកក្រពាក ដីវកដីរាក សិងដ៏ទំយំ នៅលើ កំពែងប្រាការក្លោងទ្វារ នោះយល់ជាក់ប្រាកដ ក្នុងកែវមណីរត្ន

នេះហោង មហាពជសូមព្រះអង្គ ទតមើលមើលមានតាំងនគរ ហើយមានកំពែងបាការក្លោងទ្វារយល់អស្ចារ្យ ត្រកាលក្រៃពេក ហើយមានតាំងទង់មាសទង់ប្រាក់ ត្រសាក់ត្រសុំល្អ នាស្ថាននោះសោត ផ្ទះដាសពាសពេញនូវខ្សាច់មាសផងច្រើន ហើយមាននូវសាលាជំនុំមន្ទីរតូចធំ ហើយមានពពួកប្រុសស្រីផង ដើរទៅមក ហើយមានតាំងផ្ទះអ្នកប្រមឹកស្រា មានតាំងផ្ទះតូចធំ មានផ្ទះផ្កាមាសតូចនូវផ្ទះផ្កាមាសធំ យល់ជាក់ច្បាស់ ប្រាកដក្នុងកែវមណីរត្នខ្ញុំនេះហោង មហាពជ សូមតាទព្រះអង្គទតមើលមើលមានតាំងអ្នកក្រងផ្កាមាលាក្បៀ មានតាំងអ្នកវិញខ្សែ មានតាំងអ្នកបោះ កប្បាស បោកសំពត់ មានតាំងអ្នកជាងទងជំមាស មានតាំងអ្នកចាស់ផ្ទាត់កែវ យល់ជាក់ច្បាស់ក្នុងកែវខ្ញុំនេះ មហាពជ ព្រះអង្គទតមើលមើល មានអ្នកពិសេស បេះចំអិន ក្រយាស្ងោយ មានតាំងអ្នកបេះមើលកំណាព្យកាបឃ្លោងគន្លោងគន្ទាស់ចំរៀងផង មានតាំងអ្នកបេះពាក្យ សំគោហោរទូងគេរី មានតាំងអ្នកបេះផ្លុំត្រែស័ង្ខប៉ីខ្លុយ មានតាំងអ្នកបេះកួតទ្រ ដេញតាប៉ុសាដៀវ មានតាំងអ្នកបេះទះទៃ បេះដំឡើង មានតាំងអ្នកបេះច្រៀងបេះរាំ នូវសារពើដូរ្យតន្ត្រីផងតាំង ៤ យល់ជាក់ប្រាកដ ក្នុងកែវមណីរត្នខ្ញុំនេះហោង មហាពជ ព្រះអង្គទតមើលមើល មានតាំងអ្នកប្រគប់ប្រដាល់ នូវកំលោត ពួនស្ទាក់ មានតាំងអ្នកបេះកំពេនក្បែក នូវកំពេនដាវ យល់ជាក់ច្បាស់ប្រាកដក្នុងកែវ

ខ្ញុំនេះហោង មហារាជ ព្រះអង្គទតរមិលមើលទៅអ្នកចំបាប់ ប្រចាប់ប្រកៀក ប្រកេះប្រកោះគ្នាបោកក៏តមក រីឯអ្នកឈ្នះនោះឈរនៅ រីអ្នកចាញ់រត់ចេញទៅ យល់ជាក់ច្បាស់ប្រាកដក្នុងកែវមណីរត្នខ្ញុំនេះហោង មហារាជ ព្រះអង្គទតរមិលមើលសត្វម្រឹគផងទាំងឡាយច្រើនជាដើម គឺរាជសីហ៍ ដំរី ជ្រូក ខ្លា រមាំង រមាស ឈ្លូស ចម៉ាខ្លាត្រី ក្របីព្រៃ ប្រើស ទ្រាយ ទន្សាយ ទន្សោង ខ្ទីងគោព្រៃ ស្វានស្វា ឆ្មា ចាផងច្រើន យល់ជាក់ច្បាស់ប្រាកដក្នុងកែវមណីរត្នខ្ញុំនេះហោង មហារាជ ព្រះអង្គទតរមិលមើល មានបក្សីផងច្រើនផ្សេង ៗ ជាដើមគឺហង្ស ក្រៀល ចង្កៀលខ្យង ត្រយ៉ង កណ្ដីង ក្ដុំ តាដក ចាកក្រពាកដីរុកដីវាក ក្ងានក្ងោក ចៅលរោគ តាវ៉ើផងច្រើន យល់ជាក់ច្បាស់ប្រាកដក្នុងកែវខ្ញុំនេះហោង មហារាជ ព្រះអង្គទតរមិលមើល មានទាំងត្រពាំងបឹងស្ទឹងស្រះ មានទឹកហូរថ្លាជ្រះស្រឡះទៅមក មានទាំងត្រីផងទាំងឡាយ ជាដើម គឺបង្កង់ ពិទូង ក្រពើ ឆ្លាម បបែល កំភេលផ្សោតនូវអណ្ដើកកន្ធាយ ត្រីសែ ក្រាសល្ហិច សឹង ហែបហែល អន្ទែលអន្ទែ ច្រៀវច្រៃទៅមក ដោយនូវលេករន្ធថា សឹងយល់ច្បាស់ប្រាកដក្នុងកែវមណីរត្នខ្ញុំហោង មហារាជ ព្រះអង្គទតរមិលមើល ទៅយល់អស់ទ្វីបទាំង ៤ គឺបូពិវិទេហទ្វីប ១ អមរគោយានទ្វីប ១ ឧត្តរកុរុទ្វីប ១ ជម្ពូទ្វីប ១ សឹងយល់ជាក់ច្បាស់ក្នុងកែវមណីរត្នខ្ញុំនេះហោង មហារាជ សូមទានព្រះអង្គទតរមិលមើល មាន

ទាំងព្រះអាទិត្យ ព្រះច័ន្ទ នូវអស់ផ្កាយផង ប្រទក្សិណក្នុងព្រះសុមេរុបព៌ត កជមានទាំងសត្តបរិភណ្ឌទាំង ៧ ហើយ មានទាំងព្រៃព្រះហេមពាន្តស្ថានប្រទេស មានទាំងសមុទ្រធំ ទាំង៤ យល់ជាក់ប្រាកដ ក្នុងកែវខ្ញុំនេះហោង មហាពជ ព្រះអង្គទតមើលមើល ឆកាមាសួគ៌ទាំង៦ ជាន់នូវសោឡសព្រហ្មសួគ៌ទាំង១៦ ជាន់ យល់ទាំងទេវបុត្រ ទេវតា ទេពកញ្ញាផងកម្សាន្តសប្បាយ ប្រលែងប្រចាប់គ្នាយល់ជាក់ច្បាស់ប្រាកដ ក្នុងកែវខ្ញុំនេះហោង មហាពជ សូមទានព្រះអង្គទតមើលមើល នៅស្រីក្នុងកែវនោះសឹងល្អ១០ ដំពូក មុខគួរពិតពិលមើលមើល ទៅយល់ល្អប្រពៃ គាប់ចិត្តពេកក្រៃ រីស្រីល្មៀងនោះសោត មាន២០ ដំពូក ស្រីដូចមៀតនោះ ១៤ ដំពូក ស្រីដូចមាស ២០ដំពូក ស្រីដូចប្រាក់នោះ ២០ ដំពូក ស្រីពណ៌ដូចខ្នងអណ្តើកមាសនោះ ៣០ ដំពូក ស្រីខៀវនោះ១៦ ដំពូក ស្រីហង្សស្បាទនោះ ២៥ ដំពូក រីកែវមណីរត្ននេះ ដ៏ពិចិត្រ នឹងទៅនូវផ្កានិល្យលុត្បល នូវផ្កាច័ន្ទន៍ មហាពជ ព្រះអង្គទតមើលមើល ឲ្យសព្វគ្រប់ដោយជ្រុងកែវមណីរត្នខ្ញុំនេះ មានស្រីនោះផ្ទេក ៗ ផ្ទេកបន្ទោររត់ប្រពាត់ មើលហើយគួរតែត្រេកអរមិនលែងឡើយ ៗ មណីកណ្ឋទិដ្ឋិត ៗ នេះស្រដីកាន់មណីរត្ន បុណ្ណកយក្ខ សំដែងថ្វាយព្រះមហាក្សត្រមិញសូមបេទូវប្រការអម្បាលនេះហោង ៗ ឯវត្តា ចន វត្តា បុណ្ណកោ គហិត្វាតុត្តមានសោ វេគេន គន្ត្វា ធម្មសភំ ចវិសិ ៗ រីបុណ្ណកយក្ខ ស្រដីសរសើរកែវមណីរត្ន នឹងសេះមនោម័យ នូវប្រការអំបាលនោះហើយ ទើប

ទូលទៅ មហាក្សត្រថា បពិត្រមហារាជ លេងស្កានឹងខ្ញុំនេះ ថា
បើខ្ញុំចាញ់ព្រះអង្គហើយ ខ្ញុំថ្វាយកែវមណីរត្ន ទឹងសេះមនោម័យ ជា
ដំណាំងស្កា ព្រះអង្គហោង ថាបើព្រះអង្គចាញ់ខ្ញុំ តើព្រះអង្គឲ្យអ្វីជា
តំណាំងស្កាខ្ញុំព្រះអង្គ ៗ ព្រះបាទធនញ្ជយកោរព្យរាជ ស្តាប់ហើយឆ្លើយ
ថា បើមាណពអើយ វៀរប៉ុន្តែខ្លួនអញ ទឹងព្រះរាជទេពី នូវស្វេតច្ឆត្ររាជ
សម្បត្តិ សំរាប់ព្រះរាជទ្រព្យឯណា សំណល់លែងនោះ អញទុកជាទ្រព្យ
ដំណាំងស្កាទៅហោង ថាបើទៅឈ្នះអញហើយ កំឝញតាមតែចិត្តទៅ
ទឹងប្រាជ្ញថាយកហោង បុណ្ណកយក្ខ ថាបពិត្រមហារាជ បើដូច្នោះព្រះអង្គ
កុំឲ្យយូរឡើយ ដ្បិតខ្ញុំនេះមកអំពីចម្ងាយ ពោះបើខ្ញុំចាញ់ឈ្នះក្តី ខ្ញុំនឹងគាល
ត្រឡប់ទៅឆាប់ សូមព្រះអង្គឲ្យរណ្តាប់ល្បែងស្កានោះ ឲ្យឆាប់ហោង
មហាក្សត្រស្តាប់ហើយ បន្ទូលទៅទឹងអស់អាមាត្យថាឯ ម្នាលអស់អាមាត្យ
ផងទាំងឡាយអើយ ចូរគ្នាទាំងឡាយទៅរណ្តាប់រោងស្កាឲ្យឆាប់ រីអា
មាត្យគ្នាក់ងារ តែងប្រដាប់រោងស្កានោះរួចដូចព្រះបន្ទាប់ប្រើនោះស្រេច
ហើយ ទើបក្រាលទីទៅនូវបៀមចំព្រែព្រំគន្ធទិព្វប្រដាប់កម្រាល ព្រះបាទ
ធនញ្ជយនោះផង កំរាលស្តេចមួយរយទឹងមួយនោះផង ៗ កម្រាល
បុណ្ណកយក្ខនោះផងទៀត ដោយនូវសំគួរជាទីស្តេច ទីកស្រ្តហោង លុះ
រៀបស្រេចហើយ ចូលទៅក្រាបទូល ព្រះមហាក្សត្រាធិរាជ ស្តេចស្តាប់
ហើយ មានព្រះបន្ទូលទៅនឹងស្តេចមួយរយ ទឹងមួយ ទឹងបុណ្ណកយក្ខថា ឥ
ឡូវនេះ រោងស្កាវៀបស្រេចហើយ គួរយើងទឹងលេងហោង ៗ

(នៅមានត)

# សមត្ថភាពគឺអ្វី

ព្រះមុនីកោសល សូ-ហាយ អធិបតីវេនគ្រុមជំនុំព្រះត្រៃបិដក
តែងរៀបរៀង

សមត្ថភាព ជាធម៌ចាំបាច់ជាទីបំផុត ដែលមនុស្សគ្រប់ជាន់ថ្នាក់ តែងត្រូវការ ។ ពាក្យថាសមត្ថភាពនេះ មកអំពីបាលីថា សមត្ថភាវោ ប្រែថា «ភាពអង់អាច ហ៊ានរៃ ប៉ុនប្រសប់ ធ្លៀវធ្លាស ឈ្លាសវៃ ពូកែ» ។ បាលីមួយទៀតថា បដិពលោ ប្រែថា «ការអង់អាច ។ល។ ដូចគ្នានឹងពាក្យថា សមត្ថភាពដែរ ឬ ប្រែចប់ស័ព្ទថា «ប្រតិពល» ក៏បាន

ពាក្យថា សមត្ថភាព នឹងពាក្យ ប្រតិពល មានសេចក្ដីដូចគ្នា ។ ពាក្យទាំងពីរម៉ាត់នេះ បើយើងត្រូវការយកមកនិយាយក្ដី សរសេរក្ដី អាចប្រើប្រាស់បានដូចគ្នា ។ ក្នុងអត្ថបទនេះ យើងសូមយកពាក្យ ប្រែថា «ពូកែ» មកធ្វើអត្ថាធិប្បាយ ព្រោះពាក្យថា «ពូកែ» ជាពាក្យសម្រាយ វប្បធម៌ របស់ខ្មែរយើងធ្លាប់ប្រើមកហើយ ដែលប្រែចេញមកអំពីពាក្យថា សមត្ថភាព ឬ ប្រតិពល ។ ពាក្យទាំងពីរម៉ាត់នេះ ជាឈ្មោះប្រាជ្ញាហ៊ានវៃក៏បាន ជាឈ្មោះកាយ ដែលប្រកបដោយសិល្បៈស្ទាត់ជំនាញក៏បាន

មនុស្សគ្រប់រូប សុទ្ធតែត្រូវការចង់ឲ្យមានសេចក្ដីពូកែអង់អាច

ឈ្លាសវៃនៅក្នុងខ្លួនទាំងអស់ ឥតមាននរណាមួយបដិសេធចោលនូវសេចក្តីត្រូវការឡើយ ។ ភាពនៃសេចក្តីត្រូវការនេះ តែងមាននៅក្នុងកាយរបស់មនុស្សស្ទើរតែគ្រប់គ្នាដែរ ប៉ុន្តែភាពត្រូវការនោះមិនស្មើគ្នាទេ គឺអ្នកខ្លះមានភាពត្រូវការច្រើនមុខ អ្នកខ្លះមានភាពត្រូវការតិចមុខ ឬក៏អ្នកខ្លះត្រូវការក្នុងផ្លូវនេះ អ្នកខ្លះត្រូវការក្នុងផ្លូវនោះ ឃើញថាភាពត្រូវការនេះផ្សេងៗគ្នាជាដរាប ដោយសេចក្តីប្រមូលថា មនុស្សដែលបានទទួលសេចក្តីសុខសេចក្តីចំរើនទាំងអស់ សុទ្ធតែកើតមកអំពីសេចក្តីត្រូវការ ។

ពាក្យថា «ត្រូវការ» នេះ មានច្រើនយ៉ាងណាស់គឺ ត្រូវការខាងការសរសេរ ត្រូវការខាងការអាន ត្រូវការខាងការទេសនា ត្រូវការខាងការស្តាប់ ត្រូវការខាងជាងឈើ ត្រូវការខាងជាងកំបោរ ត្រូវការខាងធ្វើមន្ត្រី ត្រូវការខាងពាណិជ្ជកម្ម ត្រូវការខាងកសិកម្ម ត្រូវការខាងចែវទូក ត្រូវការខាងបររទេះ ត្រូវការខាងបើករថយន្ត ។ល។ ភាពត្រូវការទាំងនេះ ត្រូវតែប្រឹងប្រែងធ្វើឲ្យមានក្នុងកាយក្នុងចិត្ត ទើបអាចដោះស្រាយបញ្ហាជីវិត ឲ្យបានសុខចំរើនខ្ពង់ខ្ពស់បានប្រាកដពិត ។ ការកើតមកជាមនុស្ស ក្នុងសង្គម ក្នុងប្រទេស ជាមួយគ្នាក្តី ផ្សេងគ្នាក្តី ត្រូវពឹងផ្អែកលើភាពត្រូវការជាដរាប ទើបយោងខ្លួនរួច ។

មនុស្សទាំងអស់ក្នុងសកលលោក ដែលទាក់ទងដោយករណីយកិច្ចខ្លះច្រើន ខ្លះតិច ខ្លះធ្ងន់ ខ្លះស្រាលពិតមែន ប៉ុន្តែការទាក់ទងទាំងនោះ

សុខតែឈមមុខទៅរកទីដៅតែមួយ គឺជីវិតប៉ុណ្ណោះឯង ។ ករណីយកិច្ច គ្រប់យ៉ាងរបស់មនុស្ស ប្រព្រឹត្តទៅ ដើម្បីរៀបចំជីវិត កសាងជីវិតរបស់ខ្លួន ឲ្យបានទទួលឋានៈថាជាជីវិតខ្ពង់ខ្ពស់ប្រសើរឡើងប៉ុណ្ណោះ ។

ហេតុដូចបានរៀបរាប់មកនេះ បញ្ជាក់ឲ្យឃើញថា ភាពពូកែរបស់មនុស្សក្នុងលោក មានពីរយ៉ាង ដោយសេចក្ដីរបរួមយ៉ាងខ្លីបំផុតដូចការរែកញែក ព្រមទាំងអធិប្បាយពង្រីកសេចក្ដីតទៅនេះ ៖

## ភាពពូកែ ២ យ៉ាង គឺ

១– បិត្តពូកែ គឺភាពពូកែនោះមុត រាងរៃ ក្នុងផ្លូវចិត្ត

២– កាយពូកែ គឺភាពពូកែដោយសុខភាព មានកម្លាំងកាយរឹងប៉ឹង ។

ពាក្យថា « បិត្តពូកែ » បានដល់សេចក្ដីត្រិះរិះគិតដោយចិត្ត ដែលស្ទាត់រាងរៃឆាប់រហ័សផង ទាំងសេចក្ដីគិតនោះច្រើនតែប្រកបដោយហេតុផលល្អផង ។ ភាពឈ្លាសវៃរបស់ចិត្ត ដែលអាចគិត អាចទទួលអារម្មណ៍បានច្រើនយ៉ាងនោះ ត្រូវប្រកបដោយហេតុពីរយ៉ាងទៀតគឺ សេចក្ដីទឹករឭកចាំបាន ចំពោះករណីយកិច្ចគ្រប់កាលទាំងអស់ ទាំងអតីត ទាំងបច្ចុប្បន្ន និងអនាគត ១ សេចក្ដីដឹងខ្លួន ក្នុងការធ្វើ ការនិយាយ និងការគិតគូរ ១ ។

ពាក្យថា « កាយពូកែ » បានដល់ភាពពូកែដោយកាយ ដែលប្រកបដោយសុខភាពល្អ មានសាច់ឈាមធំធាត់ល្មម មានកម្លាំងគ្រប់គ្រាន់

ផងមានសិល្បៈដោយការពិសោធន៍ ក្នុងរបៀបកីឡាឲ្យស្ទាត់ប្រាកដផង គឺ រាងកាយពូកែខាងដើរ ខាងរត់ ខាងលោតផ្លោះ ខាងប្រដាល់ ខាងហែលទឹក មុជទឹក ឬខាងកីឡាណាមួយ ដែលត្រូវប្រើដោយកម្លាំងកាយ ។ ភាពពូកែស្ទាត់ជំនាញដោយអាស្រ័យឥទ្ធិពលរបស់កម្លាំងកាយនេះ ហៅជាកាយពូកែ ។

ចិត្តពូកែ នឹង « កាយពូកែ » នេះ រកបានដោយក្រណាស់ ជាពិសេស យើងត្រូវកសាងខ្លួនឲ្យមានភាពពូកែទាំងពីរយ៉ាង ទើបជាការប្រសើរបំផុត ប៉ុន្តែភាពពូកែខាងចិត្ត មានរបៀបប្រសើរជាង ព្រោះថា កិច្ចការទាំងអស់ ដែលត្រូវធ្វើដោយកាយ ក៏សុទ្ធតែត្រូវអាស្រ័យចិត្តជាមុន ទើបប្រព្រឹត្តទៅបានដោយស្រួលល្អ ។ ឧទាហរណ៍ ដូចយ៉ាង ការសរសេរតែងសេចក្ដី និពន្ធចងក្រង ធ្វើជាសៀវភៅណាមួយ មនុស្សខ្លះ សរសេរតួអក្សរបានល្អ ទាំងរបៀបអក្ខរាវិរុទ្ធក៏ត្រឹមត្រូវល្អ ប៉ុន្តែសេចក្ដីក្នុងប្រយោគនីមួយ ៗ មិនសូវត្រឹមត្រូវ មិនថ្លៃថ្នូរដោយពាក្យពេចន៍ខ្ពង់ខ្ពស់ ឃើញថា សេចក្ដីក្នុងអត្ថបទនោះ ៗ មិនខ្ពង់ខ្ពស់ មិនមានគោលការណ៍ល្អ ដែលគួរអ្នកមើលចាប់ចិត្តបានឡើយ ។ អ្នកនិពន្ធនេះឈ្មោះថា មានភាពពូកែតែខាងកាយ មិនពូកែខាងចិត្តទេ លុះតែមនុស្សដែលមានចិត្តពូកែ កាយក៏ពូកែ ទើបសរសេររៀបរៀងតែងសេចក្ដីបានល្អគ្រប់លក្ខណៈ គឺទាំងតួអក្សរ ទាំងរបៀបអក្ខរាវិរុទ្ធ ទាំងសេចក្ដី ។

ការដឹងខ្លួនជានិច្ចគ្រប់ឥរិយាបថ មិនបណ្ដោយសតិសម្បជញ្ញៈ ឲ្យ

ឃ្លាតចេញអំពីចិត្ត ទើបជាហេតុនាំមិនឲ្យភ្លេចដើម ភ្លេចចុង ភ្លេចមុខ ភ្លេចក្រោយ ៗ ប្រៀបដូចអ្នកបររថយន្ត ដែលប៉ុនប្រសប់បរទៅតាមថ្នល់ ស្គាល់របៀបថ្នល់ដែលមានរបត់វៀចវេរ ឬក្តុកដង្ហុក តែងយកចិត្តទុកដាក់ចាំដាក់ជានិច្ចឥតភ្លេចភ្លាំង ទើបរថយន្តមិនពាសចេញអំពីថ្នល់ មិនថ្លោះធ្លោយ មិនប្រទះគ្រោះថ្នាក់ ដោយហេតុអ្នកបររថយន្ត មានស្មារតីបិតទៅក្នុងចិត្តជានិច្ច ទោះបីឆាក់ភ្នែកមើលទៅខាង ក៏ឆាកមើលតែមួយភ្លែត មិនបណ្ដោយឲ្យចក្ខុវិញ្ញាណ ចាប់អារម្មណ៍ដែលឃើញនោះឡើយ ៗ ការនឹករឭក ការដឹងខ្លួនជានិច្ច មិនភ្លេចភ្លាំងមិនធ្វេសប្រហែស នេះបាលីហៅថា សតិសម្បជញ្ញៈ ឈ្មោះថាជាធម៌មានឧបការៈច្រើនណាស់ ៗ

ចិត្តរបស់បុគ្គលណាដែលបរិបូណ៌ដោយសតិ នឹងសម្បជញ្ញៈ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាមាន សមត្ថភាព ឬហៅថា ចិត្តពូកែ គឺជាចិត្តនឹងធឹង ជាចិត្តសម្បូណ៌ដោយធម៌ជាជំនួយ កាលបើចិត្តពូកែ ទាំងកាយក៏បានហាត់រៀន តាមកម្មវិធីដែលប្រកបដោយសិល្បៈ ក៏រមែងនាំកាយឲ្យពូកែ ទៅតាមចិត្តដែរ ដែលហៅថា នាំកាយឲ្យមានសមត្ថភាព ដើរទៅជាមួយនឹងចិត្តដោយពិត ៗ

បុគ្គលកំពុងប្រកបការណាមួយ ត្រូវកំណត់ទុកជាមុនថា បើសតិសម្បជញ្ញៈ របស់អាត្មាអញជាប់កិច្ចការណាមួយយូរ ៗ ទៅ ច្រើនតែចិត្តឃ្លាតចេញអំពីគោលការ ដែលកំពុងធ្វើ ៗ ដំណើរនេះ ហៅថា

ចិត្តស្ទុះចេញរួចអំពីសតិសម្បជញ្ញៈ នាំឲ្យចិត្តនៅតែម្នាក់ឯង មិនមានធម៌ជាមិត្រសម្លាញ់នៅជាមួយ ជាហេតុនាំឲ្យថ្លោះថ្លោយក្នុងពេលនោះឯង ក្នុងរយៈពេលនៃចិត្តដែលប្រាសចាកសតិសម្បជញ្ញៈនេះហើយ ដែលហៅថាប្រមាទ គឺសេចក្តីធ្វេសប្រហែសរបស់មនុស្ស ដែលតែងកើតមានឡើងក្នុងពេលដែលចិត្តខ្វាតចេញអំពីសតិសម្បជញ្ញៈ ។ បុគ្គលមានចិត្តបែបនេះ សូម្បីដើរក៏ភ្លាត់ ធ្វើការក៏ភ្លាត់ និយាយក៏ភ្លាត់ សរសេរក៏ភ្លាត់ ៗ ការភ្លាំងភ្លាត់ ការភ្លេចនេះ ក៏នាំឲ្យទៅជាភ្លើ ព្រោះហេតុតែចិត្តមិនមាន សម្បជញ្ញៈ ជួយគ្របដណ្តប់អប់រំ យូរៗទៅក៏ក្លាយទៅជាមនុស្សខ្វះសតិសម្បជញ្ញៈ មិនអាចប្រើការកើត ដោយហេតុតែចិត្តអណ្តែតអណ្តូងតែលតោល មិនមានធម៌ជួយឧបត្ថម្ភ នេះឯងហៅថាចិត្តគ្មានសមត្ថភាព គឺចិត្តមិនពូកែ កាលបើចិត្តមិនពូកែ កាយដែលធ្លាប់មានសិល្បៈ ក៏មិនពូកែដែរ ។

គ្រាន់កាយរបស់យើងតាំងមូលនេះ បើដកចិត្តចេញផុតហើយ ឥតមានអ្វីជាតម្លៃទៀតទេ ហៅថា អស់សារប្រយោជន៍របស់កាយហើយ ចំណែកខាងចិត្ត កាលបើដកសតិសម្បជញ្ញៈចេញផុតហើយ ក៏ឥតមានអ្វីជាតម្លៃដូច្នោះដែរ ។ ចិត្តនិងកាយ ត្រូវតែប្រាស្រ័យទាក់ទងរួបរួមគ្នាដោយសាមគ្គីជាឯកភាព បរិបូណ៌ដោយសុខភាព ដោយសតិសម្បជញ្ញៈ ទើបហៅថា មានសមត្ថភាព គឺភាពពូកែវាងវៃទាំងចិត្តទាំងកាយ ក្នុងករណីយកិច្ចគ្រប់យ៉ាងដោយពិត ។ ចប់ ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង-ខាត់ រៀបរៀង*

(តមក)

---

អននុធ្យាយត្តិ កាលមិននឹកដល់ ។

អននុរូប គុ. ដែលមិនអនុរូប ដែលមិនសំគួរ ។

អននុម្មាន ន. បុំ កិរិយាប្រហែលធ្វេស ។

អននុសន្ធាន នបុំ កិរិយាមិនស្វែងរក ។

អននុសរណ នបុំ. កិរិយាមិនរឭកតាម ។

អននុដ្ឋាន នបុំ. កិរិយាមិនរក ឬមិនប្រតិបត្តិតាម ។

អនន្ឫត គុ. ដែលមិនខុស ពិត ។

អនន្ត គុ. ដែលមិនមានទីបំផុត ឋិតថេរ ។ បុំ. ព្រះសិវ ព្រះវិស្ណុ គេមះ នាមស្តេចនាគ ។ នបុំ. សេចក្តីទៀងទាត់ ។ – តា ស្រ្តី. ភាវនៃសេចក្តីទៀងទាត់ ។ – ក គុ. ដែលមិនមានទីបំផុត – វត្តិ គុ. ដែលមានសេចក្តីទៀងទាត់ – ករ គុ. ដែលធ្វើមិនឲ្យមានទីបំផុ ។ – កីតិ បុំ. ឈ្មោះមនុស្ស ។ – គុណតា ស្រ្តី. ភាវនៃ... មានគុណមិនមានទីបំផុត ។ - ចូទិន គុ. ដែលមានខ្នងកង់រាប់មិនអស់ ។ - ជារ គុ. ដែលមានត្រើយតីរីវដ្ឋារាប់មិនអស់ ។ វិជយ បុំ. ឈ្មោះខ្សងសង្ខនៃព្រះបាទយុធិឋ្ឋិរ ។ - សីរ បុំ ឈ្មោះមនុស្ស ។

**អនន្តរ** គុ. ដែលមិនមែនខាងក្នុង ដែលទៅភ្ជាម (ក្នុងអាកាស ក្នុងដូ ឬ ក្នុងពេល)

អនន្តធមិ ក្រិ. វិ. តាមលំដាប់ ។ ប៉ុ. បងប្អូនដែលមានអាយុបន្ទាប់ៗគ្នា
- ជ គុ. ប្អូនបន្ទាប់ ។ - ជាត គុ. ដែលកើតបន្ទាប់ ប្អូនបន្ទាប់ ។
- ជ្ញ គុ. ដែលមិនស្គាល់សេចក្ដីផ្សេងគ្នា ។

**អនន្តរិសសី** គុ. ដែលមិនមានអាវុធ្រនាប់ ។

**អនន្ត** នប៉ុ. កិរិយាមិនមានទីបំផុត ។

**អនន្ទ** ប៉ុ ឈ្មោះពិភពលោក ។

**អនន្ន** នប៉ុ. (វត្ថុ) ដែលមិនមែនជាអាហារ ។

(នៅមានត)

ម្ចាស់ផែនដី ១ អាមាត្យ ១ អាណាចក្រ ១
បន្ទាយ ១ ឃ្លាំង ១ សេនាឫទ្ធិភាព ១
សម្ពន្ធមិត្រ ១ ពលរដ្ឋ ១ សង្គមប្រជាករ ១
ទាំងអស់នេះ ជាអង្គនៃរាជ្យគឺប្រទេសជាតិ ។

ហិតោបទេស

# រឿងអាប៊ូលហ៊ាអ៊ូរីស

លោក ប៉ាយ-ស្មាត តំណាងក្រសួង ប្រែរៀបរៀង

(៣)

---

អា) ឃើញថាគាត់មានពុតបនតែយកអាសាខ្ញុំ ខ្ញុំមានចិត្តពោរពេញសប្បាយត្រេកអរក្រៃពេកទីបំផុតគ្មាន . . . . គាត់ក៏ប្រែមានទឹកមុខចំញែង ប.ញ្ញាចដូចមនុស្សត្រូវស្នេហ៍ ហើយគាត់អង្វរខ្ញុំឲ្យទៅនៅផ្ទះគាត់ ។ គាត់និយាយតទៅទៀតថា ៖ ខ្ញុំចាស់ហើយ ខ្ញុំជាអ្នកមានធនធានទ្រព្យសម្បត្តិស្តុកស្តម្ភ ខ្ញុំគ្មានកូន ខ្ញុំសុំយកអ្នកជាទាយាទ អ្នកទទួលមរតកពីខ្ញុំ . . . មាត់និយាយ ដៃគាត់លូកមកប្រហ៊ឱបរឹតខ្ញុំ ទៅនឹងដើមទ្រូងគាត់ ដូចជាខ្ញុំ កូនគាត់បង្កើតដូច្នោះ ។

លុះឃើញសក្ខីសញ្ញានៃសេចក្តីពក់ទាក់ពប់អាន ព្រមទាំងចិត្តស្រឡាញ់អាករពោយដោយមេត្តាដូច្នេះ ខ្ញុំក៏មានទំនុកទុកចិត្តអស់ពីពោះ ទើបដើរដោយស្លូតបូតតាមទៅគេហដ្ឋានគាត់ ។ ឯផ្ទះគាត់នោះសោតនៅទីក្រុងសុរ៉ាត ទឹងថាឥតសេចក្តីរុងរឿងសម្បូណ៌សប្បាយនោះ ឥតអន្លឹមានឡើយ នាំគ្នាដើរដល់ទៅផ្ទះ មាននាយឆ្មាំប្រដាប់ដោយឯកសណ្ឋានយ៉ាងល្អមកបើកទ្វារ ក្រឡេកក្នុងទៅទីលាន មានសួនពីរដាំផ្កាគ្រប់បែបគ្រប់យ៉ាង នៅកណ្តាលសួនពីរនោះ មានផ្លូវមួយទូលាយក្រាលបាយអរ៉ិន ហើយល្អ រលេចពណ៌ក្លីថ្លាជាងច្នៃកែវទៅទៀត ។ ផ្លូវនោះជាប់

ផុតឯផ្ទះធំតែម្ដង ៗ ថ្វីបើគ្មានលនមាសរលើបរលោង ដើម្បីឲ្យឆើត ឆាយទៅទៀតក៏ពិតមែន តែផ្ទះធំនោះមានគ្រឿងលំអ មានតុៈទូល្អ ៗ មិនដឹងបើនឹងកប់ ៗ កម្រាលនឹងព្រំទាំងឡាយ សុទ្ធសឹងតែរចនាលើសំ ពត់ តែសំពត់ទាំងនេះស្រស់បស់គួរស្ញើច ព្រោះមានសាច់ម៉ដ្ឋល្អលើស សំពត់ទាំងអស់ដែលមាននៅទីក្រុងម៉ាស៊ីលីប៉ាតាន ទីងតាមឆ្នេរសមុទ្រ កូរ៉ូម៉ង់ដែល ៗ

ជាបឋម លោកហៅខ្ញុំឲ្យងូតទឹកដូចលោកដែរ ក្នុងអាងទឹកមួយធំ ធ្វើពីថ្ម មានទឹកថ្លាត្រជាក់ស្អាត ៗ អាងទឹកនេះ តាមធម្មតា គឺសម្រាប់ លោកងូតទឹក ដើម្បីឲ្យត្រជាក់កាយលោក ហើយដើម្បីបំពេញករណីយ កិច្ចលោកខាងសាសនាផងដែរ ៗ នៅពេលងូតទឹករួចហើយ មាន ទាសាជាច្រើនយកសំពត់ស្ដើង ៗ មកជូតខ្លួនយើងទាំងពីរនាក់ ស្រេច ហើយ យើងទាំងពីរនាក់នាំគ្នាទៅអង្គុយ នៅក្នុងសាលមួយត្រង់តុៈមួយ ពោរពេញទៅដោយសាច់ច្រើនបែប ទីងម្ហូបអាហារក្នុងភាជន៍ពេរៀងខ្លួន ៗ បណ្ដាភោជនទាំងនោះ មានជាអាទិ៍គឺសម្លធ្វើពីផ្លែមុស្កាត ពីកាំពូនៃស្រុក ម៉ាកាស្សារ ពីទេពតារុស្សម្បូល្វែងនៃក្រុងសេរេនឌីប . . . ៗ ដល់ទទួល ទានអាហារភោជនឆ្អែតឆ្អល់តាមត្រូវការស្រេចហើយ យើងទាំងពីរនាក់ បានសេពស្រាឆ្នោត ដែលខ្ញុំឃើញថា មានឱជារសអស់ពីចិត្ត ៗ

លោកឪពុកថ្មីរបស់ខ្ញុំ លោកមានប្រសាសន៍កាន់ខ្ញុំជាលំដាប់លំ

ដោយខ្សឹបៗ ប្រើសំឡេងជាអាថ៌កំបាំង សេចក្ដីថា៖ ឪពុកនឹងប្រាប់កូននូវរឿងសម្ងាត់មួយ ដើម្បីជាបន្ទាល់សាក្សីនៃសេចក្ដីស្រឡាញ់ដោយស្មោះចំពោះរបស់ឪពុកទៅលើកូនឯង ។ កូនជប់ប្រាំថ្ងៃទៀត កូនស្ងួនអើយ ! ឪពុកត្រូវធ្វើដំណើរចេញពីទីក្រុង ស៊ីអាលី ទីក្រុងនេះប្រហែលកូនពុំដឹងទេ គឺជាកំពង់សមុទ្ររបស់កោះស៊ុកឹត ឪពុកនឹងធ្វើដំណើរទៅកាន់កោះមួយ ដែលឪពុកធ្លាប់តែទៅជារៀងរាល់ឆ្នាំ ។ ឪពុកគិតនាំកូនឯងទៅជាមួយផង ។ កោះនោះជាទីរហោឋានស្ងាត់កំបាំង មានសត្វខ្លាសាហាវពាសពេញ ។ កនុងកោះនោះ មានអណ្ដូងចំនួនជាពីររយសុទ្ធសឹងជាអណ្ដូងមានគជ់ខ្យង គជ់គ្រំធំៗ អស្ចារ្យ មានតែឪពុកម្នាក់ឯងប៉ុណ្ណោះទេ ដែលដឹងរឿងនេះ ។ មាននាយសំពៅម្នាក់បានប្រាប់ឪពុក នូវកំណប់ទាំងនេះ ព្រោះកាលឪពុកធ្វើជាទាសារបស់គាត់ គាត់ស្រឡាញ់ទុកចិត្តលើឪពុកជាទីបំផុត ហើយគាត់បានប្រាប់ឪពុកអំពីរបៀបត្រូវធ្វើយ៉ាងណាៗ អាចទៅជិតកោះនោះបាន ថ្វីបើមានសត្វកំណាចទាំងនោះ គឺយើងត្រូវលៃលកឲ្យទៅដល់កោះ នៅពេលយប់ហើយនាំគ្នាលបឡើងទៅ ដោយកាន់ចន្លុះអុជឆេះភ្លឺនៅដៃ ។ សត្វទាំងនេះ កាលបើឃើញភ្លើង វាភ័យផ្អើលជ្រួលជ្រាលស្ទុះរត់អស់ទៅអំពីអណ្ដូងដ៏មានតម្លៃវិសេសវិសាលទាំងនោះ យើងនឹងរកគជ់បានសន្ធឹកសន្ធាប់ទាំងការុង ៗ នាំមកទីក្រុងស៊ីពិតវិញ លក់ទៅបានប្រាក់

មិនដឹងបើនឹកថា ហើយប្រាក់ដែលយើងបាននោះ យកមកផ្សំគ្នាជាមួយនឹងទ្រព្យសម្បត្តិឪពុកដូចកូនឃើញនឹងភ្នែកស្រាប់ យើងនឹងទៅជាអ្នកមានគោរពទ្រព្យយ៉ាងសំបើម ប្រាក់កាសសម្បត្តិទាំងនេះ បុះឪពុកយកទៅណា! មុខជាឪពុកទុកឲ្យកូនទាំងអស់ ដល់ឪពុកស្លាប់បាត់បង់ជីវិតទៅ . . . . . ។ ដើម្បីឲ្យខ្ញុំជឿស៊ប់ គាត់នាំខ្ញុំ (អា.) ចូលទៅក្នុងបន្ទប់មួយ ហើយគាត់បង្ហាញប្រាក់រូបិយ៍គរទាំងពំនូក ៗ ឲ្យខ្ញុំមើល . . . ហើយគាត់និយាយមកកាន់ខ្ញុំទៀតថា អើ បើដូច្នេះ កូនសំឡាញ់អើយ ចូរកូនយកចិត្តទុកដាក់ឲ្យមែនទែន . . . . បុះកូនសប្បាយឬមិនសប្បាយនឹងធ្វើដំណើរទៅជាមួយនឹងឪពុក ចូរបាសំឡាញ់ប្រាប់ឪពុកឲ្យត្រង់មកចុះ!

– ខ្ញុំ (អា.) ឆ្លើយទៅវិញថា បាទ! ខ្ញុំសប្បាយនឹងធ្វើដំណើរទៅជាមួយលោកឪពុក តែសូមលោកឪពុកមេត្តាអញ្ញាតឲ្យខ្ញុំសរសេរសំបុត្រមួយទៅជំរាបឪពុកខ្ញុំ រៀបរាប់ហេតុផលទាំងឡាយ ដែលនាំឲ្យខ្ញុំសំចតទៅទីក្រុងសុរ៉ាតនេះមួយពេលសិន . . . ។

(ហ៊ី) – ពិតហើយ! ត្រូវសរសេរសំបុត្រទៅ! កាលណាកូនសរសេរសំបុត្រហើយ កូនឲ្យសំបុត្រនោះមកឪពុក ៗ នឹងបញ្ជូនឲ្យដល់ទៅឪពុកកូនឲ្យ (អា.) – ដូច្នេះ ខ្ញុំមានទំនុកទុកចិត្តទាំងស្រុងលើលោកហ៊ីហ្រ៊ម ក្នុងរឿងផ្ញើសំបុត្រនេះ ។ ដល់ថ្ងៃធ្វើដំណើរ យើងទៅចុះ

សំពៅទៅកំពង់ស៊ូមាលី ហើយបើកភ្លោងចេញទៅ ។ យើងបើកសំពៅអស់រយៈពេលបីសប្ដាហ៍ បានឃើញពីចម្ងាយនូវកោះតូចមួយ ហោប់ាន លោក ហ៊ីហ្គ្រីមថា ហ្នឹងហើយ កោះទុះយើងចតនាំ ហើយរង់ចាំដល់ពេលយប់ ទើបយើងចុះពីសំពៅទៅលើដីកោះ ។ នៅពេលនោះ កម្មករសំពៅទាំងឡាយត្រូវនៅចាំសំពៅ ។ មានតែលោក ហ៊ីហ្គ្រីម នឹងខ្ញុំ (អា.) តែពីរនាក់ប៉ុណ្ណោះ យើងនាំគ្នាយកចង់ជាច្រើនទៅផង សម្រាប់ដាក់គជ់ហើយនៅដៃយើង ។ កាន់បន្ទុះធេះក្ដៅ មានបន្ទុះជាច្រើនទៀត យើងកៀបនៅក្រោមក្លៀក ដើម្បីបើបន្ទុះមួយអស់យើងគុជបន្ដទៅទៀត ។ យើងនាំគ្នាដើរស្ទាប ៗ រកអណ្ដូង ហើយមិនយូរប៉ុន្មាន យើងប្រទះអណ្ដូងមួយ អណ្ដូងនេះជ្រៅជាងគេទាំងអស់ ។ លោក ហ៊ីហ្គ្រីម និយាយថា៖ កូនសំឡាញ់ ចូរកូនចុះទៅក្នុងអណ្ដូងនេះ ខ្ញុំជឿថាប្រាកដជាមានគជ់ល្អ ៗ ច្រើននៅទីនេះ . . . . ។

(អា.) – ខ្ញុំចុះតាមខ្សែពួរ លោក ហ៊ីហ្គ្រីម កាន់កន្ទុយខ្សែម្ខាង ។ លុះខ្ញុំដល់ទៅបាតអណ្ដូង ខ្ញុំភ្ញាក់ខ្លួន ខ្ញុំដឹងថាមានខ្សែងក្រោមបាតជើងខ្ញុំ ។ ខ្ញុំរើសខ្សែងទាំងនោះហើយប្រកចង់មួយពេញ ខ្ញុំចងចង់នោះភ្ជាប់ទៅនឹងខ្សែ ។ លោកហ៊ីហ្គ្រីម លោកទាញខ្សែយោងចង់មកលើស្រាយមើលពិនិត្យខ្សែង ដោយឃើញតែពន្លកគជ់ខ្ចី ។ គាត់ចងចង់ទៅវិញ ហើយទម្លាក់ទៅឲ្យខ្ញុំ ទាំងនិយាយថា៖ គជ់នៅក្នុងអណ្ដូងនេះ មិនទាន់ចាស់

ល្មមលក់បានទេ ។ កូនឯងដាក់ទៅឯបាតអណ្តូង ហើយយកដីលុប ទៅវិញ . . . ដល់ឆ្នាំខាងមុខ គដ់ទាំងនេះនិងដំ សមយើងយកវា ។

(អា.) ខ្ញុំធ្វើតាមលោកហ៊ីហ៊្សូមប្រាប់ ហើយគាត់ក៏ទាញយោង ខ្ញុំឡើងមកវិញ ។ យើងទាំងពីរនាក់នាំគ្នាទៅឯអណ្តូងមួយទៀត ជ្រៅ ជាងអណ្តូងទីមួយនេះទៅទៀត ។ អណ្តូងនេះឋិតនៅបាតនៃភ្នំមួយព្វដី កណ្តាលកោះ ។ ខ្សែក្នុងអណ្តូងនេះ មានគដ់ល្អ ។ ប្លែកខុសគេ ។ ខ្ញុំ ប្រមូលប្រកបដ៏ជាច្រើន លោកហ៊ីហ៊្សូមចេះតែទាញយោងមកខាងលើ ។

នាកាលគាត់បានគដ់ច្រើនគ្រប់គ្រាន់ ល្មមគាត់យករួចហើយគាត់ លែងទម្លាក់ខ្សែទៅទៀត ហើយមុខគាត់ទាំងញញឹម ។ ពេបជ្រាយ និយាយថា ៖

អញលាហើយអានាងអើយ! អញអរគុណហើយចំពោះកិច្ចការ អកុសលកខ្វក់ដែលឯងធ្វើឲ្យអញ . . . ។

(អា.) ខ្ញុំយល់បានថា នេះពិតជាកលឧបាយ នាំឲ្យខ្លួនខ្ញុំដល់ នូវមហាភ័យ មហាអាសន្នពន់ប្រមាណ ខ្ញុំក៏ស្រែកដង្ហោយថា ៖ ឳ! លោកឪពុក សូមលោកមេត្តា ។ ទាញយោងខ្ញុំចេញពីទីនេះ សូម លោកមេត្តា . . . ។

(នៅមានត)

# រឿងបងប្អូនពីរនាក់បែកមតិកគ្នា

លោក ដេង-ជ្រីម និពន្ធ (ត ចប់)

---

ដោយបានឃើញវែកមាស ហើយចង់បានក្រពេក បុរសបងឆ្លើយប្រាប់ទៅតាចាស់វិញថា៖ បាទ! លោកតា! ខ្ញុំបាទក្សរហើយ ទៀនតែក្សរហើយឥឡូវ ។

បុរសបង គ្មានបានឲ្យបាយមួយដុំដល់ឆ្កែសោះ ប្រាប់តែដេញឆ្កែឲ្យទាញនង្គ័ល បង្ខំឲ្យបានដាច់ហើយ ដើម្បីយកវែកមាសអំពីតាចាស់ដូចរបស់លោកជ្រាបស្រាប់ ឆ្កែនឹងមានកម្លាំងពីណាដូចគោ ម្ល៉ោះហើយ គ្នាខំប្រឹងទាញទាំងត្រដរ ណាបុរសបងវាយសំពងពីក្រោយ ។ ដោយភ័យនឹងរំពាត់ពេក ឆ្កែខំប្រឹងទាញនង្គ័លទាល់តែចេញឈាមមាត់ ។ ឯបុរសបង ដោយក្ដៅនឹងឆ្កែចេញឈាមមាត់ ទាញនង្គ័លមិនរួច ក៏វាយសំពងថែមទៀត ។ ទីបំផុត ឆ្កែទាំងពីរក៏ដួលដេករកទៅណាមិនរួច បាក់លោង ដោយត្រូវនឹងដំបងបុរសកំណាច ។

ឃើញដូច្នោះ ដោយអស់សេចក្ដីសង្ឃឹមថានឹងបានវែកមាស បុរសបងកើតចិត្តទោហោទោសោជាខ្លាំង ទើបស្រែកជេរឆ្កែថា៖ អាសត្វអពមង្គល អាសត្វចង្រៃ! អាសត្វហិនហោច! គេយកវែកមាសមកឲ្យ ៗ តែវាខំទាញនង្គ័លក្សរជឿហើយ វាពុំព្រមទាញ បើម្ចាស់វាក្សរ ម្ដេចវាខំទាញ

ឲ្យហើយទាល់តែបានវែកមួយ ៗ ម៉្លេះហើយអញក្តៅណាស់! អញមិនទុកអាឯងទេ ។

ថាតែប៉ុណ្ណោះហើយ បុរសកម្រោលកាយក្តៅទាល់តែក្រៀយ ហើយអូសយកទៅចោលនៅក្បែរមាត់ព្រៃ រួចវិលត្រឡប់ទៅផ្ទះធ្វើព្រងើយ ហើយរអ៊ូរទាំប្រាប់ប្រពន្ធថា អូនឯងមើលចុះ! យើងចំជាស៊យមែន! ព្រោះតែអាក្តួចព្រៃ វាមិនចំប្រឹងទាញឲ្យឯងសោះ កុំអីបានវែកមាសមួយ តាចាស់ម្នាក់យកវែកមាសមួយលៀនផ្លោមកដាក់ពីមុខ ថាឲ្យតែបងក្តួរដី ហើយ គាត់ទឹងឲ្យវែកនោះ អាក្តួចម្យៀត វាមិនព្រមទាញទាល់តែសោះ ឥឡូវខានបានវែកទៀត ខឹងពេក បងវាយវាសម្លាប់ចោលទៅហើយ ។

ប្រពន្ធជាស្រីកាឡកណ្ណីក៏ពេញចិត្តចំពោះអំពើអកុសល របស់ប្តីអាត្មា រួចពោលបន្ទរថា: ត្រូវបង! បងឯងធ្វើនោះត្រូវពិតប្រាកដ ត្រូវតែសម្លាប់វាចោល ព្រោះវាមិនជួយយើង ។

លុះកន្លងទៅបានមួយថ្ងៃ បុរសប្អូនមិនឃើញបងយកក្តមកឲ្យ គាត់ក៏ទៅឯផ្ទះបង ដើម្បីសួរទូវដំណឹងក្តួដែលបាត់ មិនឃើញយកទៅប្រគល់ឲ្យ ហើយគាត់សួរបងថា: ដូចម្តេចទៅក្តួខ្ញុំ បងមិនឃើញយកទៅឲ្យខ្ញុំ ? ឥឡូវក្តួទាំងពីរនៅឯណាបង ?

បងឃើញប្អូនទៅដល់ ទឹកក្តៅខ្លួល ។ លុះឮប្អូនសួរដូច្នោះ បងឆ្លើយមកទាំងខឹងថា: ប្អូនឯងកំសួរ អញក្តៅណាស់ អាក្តួចព្រៃ! តាចាស់

ម្នាក់ជាឲ្យកែវមាស ឲ្យតែភ្ជួរស្រែនោះហើយ អាគោចង្រៃ ក៏មិនចាំប្រឹង ជួយទាញនង្គ័លដើម្បីភ្ជួរឲ្យហើយសោះ បន្តិចឈប់ បន្តិចឈប់ ប្អូនឯងជួយពិចារណាមើល ធ្វើអីចឹង ក៏សមដែរឬ? ឲ្យតែវាជួយចំអូសបន្តិចទៅ ឯងបានកែវមាសស្រេចទៅហើយ ។

ប្អូនសួរទៀតថា: ហើយឥឡូវ គោខ្ញុំនៅឯណាបង? បងឆ្លើយទាំងយំប្រាប់ថា: ប្អូនឯងកុំសួររកវាធ្វើអ្វី អាគោអពមង្គលនោះ អញវាយសម្លាប់ចោលហើយ ។

និមិត្តតែឮសំដីអកុសលដូច្នោះ បុរសប្អូន ស្លុតចិត្ត ធ្លាក់ថ្លើមក្តុក ព្រោះអាណិតគោអាត្មាក្រៃពេក គឺគោនេះហើយជាប្រភព នៃសុភមង្គលរបស់ខ្លួន រួចគាត់សួរថា: បងឯងវាយសម្លាប់ហើយ យកទៅចោលនៅទីណា? – បងប្រាប់ធ្វើព្រងើយថា: អញអូសយកទៅចោលនៅមាត់ព្រៃ ក្បែរចំការអញឯនោះ ។

បុរសប្អូនមិននិយាយអ្វីតទៅទៀត ហើយទៅរកខ្មោចគោជាទីស្នេហា រួចដឹកនាំទៅកាន់សំណាក់នៃខ្លួន ។ គាត់ជីករណ្តៅកប់គោរបស់គាត់យ៉ាងស្រួល ដូចជាគេកប់ខ្មោចមនុស្ស ។ មិនយូរប៉ុន្មាន ស្រាប់តែមានដំពាំងឫស្សីពីរដុះចេញពីផ្នូរខ្មោចគោទាំងពីរនោះ ។ បុរសប្អូនមើលថែរក្សាបោសសំអាតក្បែរដំពាំងឫស្សីជានិច្ច ហើយកន្លងយូរមក ដំពាំងទាំងពីរក្លាយទៅជាឫស្សីពីរដើម ប្រកបដោយស្លឹកបៃតងស្រស់ ៗ គ្រប់ពេលទំ

នេះ បុរសប្អូនតែងទៅដេកលេងសម្រាកខ្លួននៅទីម្លប់ឬស្សី របស់គាត់ជាធម្មតា ស្ដាប់សូរសព្ទស្លឹកឬស្សីត្រូវខ្យល់បក់មក ដូចជាតូរ្យតន្ត្រី ។

រឿងប្លែកនេះក៏លេចឮជាដំណឹងដល់ទៅបុរសបងទៀតថា ឆ្កែដែលគាត់វាយសម្លាប់នោះ ឥឡូវដុះក្លាយទៅជាដើមឬស្សីមួយគុម្ពយ៉ាងស្រស់ នៅខាងក្រោយផ្ទះប្អូនគាត់ ខាងក្រោយដែលប្អូនគាត់យកខ្មោចឆ្កែទៅកប់ ។ ដំណឹងនេះធ្វើឲ្យបុរសបងកើតក្ដៅក្រហាយម្ដងទៀត ដោយគាត់គិតថាឯងសម្លាប់ឆ្កែចោល ឥឡូវឆ្កែនោះដួយចំរើនវា ដុះទៅជាឬស្សី បើដូច្នេះអញត្រូវតែបំផ្លាញឬស្សីនេះចោល កុំឲ្យសល់ជាតិឆ្កែទៅ ។ ពេលយប់ស្ងាត់ បុរសបងបានកាំបិតមួយយ៉ាងមុត លបទៅលួចកាប់ឬស្សីរបស់ប្អូនរំលំតាំងពីដើម ។

ព្រឹកឡើង បុរសប្អូនភ្ញាក់ពីដេក ឃើញឬស្សីរលំដូច្នោះ មានសេចក្ដីស្ដាយពន់ពេក ។ គាត់នឹកសង្វេគអាណោចអធម្មក្នុងចិត្តថា ឱ ! អ្នកណាអើយ ម្ដេចឡើយមានចិត្តព្យាបាទមកកាប់បំផ្លាញឬស្សីជាទីស្រឡាញ់ពេញចិត្តនៃអាត្មាយ៉ាងនេះ ។ បុរសប្អូនក៏យកឬស្សីតាំងពីដើមមកលួសពុះច្រៀកជាបន្ទោះ ហើយត្បាញបានជាជាលមួយ ។

គាត់យកមាន់ដាក់ឲ្យដេកនៅក្នុងជាលកាលយប់ ។ ស្រាប់តែមានការអស្ចារ្យកើតឡើងទៀត គឺព្រឹកឡើងស៊ុតមាន់តាំងប៉ុន្មានក្លាយជាដុំមាសទាំងអស់ ។ ដូច្នេះ កាលព្រឹក បុរសប្អូនតែងរើសយកមាសបួនដប់ដុំពីក្នុង

ជាលទ្រុងមាន់ជាធម្មតា ។

ដំណឹងស្តីពីជាលដែលធ្វើឲ្យមាន់ពងមកចេញដុំមាសឮ សាយទៅដល់បុរសបងម្តងទៀត ។ ដោយចង់បានដុំមាសដូចប្អូន ក្រុបគិតដល់កំហុសរបស់ខ្លួនលើកមុន បុរសបងស៊ូទ្រាំទាំងខ្មាស់គៀន ទៅខ្ចីជាលទ្រុងមាន់ពីប្អូន ដើម្បីយកមកដាក់ឲ្យមាន់ពង ។ គាត់ចាប់មេមាន់ប្រហែលដប់ដាក់ក្នុងជាល ដោយសង្ឃឹមថាព្រឹកស្អែក គាត់នឹងបានមាសដប់ដុំជាពិតប្រាកដ តែជាការផ្ទុយទៅវិញ គាត់មិនឃើញដុំមាស ក្នុងពេលដែលគាត់លូកដៃទៅរើស ត្រឡប់ឃើញសុទ្ធតែពស់វែកកំពុងបើកពាបំរុងចឹកដៃគាត់ទៅវិញ ។ បុរសបងកញ្ចក់ដៃចេញយ៉ាងរហ័ស ភ័យផ្អមមាត់ស្ទើរបាត់ព្រលឹង ។ សេចក្តីមួម៉ៅក្តៅក្រហាយក៏កើតមានឡើងដល់គាត់លើសលើកមុនៗទៅទៀត ។ សេចក្តីព្យាបាទខាងមនុស្សឃោរកើតមានពេញក្នុងសន្តានគាត់ៗ គិតជាមួយនឹងភរិយាថា យើងត្រូវតែលបសែងយកជាលទ្រុងមាន់ពេញសុទ្ធតែពស់វែកទៅដាក់នៅផ្ទះអាប្អូនអញ ដើម្បីឲ្យពស់ចឹកសម្លាប់ទាំងប្តីប្រពន្ធអស់ទៅ ទ្រព្យសម្បត្តិវា នឹងធ្លាក់មកលើយើងជាពិតប្រាកដ ។ នេះជាមធ្យោបាយគេប្រាក់បានដោយមិនបាច់ខំ ។

ប្រពន្ធយល់ឃើញត្រូវជាមួយផង ។ ដល់អធ្រាត្រយប់ស្ងាត់ ប្តីប្រពន្ធនាំគ្នាលើកសែងជាលទ្រុងមាន់ទៅលបទម្លាក់ទាក់ នៅត្រង់មាត់ទ្វារផ្ទះប្អូន រួចត្រឡប់តែយ៉ាងប្រញាប់មកផ្ទះអាត្មាវិញ ដោយសង្ឃឹមថាព្រឹក

ឡើង ទៀតតែបានដំណឹងល្អមកដល់ខ្លួនជាមិនខាន ។ តែមិនដូច្នោះ ហេតុតែកុសលនៃអំពើសុចរិតរបស់ប្អូន ពស់ក្នុងជាលទាំងប៉ុន្មានប្រែក្លាយជាដុំមាសទាំងអស់ នៅគរត្រង់មាត់ទ្វារផ្ទះ តែជាលនោះបាក់ខ្ទេចគ្មានសល់ ដោយសារការទម្លាក់យ៉ាងខ្លាំងរបស់បុរសបង ។

ក្រោយឡើង ភ្ញាក់ពីដំណេក បុរសប្អូនឃើញមាសនៅក្បែរទ្វារ ក៏ហៅប្រពន្ធឲ្យយកកញ្ជើមកកើបយកមាសចូលទៅក្នុងផ្ទះ ចំណែកជាលដែលបាក់ខ្ទេចនោះ គាត់នឹកស្តាយរកអ្វីប្រៀបគ្មាន តែមិនដឹងធ្វើដូចម្តេច គាត់ប្រមូលយកទៅបូជា ។ ឯផេះនៃជាល គាត់យកទៅកប់ក្នុងចំការ ។ ត្រង់កន្លែងកប់ផេះនោះ ស្រាប់តែឃើញមានដុះត្រឡាចចេញមក ។ បុរសប្អូនត្រេកអរ ខំថែថ្នាក់ថ្នមត្រឡាចមិនហ៊ានឲ្យនរណាទៅប៉ះពាល់ឡើយ ។

សូមដឹងថា ត្រឡាចនេះប្លែកពីត្រឡាចធម្មតា មានទងប៉ុនកដៃក្មេង ស្លឹកធំប៉ុនកញ្ជើ លាស់ទ្រលទ្រុបវារពេញតែចំការរបស់គាត់ ហើយមានផ្លែធំ ៗ អស្ចារ្យប្រមាណប៉ុនពាងលូ ។ ឃើញដូច្នោះ បុរសយើងមានសេចក្តីសប្បាយរីករាយក្រៃលែង ។

ដំណាលថា នៅព្រៃក្បែរនោះ មានស្វាមួយហ្វូង ពួកស្វានេះតែងតែមកលួចបេះផ្លែត្រឡាចគាត់ទៅស៊ីជារាល់ពេល ។ បុរសយើងសង្កេតទៅ ឃើញបាត់អស់ផ្លែត្រឡាចច្រើន ទើបគាត់ត្រិះរិះរកឧបាយដើម្បីចាប់ស្វា ។

ថ្ងៃមួយជាឱកាសល្អ គាត់បេះផ្លែត្រឡាចទាំងអស់ដឹកយកទៅផ្ទះ ហើយទុកឲ្យនៅសល់តែផ្លែត្រឡាចមួយដែលធំជាងគេ រួចគាត់លុងផ្លែត្រឡាចពីខាងក្នុយ យកពោះពោលចេញ ធ្វើយ៉ាងណាឲ្យគាត់អាចចូលទៅដេកសម្ងំនៅក្នុងផ្លែត្រឡាចបាន រួចយកសាច់ដុំក្នុយបិទភ្ជិតមកវិញ មើលទៅឲ្យឃើញដូចជាផ្លែត្រឡាចធម្មតា ។ ពេលយប់ស្ងាត់ បុរសយើងយកដំបងមួយទៅជាមួយផង ហើយលូនចូលទៅដេកពួនក្នុងផ្លែត្រឡាច ។

ពួកស្វាដែលធ្លាប់បានត្រឡាចស៊ី យប់អធ្រាត្រស្ងាត់ នាំគ្នាមកបេះផ្លែត្រឡាចនោះសែងយកទៅទីកន្លែងរបស់ខ្លួនឯងព្រៃភ្នំ ដើម្បីចែកគ្នាបរិភោគ ។ លុះនាំយកដល់រូងជាទីលំនៅហើយ ហ្វូងស្វាដាក់ត្រឡាចចុះ ។ បុរសយើងចេញពីក្នុងត្រឡាចភ្លាមជាមួយនឹងដំបង ស្ដេចស្វាឃើញបុរសយើងកេសំពង ភិតភ័យក្រៃពេក ក៏អង្វរសុំទុកជីវិត ហើយធ្វើសញ្ញាចង្អុលប្រាប់ដល់បុរសប្អូនឲ្យគំនរពេជ្រ ថាសូមឲ្យយកតាមចិត្តចុះ សូមកុំឲ្យតែសម្លាប់ ។ បុរសប្អូនក៏បើយកពេជ្រច្រកពេញហោប៉ៅអាវព្រមទាំងក្ដាប់នឹងដៃទាំងពីរ វិលត្រឡប់មកផ្ទះវិញ ។

ដំណឹងដ៏ប្រពៃនេះ មិនយូរប៉ុន្មាន ក៏លេចឮទៅដល់បងទៀត ។ ដោយបងបានពេជ្រដូចប្អូន បុរសបងក៏លាប្រពន្ធមកឯផ្ទះប្អូន ដោយសង្ឃឹមថាខ្លួននឹងក្លាយជាអ្នកមានដូចប្អូនមិនខាន ។ បងនិយាយទទូចអង្វរចំពោះប្អូនថាឲ្យប្អូនមេត្តាដល់ខ្លួន ដ្បិតខ្លួនក្រណាស់សព្វថ្ងៃ ឥឡូវសុំ

ប្អូនអាណិតឲ្យចូលក្នុងផ្ទៃត្រឡាចម្តង ៗ ប្អូនជាមនុស្សចិត្តល្អ អាណិតបង ក៏ព្រមឲ្យបងចូលក្នុងផ្ទៃត្រឡាច ដូចកាលដែលខ្លួនចូលនោះ ។

មានស្វាហ្វូងដទៃដែលធ្លាប់មកលួចផ្ទៃត្រឡាចដែរ តែពុំបានដឹងឧបត្តិហេតុដូចបានពោលខាងលើ យប់នោះក៏នាំគ្នាមកលួចបេះផ្ទៃត្រឡាចយកទៅ ៗ វាសែងទ្រផ្ទៃត្រឡាចផ្លាស់គ្នាច្រើនលើកច្រើនសា ព្រោះធ្ងន់ថ្ងៃកជាងធម្មតា ៗ ចំណែកបុរសបងដែលនៅក្នុងត្រឡាច បេះតែនឹកភ័យផ្អក ៗ មិនដឹងដល់ទីចំផុតនឹងមានហេតុកើតយ៉ាងណា ៗ កំពុងតែសែងត្រឡាចសួតាមមែកឈើធ្លងជ្រោះ ស្វាស្រែកប្រាប់គ្នាថា : ប្រុងប្រយ័ត្ន ៗ កុំឲ្យរបូតធ្លាក់ជ្រោះ ៗ លុះឮដូច្នោះ បុរសបងភ័យខ្លាចក្រែងស្វាទ្រផ្ទៃត្រ-ឡាចមិនជាប់ ហើយធ្លាក់ទៅក្នុងជ្រោះ ក៏កាន់តែបុកពោះខ្លាំងឡើងញ័រអស់តាំងខ្លួន ៗ ជាកម្មអកុសល ! បុរសបងភ័យពេក ស្រាប់តែធ្លាយផោម ៗ

សូមអស់លោកជ្រាប : ស្វានឹងខ្លួនស្អុយជាសត្វនឹងគ្នាពេក ៗ លុះធុំខ្លួនមិនស្រួល ស្វាសំឡឹងមើលគ្នាធ្មុំមុខជូរ មាត់សេញស្វាញទន់ដៃជើង ក៏ទម្លាក់ផ្ទៃត្រឡាចទៅក្នុងជ្រោះចោល ហើយដោយតាំងបុរសបងទៅផង ៗ –រឿងព្រេងស្តីពីបុរសបងប្អូនពីរនាក់ ចប់តែប៉ុណ្ណោះ ៗ

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ ។
> យូរ-អ៊ុន

ស៊ុនឃួនក៏និយាយល្បួងលោមថ្នមយកចិត្តឡេងថុងថា ខ្ញុំនិងអ្នកឯងនឹងកាំឡេងនេះ ឧបមាដូចត្រីនៅក្នុងអន្លង់ជាមួយគ្នា គួរតែតាំងចិត្តគិតចងមេត្រីនឹងគ្នា ធ្វើរាជការជាមួយគ្នាដោយប្រក្រតីទៅចុះ ទើបប្រសើរកេរ្តិ៍ឈ្មោះវែងឆ្ងាយ ។ ឡេងថុង ក៏ស្ងៀមមិនស្តី ។ ស៊ុនឃួនក៏ឲ្យត្រួតត្រាមើលសេនាទាហានគ្រប់គ្រងត្រៀមទុកព្រម លុះវេលាព្រឹក ស៊ុនឃួនក៏លើកទ័ពចូលទៅជិតស្រុកហាប់ប៉ា ហើយឲ្យតាំងបន្ទាយនៅទីនោះ ។

ខាងទៀវលៀវ ក៏ប្រមូលពលទាហានឡើងរក្សាលើបន្ទាយជាមាំមួន មិនបានប្រហែសធ្វេស លុះដឹងថា ស៊ុនឃួនលើកកងទ័ពទៅតាំងបន្ទាយជិតស្រុកហាប់ប៉ាហើយ ទៀវលៀវ ក៏គិតនឹងលើកពលចេញទៅតស៊ូច្បាំងគ្នានឹងស៊ុនឃួន ទទួលទាហានចូលទៅប្រាប់ទៀវលៀវថា ចូឆូឲ្យយកហិបតូចមួយមកជូនលោក ទៀវលៀវទទួលយកហិបនោះមកពិនិត្យ

មើល ឃើញសរសេរសោកប៉ងថា បើកាលណាមានសឹកសង្គ្រាមលើក មកញាំញីស្រុកហាប់ប៉ា ហើយតទល់ដល់នូវសេចក្ដីលំបាកប្រការម្ដេច ឲ្យបើកយកសំបុត្រក្នុងហិបនោះមកមើល ហើយធ្វើតាមចុះ ។

ខណៈនោះ ទៀវលៀវ ក៏ប្រឹក្សានឹងលីទៀន ឆាក់ជិនថា : ដែលនឹងចេញទៅតស៊ូនឹងស៊ុនគួននោះ ក៏នៅមិនទាន់ព្រមព្រៀងគ្នា ទៀវលៀវក៏បើកហិបចេញ ហើយយកសំបុត្រចូចមកមើលឃើញសេចក្ដីថា : បើស៊ុនគួនលើកទ័ពមកវាយស្រុកហាប់ប៉ាវេលាណា ឲ្យទៀវលៀវនឹងលីទៀន លើកទាហានចេញទៅតនឹងស៊ុនគួន ឲ្យឆាក់ជិននៅរក្សាស្រុក លុះទៀវលៀវមើលហើយ ក៏យកសំបុត្រនោះឲ្យទៅលីទៀន ឆាក់ជិនមើលៗ

លីទៀន ឆាក់ជិន ឃើញសេចក្ដីសំបុត្រហើយ ក៏និយាយនឹងទៀវលៀវថា បើសំបុត្រវុយកុងឲ្យមកដូច្នេះ លោកនឹងរិះគិតប្រការម្ដេច ទៀវលៀវថា ស៊ុនគួនដឹងថាវុយកុងលើកទ័ពទៅវាយស្រុកហាន់តុង ស៊ុនគួនមានចិត្តកំរើប ទើបលើកទ័ពមកវាយស្រុកយើង ៗ ត្រូវតែលើកទា-ហានចេញទៅតច្បាំងយកជ័យជំនះស៊ុនគួនឲ្យបានមុនសិន ដើម្បីឲ្យទាហានខាងយើងមានចិត្តកំរើបធ្វើការតទៅមុខទៀត រួចសឹមយើងគិតការតាមការតទៅ លីទៀនឮដូច្នោះក៏ស្ងៀម តែឆាក់ជិនឆ្លើយតបនឹងទៀវលៀវថា ស៊ុនគួនលើកទាហានមកគ្រានេះច្រើនណាស់ ទាហានខាងយើងតិចដែលនឹងលើកចេញទៅនោះ មុខជានឹងតទល់នឹងស៊ុនគួនមិនបាន គួរឲ្យ

គិតរក្សាស្រុកពីក្នុងឲ្យគង់នៅសិន ដើម្បីកុំឲ្យសត្រូវចូលមកក្នុងស្រុកបានៗ

ទៀវលៀវថា ដែលនឹងគិតរក្សាស្រុកនៅតែស្ងៀមដូច្នេះ នឹងមិនខុសពីក្នុងសំបុត្របណ្តាំយកុនឲ្យមកនេះទេឬ នរណានឹងនៅក៏នៅចុះ ខ្ញុំម្នាក់ឯងនឹងលើកទាហានចេញធ្វើការសង្គ្រាមតនឹងស៊ិនគួន ថាហើយក៏បង្គាប់ឲ្យតាក់តែងទាហាន លីទៀន ង៉ាក់ជិន ក៏និយាយនឹងទៀវលៀវថា បើដូច្នោះខ្លួនយើងត្រូវរួមសុខទុក្ខខុសត្រូវជាមួយគ្នា យើងនឹងសុំចេញទៅផង នឹងឲ្យតែទាហាននៅរក្សាស្រុកក៏បាន ៗ

ទៀវលៀវឮដូច្នោះក៏អរណាស់ និយាយនឹងលីទៀនថា វេលាយាម ៣ យប់នេះ អ្នកឯងត្រូវឲ្យទាហានព័ទ្ធចេញទៅទំលាយស្ពាន «សៀវកៀវ» ខាងទិសទក្សិណឲ្យអស់ចេញកុំឲ្យសត្រូវឆ្លងទៅមកបាន ហើយនាំទាហានទៅពួនបង្កប់នៅដំបន់សៀវកៀវនោះ ចាំស្កាត់កាប់ទ័ពស៊ិនគួន លុះដល់ព្រឹកឡើង យើងនឹងង៉ាក់ជិនលើកទាហានចេញទៅតាមកាប់ថែមទៀត លីទៀនយល់ឃើញត្រូវ ក៏លើកទាហានចេញទៅធ្វើតាមពាក្យទៀវលៀវបង្គាប់ លុះព្រឹកព្រហាមស្រាង ទៀវលៀវ ក៏ឲ្យង៉ាក់ជិនលើកទាហានជាកងបញ្ឆោត ឯខ្លួនទៀវលៀវ លើកទាហានចេញទៅពួនបង្កប់ចាំខ្ទប់កាប់ប្រសព្វគ្នា ៗ

ខណៈនោះ ស៊ិនគួននឹងឡេងថង ក៏លើកកងទ័ពកន្លងចូលទៅ ឯកាំឡេង នឹងលីបង ដែលជាកងមុខនោះ លុះឃើញង៉ាក់ជិនលើកទា-

ហានចេញមកពីក្នុងបន្ទាយ កាំឡេងក៏បរសេះចូលតប្បាំងនឹងអ៉ាក់ជិនបាន
១០ ភ្លេង អ៉ាក់ជិនធ្វើជាញាក់សេះថយរត់ ចូលទៅតាមមាត់ផ្លូវសៀវ-
កៀវ ហើយស្រូតបរសេះវេះទៅតាមផ្លូវបែក លីបងឃើញបានចំណាប់
ស្រួល ក៏បរពលចូលទៅជាជំនួយពីក្រោយ ស៊ុនគួនឃើញដូច្នោះក៏បំ
បោលសេះដេញទាហានតាមទៅទៀត រហូតដល់កន្លែងដែលទៀវលៀវ
ពួនបង្កប់ទ័ព ទទួលឮសូរផាវជាសញ្ញា ឮសូរហ៊ោកញ្ជ្រៀវជាគឹកកង
ឃើញលីទៀននៅខាងឆ្វេង នាំទាហានចេញមកវាយប្រសព្វជាច្រើន
ឃើញទៀវលៀវនៅខាងស្តាំ នាំទាហានចេញមកវាយខ្ទប់ប្រសព្វគ្នាទាំង
សងខាង ចូលប្រកាប់សម្លាប់ទាហានច្រើនណាស់ ទាហានទាំងនោះ
ក៏ប្រះរត់ខ្ចាត់ខ្ចាយបែកប្រពាក់ប្រពួន ស៊ុនគួនក៏បរាជ័យភ័យតក់ស្លុត
មហិមា ឯកាំឡេងនឹងលីបង ក៏ដេញអ៉ាក់ជិនជ្រុលហួសទៅ នឹងឲ្យទាហាន
បរសេះបំពានវិលមកក្រោយឲ្យហៅគ្នាទៅជួយ ក៏ទើសនឹងទាហានទៀវ
លៀវចេញមករាំងស្កាត់ជាប់គាន់គាប់ច្រើនណាស់ ។

ខណៈនោះស៊ុនគួន ក៏នៅសល់ទាហានពីស្លាប់ប្រហែល ៣០០
នាក់ ឡេងថងក៏និយាយនឹងស៊ុនគួនថា លោកចូលឆ្លងតាមស្ពានទៅឲ្យ
ដល់ត្រើយម្ខាងជាប្រញាប់ចុះ ទើបរួចពីអន្តរាយ និយាយមិនទាន់ផុតមាត់
ទទួលទៀវលៀវលើកទាហានដេញឡេងថងតាមពីក្រោយទៅទៀត ស៊ុន
គួនក៏បំបោលសេះរត់ឆ្លងតាមស្ពានថ្មទៅត្រើយខាងលិច ឃើញចុងស្ពាន

នោះដាច់ផុតគ្មានជំណា ទៅដល់ត្រើយចម្ងាយប្រហែល ៩ ហត្ថ ១០ ហត្ថ ស៊ិនគួនភ័យស្លុតស្មារតីគិតថា គ្រានេះមុខជាមិនរួចជីវិតទិនសត្រូវនេះឡើយ ហើយក៏ញាក់សេះថយមកក្រោយវិញ ក៏ថយមកមិនបាន ព្រោះទាហានទៀវលៀវដេញតាមស្ពានពីក្រោយ ទៅដល់ត្រើយពីខាងកើត ហើយមានទាហានម្នាក់ដែលតាមទៅជាមួយ ក៏ជួយរំលឹកស្មារតីស៊ិនគួនថា លោកញាក់សេះបរទៅមុខទៅ លុះទៅដល់កណ្ដាលស្ពានឲ្យលោកបន្ទំបំផាយសេះឲ្យវាស្ទុះលោតឆ្លង ត្រង់ស្ពានដាច់ ទើបដល់ផែនដី ស៊ិនគួនក៏មានស្មារតីយល់តាម តាំងតែកយបំផាយសេះទៅ សេះនោះក៏ស្ទុះអស់ទំហឹងប្រឹងលោតទៅដល់ផែនដីត្រើយម្ខាង ទទួលស៊ុសេងទិនតាំងស៊ិតជិះទូកតូចមួយទៅដល់ទីនោះ ក៏បង្ខំទាហានឲ្យចែវទូកទៅទទួលស៊ិនគួនចុះទូកបាន ឡេងថងដែលនៅពីក្រោយ ក៏ទទួលរង់តស៊ូទិនទៀវលៀវ ៗ ក៏កាប់ទាហានឡេងថងស្លាប់អស់ទាំង ៣០០ នាក់ ។

ឯកាំឡេងទីងលីបង បានឮស្គរទាហានហ៊ោកញ្ជ្រៀវពីក្រោយគឹងកងដូបោះ ក៏នាំទាហានចូលបម្រុងទៅជួយស៊ិនគួន ទទួលប្រទះនឹងលីទៀន ក៏តាំងប្រយុទ្ធគ្នានៅយូរណាស់ ឆាក់ជិនក៏នាំទាហានលបត្រឡប់ចូលពីក្រោយ ឃើញលីទៀនទឹងកាំឡេងលីបង កំពុងប្រកាប់គ្នាក៏ស្ទុះចូលទៅជួយលីទៀន ៗ នឹងឆាក់ជិន ក៏កាប់សម្លាប់ទាហានកាំឡេងស្លាប់ជាច្រើនណាស់ ឡេងថងអស់ពលសល់នៅតែខ្លួនម្នាក់ឯង ឯខ្លួននោះ

ក៏ត្រូវរបួសដោយអាវុធមុតដាច់ជាច្រើនអន្លើលើសកម្លាំង ទឹងទ្រាំតពុំឈ្នះ ក៏ប្រះត្រឡប់សេះស្ទុះបំបោលទៅ ទៀវលៀវក៏ដេញទៅដល់ចុងស្ពាន ប្រទះនឹងលីបង កាំឡេងនឹងទាហានប្រហែល ១៤.១៥ នាក់ ទាំងអស់គ្នានោះក៏លោតចុះពីលើសេះ លោតចុះទៅក្នុងទឹកស្ទឹងប្រឹងហែលទៅ ស៊ុនគួនឃើញដូច្នោះ ក៏ឲ្យថយទូកចេញទៅទទួលទាំងអស់គ្នាឲ្យឡើងមកលើទូក ហើយក៏ឲ្យចែវជម្រន់ទៅកំពង់យីស៊ូដែនស្រុកកាំងតាំង ហើយឲ្យតាំងបន្ទាយនៅលើគោក ។

ខណៈកាលស៊ុនគួនបែកទ័ពទៅនោះ ទាហាននឹងអ្នកស្រុកកាំងតាំងទាំងស្រីទាំងប្រុស ក៏រេះតែញញើតខ្លាចថ្វីដៃទៀវលៀវជាប់ក្នុងចិត្ត សូម្បីកូនក្មេងដែលលេងនឹងគ្នាហើយយំ បើមានគេបន្លាចហើយចេញឈ្មោះទៀវលៀវវេលាណា ក្មេងនោះក៏ខ្លាចតក្កមាមិនហ៊ានយំសោះ ស៊ុនគួនវេលានោះ ក៏មានសេចក្ដីទោមនស្សត្រូបចិត្តណាស់ តាំងតែបញ្ចុះបញ្ចូលពលទាហានប្រាថ្នានឹងលើកទៅសងសឹកទៀវលៀវវិញ ហើយឲ្យសំបុត្របកទៅដល់ឡោសុកសេចក្ដីថា ឲ្យឡោសុកប្រញាប់បញ្ជូនទាហានឲ្យទៅដល់ ដើម្បីនឹងលើកទៅវាយយកស្រុកហាប់ប៉ាទៀត នឹងចាប់យកខ្លួនទៀវលៀវ ឲ្យបានសម្លាប់ចេញ ។

ឯទៀវលៀវនោះ លុះមានជ័យជំនះស៊ុនគួនហើយ ក៏លើកទាហានត្រឡប់ចូលទៅស្រុកវិញ រេះតែគិតបារម្ភខ្លាចក្រែងស៊ុនគួនបែកទៅគ្រា

នេះ នឹងគេណ្ហទាហានមកបំពេញទ្វេឡើងជាច្រើន នឹងសងសឹកយើងវិញមិនលែង ឯទាហានក្នុងស្រុកហាប់ប៉ានេះក៏មានតិចផង មុខជាតស៊ូនឹងស៊ិនគួនមិនបាន គួរនឹងប្តឹងទៅចូច្ចឲ្យលើកទ័ពមកជួយ គិតហើយក៏ធ្វើសំបុត្រប្តឹងជូនដំណឹងរាជការទៅដល់ចូច្ច តាមដែលមានជ័យជំនះស៊ិនគួននោះគ្រប់ប្រការ ហើយថាវេលានោះក៏នៅមានបារម្ភក្រែងស៊ិនគួននឹងលើកកងទ័ពទៅទៀត ព្រោះទាហានក្នុងស្រុកហាប់ប៉ានោះស្តួចស្តើងណាស់ សូមឲ្យយកងលើកទ័ពទៅជួយ លុះតែងសំបុត្រហើយក៏ប្រើស៊ីថៃឲ្យកាន់ចូលទៅ ៗ ស៊ីថៃនោះលុះទៅដល់ស្រុកហាន់តុងហើយក៏យកសំបុត្រនោះទៅជូនចូច្ច ។

ចូច្ចទទួលសំបុត្រមើលដឹងសេចក្តីហើយ ក៏ប្រឹក្សានឹងទាហានទាំងពួងថា យើងនឹងគិតប្រការម្តេច ៗ ឡៅហួថា ដែលនឹងលើកកងទ័ពទៅវាយយកស្រុកសែឈួននោះ ត្រូវបង្អង់ឈប់សិនចុះ ព្រោះឡៅពីប្រុងប្រៀបទាហានមានត្រៀមទុកជាច្រើនណាស់ ប្រុងនឹងការពារស្រុកសែឈួនមិនឲ្យអន្តរាយ ឯស្រុកហាប់ប៉ានោះ ក៏ជាមណ្ឌលមួយធំ បើលោកលះបង់មិនគិត ស៊ិនគួនជាបច្ចាមិត្រនឹងលើកកងទ័ពទៅវាយយកទទេជាឥសារ បើបែកស្រុកនោះកាលណា ក៏គង់នឹងក្តៅរំជួលទៅដល់ក្រុងហ៊ូតោទៀត ហេតុនេះ សូមឲ្យលោករៀសរៃ លើកទៅជួយស្រុកហាប់ប៉ាជាប្រញាប់ចុះទើបនឹងស្រួល ចូច្ចក៏ទទួលថាត្រូវ ទើបនិ-យាយថា ក្អំគេងគុនសាន់ នឹងក្អំបង់ថៅងៀម ២ ដំបន់នេះជាមាត់ប្រក

ស្រុកហាន់គុន ត្រូវឲ្យហៃហ៊្វអៀន ឃុំទាហាននៅរក្សាត្រង់ភ្នំគេងគុន-សាន់ ឲ្យទៀវខាប់នៅរក្សាត្រង់មាត់ប្រកផ្លូវភ្នំបង់ថៅងៀម ហើយក៏ចាត់វ៉េងទាហានបាន ៤០ ម៉ឺន ប្អូនក៏លើកទៅដល់ស្រុកហាប់ប៉ា ហើយនាំទៀវលៀវ លីទៀន នឹងអ៊ាក់ជិន លើករំលងចូលទៅត្រង់ដែន តដែនស្រុកកាំងតាំង តាំងបន្ទាយនៅទីនោះ ។

បំរើសេះក៏នាំយកសេចក្ដីចូលទៅប្ដឹងស៊ុនគួនថា ឥឡូវប្អូនលើកគង់ទ័ពប្រហែល ៤០ ម៉ឺន មកបោះបន្ទាយនៅព្រំប្រទល់ដែនស្រុកហាប់ប៉ា នឹងស្រុកយើងហើយ ។ ស៊ុនគួនឮដូច្នោះក៏ភ័យខ្លាំងណាស់ ទើបចាត់ប្រើតាំងស៊ុតនឹងស៊ុសេង ឲ្យនាំទូកចម្បាំង ៩០ ចេញទៅកាំងទ័ពនៅមាត់ពាមយ៉ីស៊្វ ប្រើគាន់ប៉ូឲ្យនាំទាហានទៅយាមល្បាតតាមក្បែរមាត់ទន្លេ ។ ទៀវចៀវក៏និយាយនឹងស៊ុនគួនថា វេលានេះប្អូនទើបនឹងលើកពលមកដល់ ពលក៏កំពុងហត់នៅឡើយ គួរនឹងលើកទ័ពទៅខ្ទប់វាយឲ្យទាហានប្អូនថយកម្លាំងចុះទើបនឹងធ្វើការមានជ័យជំនះគេទៅ ស៊ុនគួនយល់ឃើញត្រូវ ទើបសួរនាយទាហានទាំងអស់ថា នរណានឹងអាសាចេញទៅធ្វើការតាមពាក្យទៀវចៀវបាន ។ ឡេងថងឆ្លើយទទួលអាសាថា ខ្ញុំបាទនឹងសុំទាហាន ៣០០ នាក់លើកទៅថ្ងន់បន្ទាយប្អូនឲ្យបាន កាំឡេងឆ្លើយថា ឡេងថងនឹងយកទាហាន ៣០០ នោះច្រើនណាស់ ខ្ញុំបាទនឹងសុំតែទាហាន ១០០ នាក់ លើកទៅធ្វើការយកជ័យជំនះឲ្យបាន ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ស្រាវជ្រាវដោយ ឌុ · គាម (ត)

(រក្សាសិទ្ធិមិនឲ្យចម្លង មិនឲ្យថតរូបឡើយ)

---

កាលនោះទេពសុពុទ្ធិគ្រប់ទិសទីស្ថាន សុបណ្ណគ្រុឌគន្ធពិទ្យាធរកិន្នរ នាគទាំងពួង ក៏នាំគ្នាលីលាហោះចុះមកគាល់ហៅព្រះឥសូរ លុះមកដល់ស្ថានកៃលាសគិរីហើយក៏នាំគ្នាចូលទៅដល់ទីអង្គុយចំនួនដំណាក់ហើយ នន្ទុកៈក៏ដងទឹកយកមកលាងជើងឲ្យតែគ្រប់ ១ អង្គ រីទេវលោកក៏ត្បុកក្បាលអង្គុលលេងតែគ្រប់គ្នាធម្មតាដូចសព្វដងរៀងមក ។ រីនន្ទុកៈក៏មានចិត្តបាបនោះទឹកខឹងទិងទេវលោកទាំងអស់ ហើយក៏ស្រែកថា យុំទេវលោកទាំងអស់នេះ ធ្វើបាបអញតែសព្វៗថ្ងៃមិនមានប្រណីអាណិតមេត្តា ត្បុកក្បាលអញលុះតែទំពែកអស់ ក៏ទឹកខឹងហើយថាថ្ងៃហ្នឹងគង់អ្នកកល់គ្នាដឹងខ្លួន ថាហើយវក៏ចង្អុលខ្លួនទេវលោកមួយរំពេច ក៏ស្លាប់វិនាសអន្តរាយទាំងអស់ហោង ។ កាលនោះព្រះឥន្ទ្រាធិកដឃើញអានន្ទុកៈវសំដែងឫទ្ធិ ចង្អុលពួកទេវលោកស្លាប់អន្តរធានអស់ដូច្នោះហើយ ក៏មានសេចក្តីភ័យតក់ស្លុតរន្ធត់ហើយគិតថាអ្នកណាអេះ ប្រសិទ្ធិចង្អុលដៃឲ្យវានេះមុខគួរឲ្យសង្ស័យណាស់គិតហើយក៏ស្តេចឡើងទៅគាល់ព្រះឥសូរាធិបតី ។ លុះដល់ហើយក៏ក្រាបបង្គំទូលស្នើ ថាអានន្ទុកៈវសំដែងឫទ្ធិវ ។ ចង្អុលទេវស្លាប់វិនាសនោះ តើព្រះអង្គទ្រង់ប្រទានពរប្រសិទ្ធិឲ្យវាឬ ទើបបានជាវពូកែដុត

ឆាប់ម្ល៉េះ ហើយវាធ្វើតាំងនេះដូចជាវាមិនមានសេចក្តីក្រែងខ្លាចបារមីទ្រង់ព្រះករុណាសោះឡើយ ។ ទើបអង្គព្រះចមមកុដត្រៃលោកបានស្តាប់ព្រះឥន្ទទូលដូច្នោះ ហើយមានព្រះឱង្ការថា អាឧទ្ទកៈនេះវានៅបរើអញមកជាយូរឆ្នាំអន្លង់ដល់មួយកោដិឆ្នាំហើយ បានជាអញប្រសិទ្ធិពរឲ្យវាព្រោះដោយតាណិត ឥឡូវនេះវាត្រឡប់មកព្រេចគល់ប្រទុសកាយវិញ បើដូច្នេះ ចូរនារាយណ៍ឯងជាទីពឹងទេវលោកតាំងពួនទៅបំផ្លាញឲ្យស្លាប់អន្តរធានបេញហោង ។ កាលនោះ ព្រះនារាយណ៍បានស្តាប់ព្រះតម្រាស់ប្រើដូច្នោះហើយ ក៏ក្រាបថ្វាយបង្គំលាថយមកក៏និម្មិតកាឡាកាយក្លាយកើតជាស្រីមួយល្អដូចទេពកញ្ញាសួគ៌ ហើយដើរមកកាន់ទីដែលឧទ្ទកៈវាអង្គុយនៅនោះ រីឯឧទ្ទកៈនោះហួសម៉ោងពេលវេលាហើយ ក៏ត្រេចដើរលេងកំសាន្តសប្បាយ លុះលេចឃើញស្រីល្អឆោមឆាយ ក៏បង្កើតដួងចិត្តនោះស្រឡាញ់ណាស់ ហើយក៏និយាយថា ម្នាលនាងស្រីក្រមុំសមរូបឆោមឆវីវណ្ណដ៏ចំរើនអើយ នាងមកពីស្ថានណា មានបើប្រាថ្នារកការអ្វី ហើយអូនស្រីឈ្មោះអីផង ដូចម្តេចបានមកនៅ ៗ ទីនេះ ចូរអូនប្រាប់បងឲ្យបានដឹងផង ។ នាងព្រះនារាយណ៍បានស្តាប់ហើយ ក៏រងតែធ្វើកក្តីឥរិយាឲ្យឧទ្ទកៈ ហើយធ្វើជាក្រឡេកបុងក្លូកទៅ ក៏ស្រដីតបទៅថា អ្នកបងឯងមកសួរគួរសមអីហើយក៏ហ៊ានមកអង្គុយជិតយើង មិនមានកោតក្រែងចិត្តយើងខ្លះ យើងនេះជាខ្ញុំបំរើព្រះឥសូរ មុខក្រសួងភ្នាក់ងារយើង

ខាងឯងប៉ាំកំព្រៀង យើងឈ្មោះសុបណ្ណកល្យាណី ព្រោះមានសេចក្ដីកើតទុក្ខរំខានចិត្ត ទើបបានដើរលេងកំសាន្តកែទុក្ខឲ្យបានស្បើយល្ហើយល្ហែកងទុក អាត្មាយើងហោង ៗ នន្ទកៈបានស្ដាប់ហើយក៏មានចិត្តនោះរឹងរឹតតែស្រឡាញ់ឡើង ទើបនិយាយថាអូនអើយអូន ៗ ឯងនេះមានរូបល្អដូចស្រីនៅស្ថានសួគ៌ ល្អទាំងចរិតកិរិយាវាចាក៏ពិរោះគួរមែនហើយសមជាអ្នកប៉ាំកំព្រៀង មួយទៀតដែលអូនថា មានទុក្ខកង្វល់នោះតើទុក្ខដូចម្ដេច ចូរអូនឯងសំដែងប្រាប់មកបងចុះ បើកស្នាយើងទាំង២ នាក់បានកសាងមកពីមុនមិនអីទេសូមបងជួយដោះទុក្ខអូនកុំព្រួយចិត្តឡើយ រីខ្លួនបងសព្វថ្ងៃនេះក៏កំព្រាគ្មានគូស្រករទីងគេនោះក៏គ្មាន បើអនុជអ្នកមេត្តាស្នេហានិងបង ៗ សែនត្រេកអរណាស់ ៗ កាលនោះនាងព្រះនាកយណ៍ឆ្លើយតបទៅវិញថាអ្នកបងអើយ សំដីអ្នកបងមានប្រសាសន៍មកនោះពីរោះណាស់ អូនមិនថាអ្វីទេ តៀតអូនចំណូលចូលចិត្តតែប៉ាំកំលេង បើអ្នកបងឯងកំចាត់ក្បាច់ត្រូវតាមប្អូនបាននោះ អូនក៏ព្រមយកអ្នកជាប្ដីហោង ៗ រីនន្ទកៈនោះបានស្ដាប់នាងថាដូច្នោះហើយ ហេតុតែមិនដឹងជាព្រះនាកយណ៍គាឡា ក៏មានចិត្តសោមនស្សអរពេកក្រៃ ញញឹមហើយទើបឆ្លើយតបទៅវិញថា ម្នាលនាងដ៏ចំរើន នាងកុំព្រួយចិត្តឡើយខ្លួនបងនេះ ក៏នៅជាខ្ញុំបំរើព្រះអង្គមកយូរឆ្នាំហើយជាមនុស្សចាស់ បងក៏ចេះដែរបន្តិចបន្តួច សូមនាងកំទៅជាមុន សឹមបងកំតាមនាងជាក្រោយ

មិនឲ្យខុសក្បាច់គូនឡើយ ៗ ស្រេចហើយនាងព្រះនារាយណ៍ឃើញ នន្ទុកៈព្រមតាមដូច្នោះហើយក៏ត្រេកអរ នាងក៏រាំតាក់ក្បាច់លេងសប្បាយ បន្តិចទៅត្រូវត្រង់ក្បាច់នាគព័ន្ធកន្ទុយ ហើយនាងរាំចង្អុលម្រាមដៃ ត្រូវត្រង់ភ្លៅនាង ៗ ឯនន្ទុកៈសោតក៏ដោយខ្លៅរាំតាក់ក្បាច់តាមនាងរៀង ៗ ទៅ លុះ ដល់ក្បាច់ចង្អុលភ្លៅចង្អុលខ្លួនឯងមិនបានគិតពីចង្អុលដៃពេជ្រខ្លួនឯង ក៏ ត្រូវបាក់ភ្លៅដួលមួយរំពេចទៅ នាងព្រះនារាយណ៍កាឡាកាយមកជាព្រះ នារាយណ៍វិញ ក៏ស្ទុះទៅជាន់សង្កត់យារព្រះវ័នឡើង នន្ទុកៈនោះ លុះ ឃើញថាព្រះនារាយណ៍ទ្រង់កាន់សង្ខនិងចក្រដំបងពេជ្រ ព្រះវ័នគ្រប់ដៃ ទាំងបួនទឹងសម្លាប់ខ្លួនដូច្នោះហើយ ក៏ស្រែកថាទូលព្រះបង្គំជាខ្ញុំនេះ មានទោសខុសពីអ្វីសូមទ្រង់មេត្តាប្រាប់មក ៗ ទើបអង្គព្រះនារាយណ៍ បានស្ដាប់ហើយ ក៏ឆ្លើយតបទៅវិញថា អាឯងនេះមានទោសជាទំហំធំ ណាស់ អាឯងមិនក្រែងព្រះបារមីអង្គព្រះឥសូរជាអធិបតីសោះឡើយ ហើយអាឯងហ៊ានសម្លាប់ទេវតាសុរាក្សទាំងពួង ទោសអាឯងនេះធ្ងន់ ណាស់ អញក៏មានសេចក្ដីអាណិតមេត្តាដែរ តែថានឹងទុកជីវិតអាឯងពុំ បានឡើយ នន្ទុកៈវាក៏ឆ្លើយតបទៅវិញ ថាដូចម្ដេច ក៏ព្រះអង្គក្លែងធ្វើជា ស្រីមក មិនធ្វើជាព្រះនារាយណ៍វិញ បង្ខាចខ្ញុំចង្អុលនិងម្រាមដៃពេជ្រស្លាប់ មួយទៀតព្រោះខ្លួនទូលព្រះបង្គំជាខ្ញុំនេះមានដៃតែពីរ កាលណាឡើយ នឹងតយុទ្ធបានឈ្នះព្រះអង្គ ថាបើមានដៃបួនដូចព្រះអង្គហើយ ម្ដេចឡើយ

ព្រះអង្គទីងធ្វើបាបបាន ៗ ទើបអង្គព្រះទ្រង់រិទ្ធិ ស្តេចបានស្តាប់ហើយទ្រង់ខ្ញាល់ណាស់ ព្រោះថាអាឯងនេះ ព្រោះចំនាយអាឯងទីងផល់ស្លាប់ បានជាអញទិម្មិតកាឡាធ្វើជាស្រី អញមិនមែនខ្វាចបារមីអាឯងនោះកំទេ ណ្ហើយចុះ អាឯងកើតជាតិនេះ អាឯងកើតមកមានតែដៃពីរផល់ទៅជាតិមុខទៀត ឲ្យអាឯងកើតមកមុខ ១០ ដៃ ២០ ហើយឲ្យគ្រឿងសាស្ត្រាវុធកាន់ព្រះខ័នធ្នូសរសិល្បជ័យឲ្យគ្រប់ដៃចុះ ហើយហោះហើរលើអាកាសបាន រីអង្គអញសុំទៅកើតតែជាមនុស្សដើរដី ដៃតែពីរជើងតែពីរ អញទីងកាប់សម្លាប់ឲ្យអស់ពូជពង្សវង្សត្រកូលអាឯងឲ្យវិនាសទាំង ៧ សន្តាន គ្រាស់ហើយស្តេចក៏កាប់ដាច់ក្បាលអានន្ទុកៈស្លាប់ទៅហោង ៗ លុះសម្លាប់នន្ទុកៈស្រេចហើយ ព្រះអង្គក៏ហោះទៅលើវេហាស៍ក៏ចុះទៅគង់ឯឆ្នេរសមុទ្រសាគរជាកំសាន្ត ៗ

ទីងស្រដីពីនាងវេជ្ជជា ទេវីមហេសីព្រះបាទឡាត្យទៀននោះ ក៏នាងទ្រង់មានគភ៌ គឺអានន្ទុកៈនោះឯមកចាប់កំណើតកើតនៅផ្ទៃនាងវេជ្ជជា គ្រប់ខែសមាសកាលណាហើយ ក៏នាងប្រសូតកជបុត្រា ១ នោះមានមុខនោះ ១០ ដៃ ២០ ព្រះបិតាឲ្យឈ្មោះ ទសកណ្ឋកុមារ ប្អូនបន្ទាប់ក្រោយទៀតឈ្មោះកុម្ភកាណ៌អសុរ អង្គព្រះបិតាមាតាមានសេចក្តីស្នេហាស្រឡាញ់ពេញចិត្តណាស់ហោង ៗ លុះចំរើនវ័យ្យនាជន្មាទីយាយុធំហើយ

អសុរទេសកណ្ឌអាយុបាន ១៤ ឆ្នាំ ហើយក៏មានចិត្តគិតចង់ទៅរៀនសិល្បប្រសាស្ត្រឲ្យបានមានឫទ្ធិអានុភាពខ្លាំងពូកែ គិតហើយក៏មកគាល់សម្តេចព្រះបិតុរង្គមាតុពជ ដល់ហើយក៏ក្រាបថ្វាយបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំលាទៅរករៀនសិល្បវិជ្ជានិងព្រះមហាឥសី ឲ្យខ្លាំងពូកែនឹងគេ ត្បិតខ្លួនសព្វថ្ងៃនេះគ្មានសិល្បវិជ្ជាអ្វីនឹងរក្សារូបកាយ តាមតែទ្រង់ព្រះករុណាវិសេសទ្រង់ព្រះមេត្តាប្រោសកូនហោង ។ កាលនោះព្រះជនកជននីនោះ លុះបានស្តាប់ព្រះរាជបុត្រក្រាបបង្គំលាទៅរករៀនវេទវិជ្ជាដូច្នោះហើយ ក៏មានឱង្ការថា អើបើបាអ្នកទៅរៀនវិជ្ជាវេទមន្តនិងព្រះឥសីសិទ្ធា ចូរកូនខំស្វាហ៍ខំរៀនសូត្រទន្ទេញឲ្យចាំចេះឲ្យបានដូចប្រាថ្នា ទ្រង់ឲ្យពរស្រេចហើយ ទេសកណ្ឌកុមារក្រាបទទួលពរពីបិតាហើយ ក៏លើកដៃថ្វាយបង្គំលាមកប្រាសាទអាត្មាវិញហោង ។

អសុរក៏រៀបប្រដាប់ប្រដាទ្រង់គ្រឿងអលង្ការស្រេចហើយ ក៏ហោះផ្ទោះចាកពីក្រុងលង្កាទ្វីបសំដៅទៅព្រៃហេមពា្ត លុះដល់មណ្ឌលព្រះសិទ្ធាចារ្យឈ្មោះព្រះមហាឥសីគោបុត្រ ហើយក៏ចុះចូលទៅដល់ក្រាបថ្វាយបង្គំនៅមុខអាស្រមណ៍បរមសាលាដូច្នោះហើយ ។ ទើបអង្គព្រះមហាឥសីគោបុត្របានឃើញព្រះរាជឱរសព្រះបាទទាព្យាក្យទៀនហើយ ទើបមានព្រះពុទ្ធដីកាសួរថាម្នាលទេសកណ្ឌអសុរ បាឯងតើមកមានប្រាថ្នាការអ្វីបានជាគ្មានហេតុពលសកលយោធា អាត្មានេះឆ្ងល់សង្ស័យណាស់ ទើបទេសកណ្ឌ

អស្សុក ក្រាបគបព្រះវាចាថា ខ្ញុំព្រះករុណាដែលមកនេះសូមបានមករៀនសិល្បសាស្ត្រវិជ្ជាការក្សោរូបកាយតាមតែសម្តេចព្រះអយ្យកោ មេត្តាប្រោសទៅឲ្យបានរៀនផង ៗ ព្រះមហាឥសីគោបុត្របានស្តាប់ហើយ ក៏មានព្រះទ័យនោះត្រេកអរសោមនស្សយកដៃអង្អែលខ្នងទៅហើយថា ចៅអើយជីតាចេះប៉ុន្មាន តានឹងប្រដៅឲ្យទៅរៀនទាំងអស់ ចូរទៅខំឧហាតសង្វាតរៀនសូត្រទៅ ធ្នូសិល្បជ័យនោះជីតានឹងជប់ឲ្យ ៗ បានដូចក្តីប្រាថ្នាចៅហោង ៗ ទសកណ្ឋអស្សុក ក៏ខុស្សាហ៍គោរពប្រណិប័តន៍បំរើគត់ប្រចាំ ហើយខំខុស្សាហ៍សូត្ររៀនទន្ទេញការនានាជាអចិន្ត្រៃយ ៗ លុះរៀនយូរបន្តិចទៅ ក៏ចេះចាំចប់ស្រេចហើយ ខំហាត់បាញ់ធ្នូសិល្បក៏បានត្រង់ដូចសេចក្តីប្រាថ្នាហោង ៗ លុះមានសម័យថ្ងៃមួយ ក្រុងទសកណ្ឋអស្សុក ក៏ទៅក្រាបបង្គំលាជីតាទៅលេងព្រៃព្រឹក្សា ស្រេចហើយអស្សុក ត្រេចយាត្រាដើរលេងសប្បាយ លុះឆ្ងាយបន្តិចទៅ ៗ ដល់ព្រៃសួនឧទ្យានព្រះបាទ អរជុនការ ទសកណ្ឋ អស្សុក ក៏ដើរលេងបេះផ្កានូវផ្លែឈើទាំងពួង ហើយកាច់មែកឈើលេងតាមកំសាន្តសប្បាយចិត្តឥតកោតក្រែងឡើយ ៗ

នឹងសំដែងពីព្រះបាទ អរជុនការ គង់ក្នុងពិមានរ័ត្នវេហានៅលើកំពូលភ្នំចក្រវាឡ មានឫទ្ធិតបៈតេជៈខ្លាំងពូកែ ស្ថានសួគ៌ទាំង ១៦ ជាន់ សុទ្ធសឹងតែបាក់បបខ្ចបខ្លាចមិនអាចនឹងហ៊ានតដៃឡើយ ៗ ព្រះបាទ អរជុន-

ការនោះ មានកំណត់តែ ៧ ថ្ងៃទៅប្រពាធឧទ្យានកំសាន្តព្រះទ័យម្តង ព្រះបាទអរជុនការ លុះគំរប់ថ្ងៃហើយ ក៏កាន់ដំបង់ហោះទៅ ៗ លុះដល់សួនឧទ្យាន ហើយឃើញព្រៃព្រឹក្សាតូចធំបាក់មែកបែកដើមដេរដាសពាសពេញព្រះធរណី អសុរនឹកឆ្ងល់សង្ស័យក្នុងចិត្តគិតថានរណាអេះ មកធ្វើដូច្នេះ មិនក្រែងខ្លាចអញសោះឡើយ លុះលបៗដើរមើលទៅក៏ឃើញទសកណ្ឋមុខ ១០ ដៃ ២០ ក៏ខឹកខឹងក្រេវក្រោធហើយស្រែកថា ហើយអសុរឯងនេះមកពីណា ពូជពង្សវង្សត្រកូលឯងហើយនៅនគរណា នាមឯងគេឈ្មោះអ្វី ទើបឯងហ៊ានព្រហើនហានក្លាមកកាប់ដើមព្រឹក្សានៃសួនឧទ្យានអញ មិនមានកោតញញើតក្រែងចិត្តអញជាម្ចាស់សោះឡើយ កុំថាឡើយឯងមុខ ១០ ដៃ ២០ អញនឹងបំផ្លាញអាឯងឲ្យក្ស័យជីវក្នុងគ្រានេះ ពោះទេវាសុរឫទ្ធិក៏គង់ក្រែងខ្លាចឫទ្ធានុភាពអញទាំងអស់ហោង ៗ គ្រានោះទសកណ្ឋអសុរ បានស្តាប់អរជុនការថាដូច្នោះហើយក៏ទ្រង់ក្រេវក្រោធពីរពេកក្រៃ ឆ្លើយតបទៅវិញថា ណែអសុរឯងតើនាមាឈ្មោះអ្វី ទើបឯងអួតអាងកាងក្រទារឫកខ្លាំងម្ល៉េះ រីខ្លួនអញនេះឈ្មោះហៅទសកណ្ឋអសុរ ពង្សាព្រះបាទឡាត្យទៀន វង្សព្រហ្មសោយរាជ្យនៅនគរក្រុងលង្កាទ្វីប អង្គព្រះមហាឥសីគោបុត្រជាគ្រូបាអាចារ្យអញបានបង្ហាញបង្ហាត់បង្រៀនវេទមន្តវិជ្ជា អញដើរមករកលេងព្រៃពនាល័យទីហេមវេសន៍ អញនេះមិនបានដឹងជាសួនឧទ្យានរបស់អ្នកណានោះក៏ទេ

លុះស្រាប់តែឃើញព្រៃផ្កាជាទីសប្បាយកាយ ក៏គិតថាតែជាព្រៃព្រឹក្សា ពនាល័យទីហេមពាន្ត ណាវើយកុំអាលអួតអាងឫទ្ធានុភាពខ្លាំងពូកែ រីឯអង្គអញសោតក៏មិនមានគោតខ្លាចក្រែងឯងនោះក៏ទេ ខ្លួនឯងនេះប្រៀបដូចជាហ្វូងម្រឹគផងទាំងពួង កាលណាឡើយទ្រាំទ្រទឹងដៃអញបានគង់តែទឹងស្លាប់ហោង ។ កាលនោះព្រះបាទអរជុនការបានស្តាប់ពាក្យអសុកហើយទ្រង់ក្រេវក្រញេវក្រញ៉ឹងខឹងខ្លាំងណាស់ ដូចភ្លើងប្រល័យកល្បហើយទ្រង់ចាប់យកកូនធ្នូសិល្បសរជ័យបានស្រេច ស្តេចក៏ប្រាប់ទៅវិញថាអញនេះឈ្មោះហៅថាព្រះបាទអរជុនការថាតែប៉ុណ្ណោះហើយ អសុក ក៏ស្ទុះទៅសំពងទសកណ្ឋអសុក ៗ ក៏ប៉ប់រងគេចកែបែរបៀងតែវៀងខ្លួន អ្នកទាំងពីរសុទ្ធសឹងតែពូកែ ក្នុងចិត្តគិតប៉ង់ប្រាថ្នាយកជីវិត រួចហើយព្រះបាទអរជុនការ ក៏ចាប់យកធ្នូសរសិល្បជ័យថ្វីងទៅកកើតជានាគពាជដេញរួតរឹតខ្លួនទសកណ្ឋជុំខ្លួន ហើយនាំហោះឡើងទៅកណ្តាលវេហាស៍ប្រទក្សិណទៅមក ៗ កាលនោះ ព្រះមហាឥសីគោបុត្រ វេលាថ្ងៃនោះ ក៏តាំងស្មាធិចំរើនឈានទៅក្នុងកុដិ បានឮស័ព្ទសំឡេងខ្ទរខ្ទាកក្រេកទឹកដីដូច្នោះហើយក៏នឹកពិភាល់នឹងទសកណ្ឋ ជាសិស្សលោទៅលេងព្រៃ ប្រាកដជាមានហេតុ ដូច្នេះគួរអាត្មាត្រូវទៅកាន់អសុកតាមមើលឲ្យដឹងហេតុការណ៍គិតហើយក៏ចេញចាកពីអាស្រមណ៍ ហើយហោះទៅដោយឫទ្ធិអានុភាពលុះហោះទៅបានដល់ឃើញព្រះបាទអរជុនការទេវេទ ថ្វីងសរជានាគពាជ

តរឹតចាប់ចងទសកណ្ឋ អសុរ ទក្សិណទៅកណ្ដាលអាកាសដូច្នោះហើយ ក៏ទឹកភ័យគិតក្រែងទសកណ្ឋស្លាប់ ទើបស្រែកថា ម្នាលអ្នកអរជុនការ រទក ហេតុដូចម្ដេចបានជាធ្វើដូច្នេះ ៗ ព្រះបាទអរជុនការបានឮសំដី ព្រះមហាឥសីគោបុត្រហើយ ក៏ឆ្លើយតបទៅមហាឥសីវិញថា អានេះជា មនុស្សព្រហើនជួរអាក្រក់ណាស់ វាមកកាច់មែកហែកដើមព្រឹក្សសួនឧទ្យាន ជារបស់ខ្ញុំ ហើយមិនប៉ុន្ដែម៉្លោះទៀតក៏អួតអាងកាងក្រេត បានជាខ្ញុំព្រះ ករុណាចាប់ចងផ្ដាលផ្ដាញ់វាឲ្យវាដឹងឫទ្ធិអំណាចខ្ញុំ ទៅមុខក្រោយ ឲ្យវារាង ចាល ៗ ព្រះមហាឥសីបានស្ដាប់ហើយក៏ឆ្លើយតបទៅនឹងព្រះបាទអរ-ជុនការថា ណ្ហើយចុះសិស្សអាត្មានេះវាធ្វើខុសទោសដល់ជីវិតមែនពិត ហើយ តែវាជាកូនសិស្សអាត្មាភាពតាំងតែពីនៅក្មេងតូច ៗ រៀនមក ឲ្យ អាត្មាភាពបិណ្ឌបាទសូមជីវិតបានម្ដង ៗ ព្រះបាទអរជុនការ បាន ស្ដាប់ពុទ្ធដីកាមហាឥសីហើយ ក៏មានចិត្តនោះនឹកអាណិតមេត្តាព្រះមហាឥសី គោបុត្រនិយាយលួងលោមសុំសិស្សដូច្នោះហើយ ទើបទូលតបទៅវិញថា ដែលព្រះអង្គសុំទោស ខ្ញុំព្រះករុណាក៏ប្រគេន ថាហើយក៏ស្រាយក្រុង ទសកណ្ឋ ប្រគេនព្រះមហាឥសីស្រេចហើយក៏បង្គំលាឥសីហោះទៅកាន់ ស្ថានវិមានវិញហោង ៗ

នេះនឹងសំដែងពីព្រះឥសូរ លោកទ្រង់រំពឹងក្នុងញាណ ឃើញយល់ ឃើញអានន្ទកៈនោះ ឥឡូវនេះវាទៅចាប់កំណើតកើតជាទសកគ្រីអសុរ

មុខ ១០ ដៃ ២០ ជាព្រះរាជបុត្រព្រះបាទទឡ្ហាត្យទៀន ទៅឯនគរក្រុងលង្កាទ្វីប អានេះរាកាចម្នោមានៈអាក្រក់ក្រៃពេក នឹងបានសេចក្ដីក្ដៅក្រហាយគ្រប់ ៗ ស្ថាន មិនដឹងជានឹងបានអ្នកណាបង្ក្រាបបាន មានតែអង្គនារាយណ៍ទើបទៅបង្ក្រាបវាបាន ដូច្នេះត្រូវតែអញគិត ទ្រង់គិតដូច្នោះហើយ ទើបឲ្យព្រះវេស្សវ័ណ ទៅបង្កើតរូបវង្សត្រកូលជាមួយនឹងវា ទើបនឹងបានដឹងហេតុការណ៍ក្នុងពូជពង្សវង្សវាអស់ ៗ ហើយក៏ឲ្យរៀនគម្ពីរហោរាសាស្ត្រឲ្យចប់អស់ រង់ចាំព្រះនារាយណ៍បែងភាគទៅកាលណាហើយ អ្នកនឹងបានដឹងហេតុការណ៍សារពើគ្រប់ដំពូកហោង ៗ ហើយទ្រង់ប្រទានវេនតាពេជ្រ ១ ដ៏វិសេសប្រសើរឲ្យទៅបង្កើតទៅជាដួងភ្នែកតាំងសងខាង នឹងបានធ្លុះមើលក្នុងត្រ័យលោកទាំង ៣ ដូចភ្នែកទិព្វហោង ៗ គ្រានោះ ព្រះវេស្សវ័ណទេវបុត្រក៏ទទួលព្រះពរនិងវេនតាពេជ្រកែវហើយ ក៏ច្យុតចាកចុះមកកើតក្នុងគភ៌នាងរដ្ឋជាគ្រប់ទសមាសា ក៏ប្រសូតមកជាប្រុស ព្រះបិតាសន្មតឈ្មោះហៅពិភេកអសុរ លុះចំរើនវ័យធំឡើង មានប្រាជ្ញាជ្រៀវជ្រាតណាស់ តែបុរិសានុភាពនោះទន់ទាបជាងគេមិនខ្លាំងពូកែដូចទសកណ្ឋនិងកុម្ភកណ៌ក៏ទេ រីនាងសមណក្ខាជាប្អូនពៅបំផុត ព្រះបិតាក៏មានចិត្តនោះស្នេហាប្រតិព័ទ្ធពេកហោង ៗ

នឹងនិយាយពីព្រះបាទគោត្តមដែលសោយរាជសម្បត្តិនៅនគរសោកេតបុរីរាជធានី លុះសោយរាជ្យយូរទៅក៏គ្មានព្រះរាជបុត្រាបុត្រីនឹងគេ

ឡើយ ហើយទ្រង់គិតនឿយណាយនឹងរាជការសម្បត្តិជាតិស្ថាន ក៏ទ្រង់លះបង់រាជសម្បត្តិទៅបួសជាតាបសឥសី ចំរើនឈានជាយូរអង្វែងបាន ២០០០ ឆ្នាំ លុះកាលតែពុកមាត់ពុកចង្កា ដុះវែងដល់ទៅដើមទ្រូងច្រើនដូចស្មៅក្រពញជ្រូក មហាឥសីប្រឹងតែខំភាវនាសង្រួមចិត្តប្រព្រឹត្តតាមភេទតាបស គ្រានោះមានសត្វចាបព្រៃមួយគូញីឈ្មោល លុះឃើញពុកមាត់តាបសឥសីដូច្នោះហើយ ក៏នាំគ្នាមកនៅធ្វើជាសំបុកតែរាល់ឆ្នាំ លុះដល់នាងចាបនោះមានពងក្នុងពុកមាត់មហាឥសី ពេលនោះពីរហោង ៗ ជួនជាសម័យថ្ងៃមួយនោះជាហេតុនឹងបណ្ដាលឲ្យមានហេតុនោះ សត្វចាបឈ្មោលនោះក៏និយាយនឹងនាងចាបជាប្រពន្ធថា ម្នាលនាង ចូរនាងនៅរក្សាកូននឹងសំបុកនេះចុះ បងនឹងលានាងទៅ ៗ រកចំណីអាហារគោចរ ថាតែម្ល៉ោះស្រេចហើយ ចាបឈ្មោលនោះក៏ហើរចាកសំបុកទៅ លុះដល់ព្រៃហេមពាន្តហើយ ក៏ក្រឡេកមើលទៅឃើញផ្កាឈូកហើយក៏ចុះទៅជញ្ជក់ចឹកស៊ីសប្បាយ តាំងតែពីព្រឹកលុះដល់ថ្ងៃជ្រលងព្រលប់យប់ រីផ្កានោះ កាលពីព្រឹករីកឡើង លុះដល់ព្រលប់កាលណាហើយផ្កានោះក៏ក្រពោបក្ដោបជិតវិញ ទាល់តែព្រឹកឡើងវិញនោះ ទើបផ្កាឈូករីកវិញហោង ហើយក៏ហើរទៅកាន់សំបុកអាត្មាវិញហោង ៗ គ្រានោះនាងចាបជាប្រពន្ធឃើញប្ដីមកកាលណាហើយ ក៏បង្កើតក្ដៅក្រហាយក្នុងចិត្តខឹងខ្លាំងណាស់ ទើបស្ដីទៅថាអ្នកទៅឯណាថ្មើរណេះទើប

បានមកដល់ស្ថានលំនៅ រីតាបសឈ្មោលនោះទើបស្តីប្រាប់នាងតាបញីជាប្រពន្ធថា ខ្លួនបងនេះទៅរកចំណីឯព្រៃហេមពាន្ត ក៏បានឃើញផ្លូឈូកផ្កាឈូក បងក៏ចុះទៅផញ្ញប់ចិកស៊ី ហើយទឹងចិកពាំនាំយកមកផ្ញើជូនឯងអាស្រ័យ លុះស្រាប់តែថ្ងៃលិចល្ងាចយប់ទៅ ផ្កានោះក៏ក្រសោបក្តោបខ្លួនបងនៅក្នុងផ្កានោះ ដល់ព្រឹក បានជាបងបាត់ លុះដល់ថ្ងៃរះឡើងកាលណាទើបផ្កានោះរីកវិញ បងក៏បានមក តាបសឈ្មោលនិយាយប្រាប់ពីដើមដល់ចុងឲ្យប្រពន្ធស្តាប់ នាងតាបជាប្រពន្ធនោះ កាលណាបានស្តាប់ប្តីស្រដីប្រាប់ដូច្នោះហើយ ក៏ខឹងក្តាញ់នឹងប្តីណាស់ក៏ប្រឆាំងបែរមុខចេញក៏និយាយតបទៅនឹងប្តីថាមែនហើយ ខ្ញុំក៏ជឿអស់ពីចិត្ត ព្រោះតែអ្នកមានសាហាយស្មន់អន្ទកទើបបាននៅដេកនឹងគ្នា មិនដែលមានផ្កាណាទឹងក្រសោបក្តោបរូបអ្នកនៅបាន ខ្ញុំមិនជឿស្តាប់ពាក្យអ្នកឯងនិយាយទេ រីតាបសឈ្មោលនោះ លុះបានឮពាក្យសំដីនាងតាបជាប្រពន្ធថាកៀសកៀងជៀងពាក្យក្តួចកាន់ប្រច័ណ្ឌខឹងដូច្នោះហើយ តាបសឈ្មោលក៏ឆ្លើយតបទៅវិញថា ៗ បើនាងមិនជឿ បងហ៊ានសច្ចាស្បថឲ្យនាង ខ្លួនបងនេះត្រង់ពិតប្រាកដ ៗ នាងតាបញីនោះឆ្លើយតបសព្ទតាមវាចាស្វាមីថា អ្នកនឹងស្បថយ៉ាងដូចម្តេច ទើបតាបសឈ្មោលថាបងហ៊ានស្បថឲ្យបាបដូចមហាឥសីនេះ ៗ គ្រានោះព្រះមហាឥសីនោះ លុះបានស្តាប់សព្ទសត្វតាបវានិយាយស្បថឲ្យប្រពន្ធវាដូច្នោះហើយ ក៏ខឹងឆ្ងល់ពិភាល់នឹងសត្វតាប

ណាស់ ទើបមានពុទ្ធដីកាសួរថា តែណាបាបឈ្មោលអើយ ឯងនាំគ្នាមកធ្វើសំបុកនឹងពុកមាត់អញផង ម្តេចឡើយឯងត្រឡប់មកថាខ្លួនអញជាមានបាបវិញ អញសព្វថ្ងៃនេះ ព្រោះខ្លាចបាបខ្លាស់បាប ទើបបានជាលះរាជសម្បត្តិមកសាងព្រឹទ្ធិ បួសជាតាបសឥសីចំរើនមេត្តាការនាជាអចិន្ត្រៃយ៍ ឥឡូវនេះឯងថាអញមានបាបពីដំណើរអ្វី ៗ ទើបតាបទូលតបព្រះពុទ្ធដីកាថាព្រះអង្គនេះ បានជាខ្ញុំថាមានបាប ព្រះអង្គជាមហាក្សត្រសោយរាជសម្បត្តិ ហើយមិនមានបុត្រាបុត្រី ក៏លះបង់រាជសម្បត្តិមកបួសជាតាបសនៅព្រៃ ឲ្យសូន្យពង្សវង្សក្សត្រខត្តិយាដែលនឹងគ្រងការាជធានីទៅបានជាមានបាបធំណាស់ ទើបបានជាខ្ញុំព្រះករុណាស្បថឲ្យបាបដូចព្រះអង្គសព្វថ្ងៃនេះ មិនបានសំរេចឈាន សូមទ្រង់រំពឹងគិតទៅចុះ ៗ គ្រានោះព្រះតាបសឥសីបានស្តាប់ពាក្យតាបប្រាប់ថាដូច្នោះហើយ ព្រះអង្គទ្រង់រំពឹងយល់ឃើញដូចជាពាក្យពពោល ក៏ទ្រង់មានមនោចិត្តត្រេកអរសោមនស្សណាស់ ហើយព្រះអង្គក៏ទ្រង់តាំងពិធីកម្មកងអគ្គីតាមគេទព្រះមុនិពីបូរាណរៀងមក ដល់បង្កើតបានជាស្រីមួយល្អណាស់ ទើបសន្មត់ឲ្យឈ្មោះនាងកាលអច្ចនាស្រេចហើយ ឥសីគោត្តមនោះក៏តាកសិក្ខាបទមកនៅរួមព្រះវេណីនឹងនាង កាលអច្ចនា យូរថៃថ្ងៃមកលុះតែនាងមានគភ៌គ្រប់ទសមាសហើយ លុះបានប្រសូតពារពេលាក៏សំរាលបុត្រ ១ ឲ្យឈ្មោះហៅនាងស្វាហាយ រូបឆោមលោមពណ៌ក៏ល្អដូច

ទេពកញ្ញា ព្រះបិតាមាតាក៏មានចិត្តនោះស្រឡាញ់ណាស់ហោង ៗ កាលនោះព្រះគោត្តម វេលាព្រឹកឡើងកាលណាហើយ ក៏តែងតែទៅបេះផ្លែឈើមើមឈើមកចិញ្ចឹមជីវិត តែទៅព្រៃកាលណាហើយប្តីផ្តាំនឹងប្រពន្ធថាចូរនាងរក្សាកូនឲ្យល្អ អញទៅនេះមិនយូរទេ ផ្តាំស្រេចក៏លើកដង្រែកសង្រែកដាក់លើស្មាហើយរែកដើរចូលទៅព្រៃ រកបេះផ្លែឈើមើមឈើក្នុងព្រៃពនាល័យទីហេមវន្ត ៗ (ស្មេះ) នឹងនិយាយពីសម្តេចឥន្ទ្រាធិរាជទ្រង់បើកទិព្វចក្ខុញាណដឹងដោយព្រះបារមី ថាអានទូកៈនោះកាទៅបង្កើតជាកូនព្រះបាទឡាត្សទៀនឈ្មោះទសកណ្ឋ អសុរមានចិត្តមិច្ឆាទិដ្ឋិកាចឃោរឃៅ នឹងបៀតបៀនត្រៃលោកាពុំលែងឡើយ ទ្រង់គិតយល់ហើយថាដល់ព្រះនារាយណ៍កាឡាបែងភាគចុះមកចាប់បដិសន្ធិ នឹងមហេសីព្រះបាទទសរថ ហើយស្តេចនឹងបង្រាបប្រាប់អសុរពាលពាលា គួរអញនឹងបែងបូជាកំលាំងទៅបង្កើតកូនមួយ នឹងបានជួយកំលាំងច្បាំងនឹងអសុរកពងង ៗ ឥឡូវនេះប្តីនាងកាលអច្ចនា ក៏ទៅព្រៃរកបេះផ្លែឈើមើមឈើមិនទាន់មក ដូច្នេះគួរអញទៅសេពសម្ពន្ធនឹងនាង កាលអច្ចនា បង្កើតកូនមួយទុកជួយព្រះនារាយណ៍ហោង ៗ ទ្រង់គិតស្រេចហើយក៏ហោះចុះចាកទេវស្ថានអាគ្នា មកកាន់អាស្រមណ៍បរមេសាលា នាងកាលអច្ចនា ហើយព្រះអង្គទ្រង់បដិសណ្ឋារៈទៅវិញទៅមក នាងក៏ព្រមដោយដូចសេចក្តីប្រាថ្នា ហើយក៏សេពសមស្នាគមន៍រួមនោសេទនឹងគ្នា ស្រេចហើយព្រះកោសី

កំលា នាងត្រឡប់ទៅកាន់ស្ថានពិមានវិញហោង ៗ រីព្រះគោត្តមនោះ ក៏ត្រឡប់វិលមកពីព្រៃវិញហោង ៗ លុះយូរបន្តិចទៅនាងក៏មានគភ៌គ្រប់ទសមាស ក៏ប្រសូតកជបុត្រ ១ សម្បុរពណ៌ …នោះប្រាយគន់ពណ៌ដូចមកិត រីរូបកុមារនោះល្អដូចរូបព្រះឥន្ទជាបិតា រីឯនាងកាលអច្ចនា ទីងព្រះគោត្តមជាបិតា ក៏មានចិត្តនោះស្នេហាស្រឡាញ់បុត្រនោះពេកក្រៃ រីឯព្រះគោត្តមតែព្រឹកឡើងកាលណាហើយ ក៏តែងតែទៅរកបេះផ្លែឈើមើមឈើជាប្រក្រតីរៀង ៗ ទៅ ៗ លុះដូនថ្ងៃ ១ នោះ នាងកាលអច្ចនា អង្គុយនៅក្នុងសាលាអាស្រមណ៍ក្រឡេកមើលទៅឃើញព្រះអាទិត្យស្ថិតនៅកណ្តាលអាកាស មានរស្មីភ្លឺត្រចះធុះធ្លាស់សព្វទិស នាងក៏ទឹកក្នុងចិត្តស្រឡាញ់ព្រះអាទិត្យ ហើយក៏លើកដៃថ្វាយបង្គំទៅព្រះអាទិត្យ ៗ កាលនោះព្រះអាទិត្យទ្រង់បើកព្រះនេត្រទិព្វមើលមក ឃើញនាងកាលអច្ចនាហើយ ក៏ចាប់ចិត្តប្រតិពទ្ធចង់រួមរស់នឹងបង្កើតកូន ១ ទុក ទីងបានជួយព្រះនាកយណ៍ថែងភាគ ចុះមកបង្ក្រាបអសុរ ទ្រង់គិតរំពឹងដូច្នោះហើយ ទើបមានទេវបញ្ជាទៅទីងទេពសារថីថា ចូរអ្នកនៅបរកដរថឡគ្រប់ចក្រវាឡ អញនឹងចុះទៅកាន់នាងកាលអច្ចនា ស្រេចហើយទេវបុត្រព្រះអាទិត្យក៏ហោះចុះមកដល់អាស្រមណ៍កុដិកាលណាហើយ ៗ

ចប់ភាគ ២

សូមរង់ចាំអានភាគ ៣ តទៅទៀត

# រឿងព្រេងបិន (ត)

## ១៦ សេចក្ដីយុត្តិធម៌និងប្រាក់

### 16 — La justice et l'Argent (Conte mongol)

លោក ព៉ាយ - ប៊ុគា ប្រែរៀបរៀង

តាំងពីព្រេងនាយ នៅវាលខ្ពស់នៃប្រទេសម៉ុងហ្គោលី មានអ្នកចម្រៀងម្នាក់ក្មេងខ្វាក់តាំងពីរ ៗ រាល់ពេលវេលា អ្នកចម្រៀងនោះស្ពាយតាប៉ីគ្រេចចុះឡើងតាមវាលនោះ ៗ គាត់ញុំាងចិត្តប្រជាជននៅទីនោះដោយចម្រៀង ការនិយាយរឿងផ្សេង ៗ ឲ្យបាត់អផ្សុក ឲ្យរីករាយសប្បាយ ៗ លុះយូរឆ្នាំទៅ អ្នកចម្រៀងនោះប្រមូលប្រាក់សន្សំបានល្មមសម្រាប់ការចាស់ជរា ទៅអនាគត ៗ ដោយគាត់គ្មានផ្ទះសម្បែង ដូច្នេះតើនឹងយកប្រាក់នោះ ទៅលាក់ឯណា បើទីនោះសុទ្ធតែមានចោរដើរទៅមកជានិរន្តរ៍ ៗ

ដល់ត្រិះរិះទៅគាត់ក៏នឹកឃើញនូវមធ្យោបាយមួយបែប ដើម្បីរក្សាប្រាក់នោះ គឺយកប្រាក់ទៅដាក់ក្នុងថង់ស្បែកចងនឹងចង្កេះឲ្យជាប់ ៗ តែមិនយូរប៉ុន្មាន ក៏មានគ្រោះថ្នាក់មកដល់គាត់ដូចតទៅ :

មានកាលមួយថ្ងៃ ព្រះសុរិយាមានរស្មីត្រចះត្រចង់លើមេឃ ព្រះពាយបក់រំភើយ ៗ លើវាលស្មៅ ពពកក៏គ្មានលើនភាល័យ គ្មានអ្វីជាឧបសគ្គមកពាំងពន្យូចការសុខដុមរមនាសោះឡើយ ៗ

អ្នកចម្រៀង បានច្រៀងសប្បាយក្សេមក្សាន្ត អង្គុយនៅមុខពួក

ចាស់ក្មេងដែលចាំស្ដាប់គ្រប់ៗគ្នា ក៏ស្រាប់តែមានមនុស្សដើរពីចម្ងាយម្នាក់ មានគ្រឿងស្លៀកពាក់ហឹកហាក់គឺ: អាវកាក់សក្លាតខៀវផ្ទៃមេឃ ខោព្រែលើបរលង់ មួកព្រៃខ្មៅហើយស្បែកជើងខ្មៅក្បូរលោងស្រិល ។ មនុស្សនោះបានដើរមកចំអ្នកចម្រៀង ។ ក្រោយដែលបានបោលកន្ទុយភ្នែកទៅលើមនុស្សនោះក៏រត់ជ្រែកពួកជនានុជន ទៅអង្គុយចំពីមុខមនុស្សខ្វាក់នោះ ភ្នែកក្រឡេករៃពាមើលត្រង់ដើមទ្រូង ។

ដល់មនុស្សខ្វាក់ច្រៀងចប់ហើយ ពួកជនានុជនក៏នាំគ្នាវិលទៅគេហដ្ឋានសព្វៗខ្លួន ។ មនុស្សនោះក៏លោតទៅលើខ្លួនមនុស្សខ្វាក់នោះ ប្រវាយដណ្ដើមយកថង់ស្បែកនោះ ។ តែមនុស្សខ្វាក់បានចាប់ដៃអាវចោរជាប់ ហើយស្រែកថា:

“ ចោរ ! ចោរ ! មិនដែលឃើញអ្នកណាហ៊ានបែបនេះ ។ វាហ៊ានលួចទាំងមុខគេឥតកោតញញើតសោះឡើយ ” ។

មនុស្សជិតខាង លុះឮសម្រែកមនុស្សខ្វាក់នោះ ក៏រត់ប្រញាប់ប្រញាល់មកកាន់ទីនោះ ។ មនុស្សទាំងឡាយនោះបានឃើញមនុស្សខ្វាក់កាន់ដៃអាវចោរជាប់ ក៏មានចិត្តទោមនស្សឥតឧបមា ហើយស្ដីបន្ទោសចោរនោះថា:

“ អាពូជជ្រឹង ! ម្ដេចក៏អាឯងធ្វើបាបមនុស្សខ្វាក់ដូច្នេះ ! ” ។

ក្នុងពេលនោះ មនុស្សទាំងឡាយចាប់ចោរនោះដើម្បីនឹងនាំទៅសា-

លាស្រុក ។ តែ ចោរនោះបានលើកបង្ហាញជនានុជននូវថង់ស្បែក នោះ ហើយពោលថា :

" តើអ្នកឯងជឿបានទេ ថាមនុស្សម្នាក់ក្រីក្របែបនេះ មានប្រាក់ច្រើនម៉្លេះ ! នេះគឺជាមធ្យោបាយចង់ធ្វើបាបខ្ញុំ ! " ។

ពួកប្រជាជនទាំងឡាយមានចិត្តខឹងខ្លាំង មហិមា បើទុកជាយ៉ាងណាក៏ត្រូវតែនាំចោរនោះ ទៅជូនលោកសុកា ។

លោកសុកាបានពិនិត្យសាកសួរ រឿងនេះសព្វគ្រប់ ក៏ឲ្យមនុស្សម្នាក់មកអង្គុយជិតលោក ហើយបង្គាប់ទៅចោរថា :

" ឯងលុតជង្គង់មក ! ធ្វើយសារភាពឲ្យធាច់ ៗ លួចប្រាក់អ្នកចម្រៀងនេះ ! ឥតខ្មាស់អៀនគឺជាទោសធ្ងន់បំផុត ហើយនាំឲ្យអាម៉ាស់មុខដល់ពួកព្រះពជវង្សានុវង្សផង អ្នកឯងយកច្បាប់ឈើមិនដើងបានជាឯងធ្វើដូច្នេះ ! " ។

តែ បើទុកជាលោកសុកាមានប្រសាសន៍យ៉ាងណា ចោរនោះស្ងៀតនៅស្ងៀមចាំស្ដាប់ រួច ក៏ពោលទៅកាន់លោកសុកាថា :

" គឺជាកិត្តិយសនៃលោក ខ្ញុំជាពូជព្រះពជវង្សានុវង្ស ម្ដេចក៏លោកបរិនចោទថាខ្ញុំប្រព្រឹត្តបទឧក្រិដ្ឋបែបនេះកើត ! ។ ព្រះពជអយ្យកោនៃខ្ញុំមានព្រះកិត្តិសព្ទល្បីល្បាញពន់ពេក ! ហើយខ្ញុំ ៗ មានប្រាក់កាសល្មមគួរសម ម្ដេចលោកចោទថាខ្ញុំលួចប្រាក់មនុស្សម្នាក់បែបនេះ

ដូចជាមិនសមសោះ ? " ។

រាំងដែលបុរសជាចោរ បាននោលដូចខាងលើនេះ បានញាំង ឲ្យលោកសុភាកាន់តែទឹងយ៉ាងខ្លាំង ។

លោកសុភាឆ្លើយតបដោយចិត្តក្រេវក្រោធឥតឧបមា ទៅនឹងចោរថា:

" ប្រហែលជាជីដូនជីតាឯងមានពូជមិនល្អ បានជាបង្កើតកូនចៅ ជាពូជចោរគមក ។ ឯងនឹងមើលពកច្បាស់ចង់យកកិត្តិយសជីដូនជីតាឯង មកបិទបាំងកំហុសឯង ។ ឯងមានកស្តុតាងទេថាជីដូនជីតាឯងមាន សម្បត្តិ ! " ។

បុរសជាចោរពោលថា :

" សូមអភ័យទោស លោកសុភា នាមនៃជីតាខ្ញុំ អ្នកណា ក៏ស្គាល់ដឹងច្បាស់ ! ។ តាំងពីព្រះចៅអធិរាជ ព្រះអគ្គមហេសី មន្ត្រីធំៗ រហូតដល់ពួកអកិជនទាំងឡាយ គ្មានអ្នកណាមួយថាមិនស្គាល់ជីតាខ្ញុំ ! ។

លោកសុភាមានចិត្តងឿងឆ្ងល់ពន់ពេក ។

បុរសជាចោរពោលបន្ថែមថា : ខ្ញុំសូមបញ្ជាក់លោកសុភា សូម្បីតែលោកក៏គង់ដែលស្គាល់ជីតាខ្ញុំដែរ " ។

លោកសុភាក៏ឆ្លើយតបទៅនឹងបុរសជាចោរថា :

" បើដូច្នោះ អ្នកណាជាជីតាឯង " ។

បុរសចោរតបវិញថា :គឺលោក " ជាចិនតៃ " ដែលមានខ្នងកោង

មុខអុតនោះឯង ជាដីតាំ ” ។

លោកសុភា ក្រោយដែលបានស្ដាប់នូវសព្ទកថានៃបុរសជាចោរ ក៏គិតជញ្ជឹងមួយស្របក់ អន្ទើលចង្កាហើយពោលថា :

« រឿងក្ដីនេះលំបាកជំនុំជំរះណាស់ យើងនឹងសម្រេចនៅពេលស្អែក » ។

លោកសុភាឃុំខាំងបុរសម្នាក់ក្អែក និងចោរនៅបន្ទប់មួយ ៗ ដោយឡែកពីគ្នា ។ ដល់ពេលអធ្រាត្រស្ងាត់ ចោរយកស្បែកជើងប្រាក់មួយទម្ងន់ ៥០ ដំឡឹងទៅជូនលោកសុភា ។

ដល់ពេលស្អែកនឹងជំនុំជំរះក្ដីនេះ លោកសុភាក៏ប្រែនូវអាកប្បកិរិយា ហើយស្រែកទៅកាន់បុរសម្នាក់ថា :

« ឱបុរសម្នាក់ ! ម្ដេចក៏ឯងមិនរស់នៅជាអ្នកសុចរិត ស្មោះត្រង់ទៅ ! ម្ដេចក៏ចាំលោភទ្រព្យសម្បត្តិគេ ហើយនាំខានដល់គ្រួសារពួកអភិជនដោយចោទបង្កាច់គេតាំងស្រួនិងជូរបះ ? តើឯងស្គាល់ទោសទក្រិដ្ឋខ្លួនឯងឬទេ ? » ។

អ្នកចម្រៀង ក្រោយដែលបានទទួលនូវពាក្យអសប្បុរសពីលោកសុភា ក៏យល់ជាក់ច្បាស់ស្ថានការណ៍ក្នុងពេលនោះ ។ បុរសម្នាក់មិននិយាយស្ដីអ្វីសោះឡើយ យកម្រាមដៃកកាយព្រះធរណីហើយផ្ទៀងត្រចៀកស្ដាប់ ហាក់ដូចជាបានឮសំឡេងអ្វីមួយ ។

លោកសុភាឃើញកាកប្បកិរិយាប្លែកអស្ចារ្យ នៃមនុស្សម្នាក់នោះ ក៏សួរថា :

ណែ បុរសម្នាក់ អ្នកឯងធ្វើអ្វីដូច្នេះ !

បុរសម្នាក់តបទៅនឹងលោកសុភាវិញថា :

« សូមអភ័យទោស ! ពីម្សិលមេញ ខ្ញុំបានឮសំឡេងយុត្តិធម៌ឥឡូវនេះ ខ្ញុំឮសួរលោហធាតុម្យ៉ាង ប្រហែលជាប្រាក់ ខ្ញុំចង់កកាយយកប្រាក់នេះ ដើម្បីនឹងជូនលោក » ។

រួច បុរសម្នាក់ បន្ថែមតទៅទៀតថា :

« ខ្ញុំអភ័ព គ្មានពន្លឺមើលឃើញនឹងគេ តែធម្មជាតិបានទុកត្រចៀកទាំងពីរឲ្យខ្ញុំស្ដាប់សំឡេងដែលចេញពីក្នុងមហាប្រថពី ហើយខ្ញុំអាចស្ដាប់បាននូវសំឡេងដែលចេញពីចិត្តមនុស្ស ! » ។

ក្រោយដែលបានស្ដាប់នូវកថានៃបុរសម្នាក់ លោកសុភាក៏ព្រួយថប់បារម្ភជាខ្លាំង ក៏ឈប់លែងស្ដាប់ពាក្យនេះតទៅទៀត ។ លោកចូលទៅក្នុងគេហដ្ឋានរបស់លោក ហើយលោកបង្គាប់គេឲ្យដោះលែងបុរសម្នាក់នោះ ដែលមានប្រាជ្ញាឆ្លាតវៀងវៃ ។

( ចប់ )

នៅមានរឿងបងប្អូនប្រាំពីរនាក់តទៅទៀត ។

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ត.

## ប្រកាសប្រឡងទំនៀមទម្លាប់

នៅឆមាសទី ២ គឺតាំងពីខែ កក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៤ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែងពីរមុខ គឺ :

១– អំពីសិប្បការ ជារបររបស់ខ្មែរ ;

២– អំពីទំនុកច្រៀងបុរាណ របស់ខ្មែរ ។

*ដូច្នេះ អស់លោកអ្នកចេះដឹងទាំងឡាយ ជាស្ត្រី ជាបុរស ឬជាបព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងអត្ថបទ តាមគោលបញ្ហាដូចរៀបរាប់ខាងមុខ* ឲ្យការណាំទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែធ្នូ ឆ្នាំ ១៩៦៤ ។

ការប្រឡងប្រជែងនេះ មានរង្វាន់ជា ៤ ថ្នាក់ :

| | |
|---|---|
| ថ្នាក់លេខ ១... ១.០០០៛០០ | ថ្នាក់លេខ ៣... ៦០០៛០០ |
| ថ្នាក់លេខ ២... ៨០០៛០០ | ថ្នាក់លេខ ៤... ៤០០៛០០ |

បណ្ដាអត្ថបទតាំងពីរមុខនេះ បើបេក្ខជនម្នាក់ ធ្វើទៅដាក់ប្រឡងតាំងពីរមុខ ហើយបានល្អតាំងពីរមុខ អាចបានរង្វាន់តាំងពីរមុខ តែបើស្ម័គ្រដាក់ប្រឡងតាំងពីរមុខ សូមសរសេរអត្ថបទនីមួយ ៗ លើសៀវភៅសរសេរខ្នាតធំ ស្ដើងឬក្រាស មានចំនួនទំព័រតិចឬច្រើន តាមសេចក្ដីខ្លីឬវែង ផ្សេងពីគ្នា គឺអត្ថបទ ១ មុខដាក់សៀវភៅ ១ កុំដាក់ ២ មុខចូលគ្នា និងកុំសរសេរលើក្រដាសតែ ១ សន្លឹក ២ សន្លឹកស្ដើង ៗ ឡើយ ហើយសូមសរសេរនាម និងទីលំនៅរបស់ខ្លួនឲ្យច្បាស់លាស់លើក្រដាសស ១ សន្លឹក ដាក់ក្នុងស្រោមសំបុត្រ ១ ដោយឡែក ជាមួយនឹងអត្ថបទ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួនក៏បាន យកទៅឲ្យមេឃុំផ្ញើទៅតាមប៉ុស្ដិ៍ឲ្យក៏បាន ដោយកាខ្នងសំបុត្រថា :

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

(ផ្នែកក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)

គោលបញ្ហានៃការប្រឡង

១- អំពីសិប្បយការ ជារបររបស់ខ្មែរ :

ដោយរបស់បរទេស នេះតែមានចូលមកលក់ដូរក្នុងស្រុកខ្មែរយើង អ្នកស្រុកយើងក៏នេះតែនិយមប្រើ ហើយលះបង់ការងាររបររបស់ខ្លួន ពោលបន្តិចម្តង ៗ បណ្តាលឲ្យការបង្កើតផលរបស់ជាតិខ្លួនរលត់ទៅជាលំ-ដាប់ ទីងនាំឲ្យអ្នកស្រុកទៅជាល្ងង់ ចាំតែទិញរបស់គេប្រើស្រាប់ ហើយគេចង់ដំឡើងថ្លៃប៉ុន្មានក៏សឹងតែបាន ព្រោះខ្មែរយើងត្រូវការ ៗ ប៉ុន្តែសម័យនេះ ដោយសារការតែទម្រង់សេដ្ឋកិច្ចរបស់សម្តេចព្រះប្រមុខរដ្ឋទ្រង់ដឹកនាំឲ្យខ្មែរយើងខំបង្កើតផលិតផលរបស់ជាតិ កុំឲ្យខាតរូបិយប័ណ្ណទៅប្រទេសក្រៅ នោះក៏ផ្តល់នូវកំពូលមួយដល់អ្នកបច្ចេកទេសខ្មែរយើងដែលពីមុនមកបោះបង់ពោលមុខរបរអស់ជាច្រើនទៅហើយនោះ ឲ្យមានកម្លាំងប្រឹងកសាងថ្វីដៃរបស់ខ្លួនថែមឡើងវិញជាថ្មី ដើម្បីពង្រីកផលិត-ផលរបស់ខ្លួនដោយខ្លួនឯង ៗ ឧទាហរណ៍ដូចពីដើមដែលស្រុកខ្មែរយើងមិនទាន់មានរបស់បរទេសនាំចូលមកលក់ដូរច្រើនហើយប្លែក ៗ នៅឡើយខ្មែរយើងនេះធ្វើរបស់ច្រើនបែបច្រើនយ៉ាង តាមដែលខ្លួនត្រូវការ ជាអាទិ៍ គឺ សំពត់ហូល ល្បើក ប្រឡុប ផាហ៊ុំ ផាមួង អន្លូញ ក្រមួនសុទ្ធ ក្រមួនលាបមាត់ ទឹកអប់ ម្សៅ ក្រដាសមន ស៊ីករ ភ្លុល ផ្តិលខាត់ ផ្តិលស្ពាន់ ផ្តិលប្រាក់ បាត្រខ្ទក គុ-គោកជើងពានខ្ទក ដាំខ្យង ប្តុ-រគោកជើងពានឈើ គុ-ថាសជើងពានប្រាក់-ស្ពាន់ ហឹបស្លា ប្រអប់ផ្សេង ៗ មានកន្ត្រក-មូល ជាវិការៈនៃស្នែង នៃឈើ ខ្ទកដាំខ្យង កាំប្រួបផ្សេង ៗ

រូបភាពផ្សេងៗ ជាវិការៈនៃឈើ នៃលោហធាតុ ចម្លាក់នៅហោជាងវិហារ ទម្លុះស្បែកជាក្បាច់ជារូបភាពផ្សេងៗ ក្បាលបក់ ក្បាលកិន ក្បាលជាន់ ក្បាលថ្ម រហាត់ទឹក រហាត់វៃ រទេះគោ ទូកផ្សេងៗ ផ្តិលខ្ទមចន្ទន៍ ក្អម ឆ្នាំង ផើង ផើងក្រាន ជាវិការៈនៃដី ។ល។ ស្រា ទឹកក្បួង ទឹកខ្មេះ ទឹកត្រី ។ល។ ជាគ្រឿងឧបភោគ បរិភោគ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនទីងជារបស់សម្រាប់លក់ដូរក្នុងប្រទេស តាំងអំពីអតីតកាល ។

សិប្បការជារបស់ខ្មែរ ដែលក្រុមជំនុំរៀបរាប់ខាងលើនេះហើយ ដែលលោកអ្នកប្រឡងត្រូវសរសេរតែងផ្ញើទៅប្រឡងក្នុងលើកនេះ ។ ការប្រឡងនេះក្រុមជំនុំ សូមបញ្ជាក់ថា លោកអ្នកអាចសរសេរអំពីរបស់ដែលគេលះបង់ចោលអស់ទៅហើយក៏បាន អំពីរបស់ដែលគេប្រកបធ្វើជាកល់ថៃនៅឡើយក៏បាន គ្រាន់តែ បើលោកអ្នកត្រូវការសរសេរអំពីរបស់ណា សូមធ្វើសេចក្តីអធិប្បាយអំពីរបស់នោះឲ្យច្បាស់ទីងឲ្យបានសព្វគ្រប់ផង ព្រោះលើកមុន ក្រុមជំនុំបានទទួលឯកសារស្តីអំពីរបៀបស្លដាំឆេក ដែលលោកអ្នកសរសេរបាននិយាយអំពីរបៀបស្ល របៀបធ្វើ ទីងគ្រណាមផ្សេងៗ ហើយ ប៉ុន្តែលោកភ្លេចប្រាប់អំពីការប្រើ ថាមានរបៀបដូចម្តេច ។

ដើម្បីជាការឆ្លើយចំពោះបញ្ហានេះ ក្រុមជំនុំសូមជូនសេចក្តីជាលំនាំខ្លះ ដល់អស់លោកអ្នកសរសេរតែងដូចតទៅ ៖

ក)– របៀបធ្វើវត្ថុនីមួយៗ វត្ថុដែលត្រូវយកមកផ្សំ ទម្ងន់ ឬវង្វាល់

នៃវត្ថុនីមួយ ៗ ព្រមទាំងប្រដាប់សម្រាប់ប្រើ ក្នុងការប្រកបធ្វើរបស់នោះៗផង ។

ខ)- ក្នុងពេលធ្វើ តើមានត្រណម ឬពិធីអ្វីជាការចាំបាច់ឬទេ ?

គ)- ពាក្យទំនឹមទំនៀមឬពាក្យស្លោកផ្សេង ៗ ព្រមទាំងរឿងព្រេង ដែលទាក់ទងនឹងរបរនោះផង ។

ឃ)- វិធីប្រើរបស់នីមួយ ៗ ។

ង)- បើប្រសិនអស់លោកអ្នកសរសេរតែង អាចគូររូបភាពនៃរបស់ ដែលលោកអ្នកសរសេរផងបាន នោះជាការប្រសើរណាស់ ។

ជាពិសេស សូមបញ្ជាក់អំពីរបរដែលលោកអ្នកសរសេរនោះថា : លោកអ្នកបានធ្វើផ្ទាល់ខ្លួន ឬបានឃើញគេធ្វើនៅស្រុកណា ភូមិណា ខេត្តណា បើលោកបានជ្រាបដោយមានគេនិយាយប្រាប់ ក៏សូមបញ្ជាក់ទីកន្លែងដែលធ្វើរបរនោះ ព្រមទាំងអ្នកឲ្យការណ៍ដល់លោកអ្នកផង ។

២- អំពីចំនុកច្រៀងបុរាណ របស់ខ្មែរ :

ដែលហៅថា « ចំនុកច្រៀងបុរាណ របស់ខ្មែរ » នេះ គឺសំដៅដល់ពាក្យកាព្យឃ្លោងខ្លី ៗ ដែលអ្នកស្រុកធ្លាប់ចេះចាំត ៗ គ្នាមក រកដើមកំណើតថាអ្នកណាមួយជាអ្នកតែងមិនឃើញ ប៉ុន្តែគេចេះទូទៅគ្រប់ស្រុក គេធ្លាប់ច្រៀងលេងតាមកាលស្រេចការ នៅលើខ្នងក្របី នៅចុងត្នោត ឬនៅពេលបុណ្យទានតាមប្រពៃណីណាមួយ ។ ឧទាហរណ៍ដូចជា ចំនុក

បំពេកូន ទំនុកអុំទូក ទំនុកប្របកៃ ទំនុកបើកបាយខុន-រាំដាវ ទំនុកបើករាំងនន ទំនុកសារិកាកែវ ទំនុកចចេញ្ញងគោព្រៃ ទំនុកអាឡេវទៅបាញ់ប្រើក ។ល។

សូមលោក-អ្នកណាដែលចេះចាំទំនុកទាំងនេះ មេត្តាសរសេរកប់រៀបចញ្ជូនទៅឲ្យក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ភ្នំពេញ ដើម្បីក្រុមជំនុំពិនិត្យដាក់ពិន្ទុ ឲ្យលេខតាមការគួរ ។

ដើម្បីឲ្យងាយស្រួលដល់លោក-អ្នក ដែលនឹងសរសេរដាក់ប្រឡង យើងសូមជូនរបៀបសរសេរតាមលក្ខខណ្ឌដូចតទៅ ៖

## ១– សេចក្តីទំនុក :

ក– សូមបញ្ជាក់ឈ្មោះទំនុកឲ្យបានច្បាស់ ថាឈ្មោះទំនុកអ្វី ?

ខ– សរសេរសេចក្តីដែលជាទំនុកនោះ ឲ្យចប់ចុងចប់ដើម បានច្បាស់លាស់ ចែកចេញឲ្យមានឃ្លាល្បះត្រឹមត្រូវផង ។

គ– បើទំនុកនោះ មានពាក្យបន្ទរថាម៉េច ? ហើយបន្ទរត្រង់ឃ្លាណា ? សុំកត់ទាំងពាក្យបន្ទរនោះ ដាក់ជាប់ជាមួយទំនុកនោះ ត្រង់ឃ្លានោះផង ។

## ២– ហេតុទាក់ទងដោយដើមកំណើត :

ក– សូមនិយាយពីប្រវត្តិដើមរបស់ទំនុកនីមួយ ។ ដែលលោកអ្នក

សរសេរនោះថា ហេតុអ្វីបានជាកើតមានចំនុកនេះឡើង ឧបមាថា កើតដោយសារពួកអ្នកធ្វើសង្គ្រាម អ្នកអុំទូកជកព្រលិត អ្នករកខុស រកឃ្មុំ យកជ័រ ស្ទូចត្រី ឬបើមានរឿងព្រេងណាមួយដែលនិទានទាក់ទងដោយដើមកំណើតចំនុកនេះ បទនេះ ក៏សូមប្រាប់ផង ។

ខ- ចំនុកនោះៗ កើតមកពីសម័យណា បើដឹងឆ្នាំច្បាស់ សូមប្រាប់ក៏បាន បើមិនដឹងច្បាស់សូមប្រាប់តែជំនាន់ ដូចជាជំនាន់អង្គរ-ជំនាន់លង្វែក-ឧត្តុង្គ ជាដើម ។

គ- តើនរណាម្នាក់ ឬក្រុមណាមួយជាអ្នកបង្កើតចំនុកនេះឡើង ? បើអ្នកនោះមានឈ្មោះមានងារ សូមប្រាប់មកផង ។

ឃ- ហេតុអ្វីបានជាចំនុកនេះឯង មានចំណងជើងដូច្នេះ ព្រោះគេយកន័យចំនុកនេះប្រៀបធៀបនឹងអ្វី ? ឬមានកាយវិការដូចម្តេច ?

## ៣- ព័ត៌មានបន្ថែម :

ក- គេនិយមសូត្រ ឬច្រៀងចំនុកនេះនៅក្នុងពេលវេលាណា ? ដូចជា វេលាច្រូតកាត់ វេលារៀបអាពាហ៍ពិពាហ៍ ពេលកោរជុក ពេលអុំទូកលេង ពេលចាំចាប ពេលឡើងត្នោត ។ល។

ខ- តើចំនុកនេះ អ្នកស្រុកខ្មែរយើង នៅភូមិភាគណាដែលនិយមច្រៀង និយមសូត្រច្រើនជាងគេ ?

គ- តើចំនុកនេះមានទាក់ទងនឹងជំនឿយ៉ាងណា ? ដូចជាច្រៀង

បញ្ជាន់រូបអាវក្បូ អញ្ជើញម្រេញគង្វាលឲ្យជួយទាក់ដំរី ប្រគំជូរជំបូរ លាបំណន់ ឡើងគ្រូ ឡើងរោង កាត់ខ័ណ្ឌស្លា ។ល។

ឃ- តើនៅក្នុងស្រុកភូមិរបស់អស់លោក-អ្នក មាននរណាប៉ិនប្រសប់ច្រៀង ឬសូត្រទំនុកណា ពិរោះជាងគេ ? សូមប្រាប់ឈ្មោះ ប្រាប់ទីលំនៅអ្នកនោះផង ។

សេចក្ដីបញ្ជាក់ :

បេក្ខជននីមួយ ៗ ដែលអាចសរសេរទំនុកច្រៀងបុរាណរបស់ខ្មែរ មកដាក់ប្រឡងបាន ទាល់តែបានយ៉ាងតិច ១០ ទំនុកឡើងទៅ ហើយទំនុកទាំងនេះ ឥតមានកំណត់ថាវែង ឬខ្លីប៉ុណ្ណា ១ឡើយ ។ ពាក្យគាព្យខ្លះដែលពុំមែនសំរាប់ច្រៀង ហើយគ្រាន់តែសំរាប់សូត្រលេង ដើម្បីបញ្ចោកេង ដូចជាពាក្យថា : កាច់សាំងក្របែកក្អមតាព្រហ្ម ... បូតស្លឹកក្រវេះបាក់ព្រែក... ប៉ាត់ប៉ុយដៃសំអុយ ជាដើម ក៏អាចរាប់ថាជាទំនុកមួយដែរ ។ បើលោកអ្នកអាចសរសេរពាក្យបណ្ដៅមានជូន ១ ដែលគេតែងប្រដៅគ្នាឲ្យរក និងពាក្យលក់ដល់អ្នកដែលរកមិនឃើញផងក៏បាន ។

ទំនុកនីមួយ ១ ដែលលោកអ្នកបានសរសេរនោះ សូមដាក់សេចក្ដីបញ្ជាក់ថា លោកបានចេះផ្ទាល់ខ្លួន ឬបានសាកសួរ-កត់ចម្លងអំពីអ្នកណា នៅស្រុកណាផង ។

អត្ថបទដែលដាក់ប្រឡងនេះ ទាំងជាប់ ទាំងមិនជាប់ ត្រូវទុកជាសម្បត្តិរបស់ក្រុមជំនុំតទៅ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# ព្រះរាជពិធីថ្វាយព្រះឥស្សរិយភណ្ឌ

ចំពោះ

## សម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ

រៀបរៀងដោយ ឌុ-គាម

ដូចលោកអ្នកអានបានចាំ នូវព្រះរាជឱង្ការសម្តេចព្រះប្រមុខរដ្ឋនៅពេលសម្ពោធគ្រឹស្ថានព្រះសីហនុ នៅក្នុងបរិវេណ នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅថ្ងៃទី ២៨ វិច្ឆិកា គ.ស. ១៩៦៣ ថាព្រះអង្គទ្រង់លើកព្រះឋានៈសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ឲ្យឡើងជាសម្តេចព្រះសង្ឃរាជ ៗ ដូចនេះហើយ ទើបមានព្រះរាជក្រឹត្យលេខ ២៤ រ.វ ចុះថ្ងៃទី ២៨ វិច្ឆិកា គ.ស. ១៩៦៣ ថា សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ តាំងជា សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ និងសម្តេចព្រះសុធម្មាធិបតី ភុល-ទេស សង្ឃនាយកគណៈធម្មយុត្តិកនិកាយតាំងជា សម្តេចព្រះសង្ឃរាជថ្នាក់ទី ២ ៗ

ការឡើងព្រះសមណសក្តិ ជាកំពូលនៃព្រះសង្ឃ និងពុទ្ធបរិស័ទ ពិតជាសមទៅតាមព្រះសមត្ថភាពព្រះបញ្ញាញាណ ព្រះឧត្តមគតិ និងព្រះគុណូបការដ៏ពិសេសនៃសម្តេចព្រះសង្ឃទាំងពីរព្រះអង្គ ព្រមទាំងស្របតាមប្រពៃណីផង ព្រមទាំងជាជោគជ័យមួយដ៏ឧត្តមនៃសង្គមរាស្ត្រនិយម ក្នុងការលើដំកើងព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ

ឡើង ។ ព្រះរាជពិធីថ្វាយព្រះឥស្សរិយកណ្ឌ ចំពោះសម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គ បានប្រព្រឹត្តទៅនៅព្រះទីនាំងទេវាវិនិច្ឆ័យ កាលពីព្រឹកថ្ងៃទី ១៩ ឧសភា ឆ្នាំ ១៩៦៤ ក្រោមព្រះកិច្ចចាត់ចែងនៃសម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

នៅវេលាម៉ោង ៧.៣០ ព្រះរាជវង្សានុវង្ស ឥស្សរជនជាន់ខ្ពស់នៅក្នុងព្រះរាជធានី ទាំងទាហានទាំងស៊ីវិល ដែលមានជាអាទិ៍គឺសមាជិកព្រះរាជវង្សានុវង្ស សម្ដេចឧបរាជាំង ប៉ែន-នុត សហជីវិន អ៊ុង-ហុងសាធ ប្រធានរដ្ឋសភា អ្នកអង្គម្ចាស់ នរោត្តម-ម៉ុងតាណា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ អ្នកអង្គម្ចាស់នរោត្តម-កន្តុល នាយករដ្ឋមន្ត្រី ឯ.ឧ. សាន-យ៉ុន អគ្គនាយកនៃក្រសួងនានាក្នុងព្រះបរមរាជវាំង សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក សហជីវិន ស៊ិន-សាន ទីប្រឹក្សាផ្ទាល់ព្រះអង្គនៃសម្ដេចព្រះប្រមុខរដ្ឋ ឯកឧត្តមឧត្តមសេនីយ លន់-ណុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេស សមាជិករដ្ឋាភិបាល សមាជិកនៃសភាទាំងពីរ ឯ.ឧ. ញឹក-ទ្យូ ចាងហ្វាងពិធីការព្រះបរមរាជវាំង មេសេនាធិការនៃកងទ័ពទាំង ៣ មន្ត្រីជាន់ខ្ពស់គ្រប់ក្រសួងក្នុងព្រះរាជធានី ព្រមទាំងនាម៉ឺនមុខមន្ត្រីឯទៀតនានាខ្លះ បានស្ដេចយាងអញ្ជើញមកប្រជុំក្នុងព្រះរាជពិធីដ៏មហោឡារិកនេះ ។ នៅវេលាម៉ោង ៧,៤៥ នាទី ព្រះរាជាគណៈ ៣៨ អង្គ មានជាអាទិ៍ព្រះពោធិវង្ស ហួត-តាត និមន្តចូលគាន់

អាសន: ។

នៅវេលាម៉ោង ៧.៥០ នាទី សម្តេចព្រះមហាក្សត្រិយានី និង សម្តេចព្រះប្រមុខរដ្ឋ ដោយមានឥស្សរជនជាន់ខ្ពស់ជាព្រះរាជបរិពារតាមហែហមផង បានស្តេចយាងចេញប្រថាប់ក្នុងទេពវិនិច្ឆ័យ ដើម្បីរង់ចាំក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ ដែលនៅពេលនោះក្រុមបារគូបានថ្វាយបង្គំ ហើយក្រុមភ្លេងពិណពាទ្យព្រះរាជទ្រព្យថ្វាយបទភ្លេងជាតិជាព្រះកិត្តិយស ។ ឯនាម៉ឺនសព្វមុខមន្ត្រី ក៏ក្រាបថ្វាយបង្គំតាមបវារក់គង់ ៣ ដង ។

នៅម៉ោង៨ សម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គស្តេចមកដល់ ដោយមានក្បួនដង្ហែជាផ្កាភោរផង តាមព្រះរាជវាំងវិសេស ដោយមានទាហានក្រុមកេរ្តិ៍ព្រះអង្គបានថ្វាយគារវកិច្ចជាព្រះកិត្តិយស ។ ឯ.ឧ. មហាមន្ត្រី ញ៉ឹក-នូវ នឹងលោកវរសេនីយឯកសរ-ហោ ព្រះរាជអង្គរក្សនៃសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ទទួលសម្តេចព្រះសង្ឃរាជទាំងពីព្រះអង្គនៅពេលយាងចុះពីរថយន្ត ។ មន្ត្រីទាហានស៊ីវិល នៅក្នុងព្រះទីនាំងទេពវិនិច្ឆ័យ ឈរបែរមុខឈមរកគ្នា ។ សម្តេចព្រះឧបយុវរាជ ស្តេចយាងទៅចាំទទួលនៅមាត់ទ្វារ ហើយដង្ហែស្តេចយាងទៅគង់ប្រថាប់ក្នុងព្រះទីនាំងគោរពៈកិត្តិយស ។

ក្រោយពេលដែលសម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះប្រមុខ

វង្ស ព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រីក្រាបថ្វាយបង្គំ ថ្វាយគារវ-កិច្ច ចំពោះសម្តេចព្រះសង្ឃរាជហើយ ឯ.ឧ. មហាមន្ត្រី ញ៉ឹក-នូវ បានថ្លែងសុន្ទរកថាទូលថ្វាយសម្តេចព្រះសង្ឃរាជ ក្នុងព្រះបរមនាមនៃព្រះរាជបល្ល័ង្កដូចតទៅនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះសង្ឃរាជគណៈមហានិកាយ សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ត្បិតសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ព្រះអង្គមានព្រះរាជតំរិះថា ទីស្តេចសង្ឃបានចំហទំនេរ ជាច្រើនវស្សកាលមកហើយ (១) ហើយម្យ៉ាងទៀត ព្រះអង្គទ្រង់បានជ្រាបជាក់ច្បាស់ថា សម្តេចទាំងពីរព្រះអង្គ មានចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់លើសលប់លើព្រះសង្ឃទាំងឡាយ ទាំងពួង

១– តាមព្រះរាជពង្សាវតារនៃប្រទេសកម្ពុជា ដែលដំកល់ទុកក្នុងបណ្ណាល័យ នៃពុទ្ធសាសនបណ្ឌិត្យថា កាលក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះអង្គឌួង ព្រះអង្គទ្រង់បានតែងតាំងព្រះសង្ឃរាជ ២ ព្រះអង្គមកហើយ គឺដំបូងពីថ្ងៃ ៩ កើតខែបុស្ស ឆ្នាំមមែ នពស័ក ព.ស. ២៣៩១ គ ស. ១៨៤៧ តាំងសម្តេចព្រះ សង្ឃរាជ ព្រះនាម ទូ ទ្រង់គង់នៅវត្ត ក្រាំងពន្លៃ ។ តមក នៅឆ្នាំថោះសប្តស័ក ព. ស. ២៣៩៩ គ. ស. ១៨៥៥ បានតាំងសម្តេចព្រះសង្ឃរាជព្រះនាមទៀង នៅវត្តប្រាង្គ រួចមកគង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។



ឯកឧត្តម ញឹក - តូវ មហាមន្ត្រី ជាព្រះរាជតំណាង ថ្លែងសុន្ទរកថាស្ដីពីការថ្វាយគ្រឿងឥស្សរិយភណ្ឌ បំពោះ សម្ដេច ព្រះសង្ឃរាជទាំងពីរព្រះអង្គ កាលពីថ្ងៃទី ១៩ - ៥ – ៦៤ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ។

ក្នុងព្រះរាជអាណាចក្រកម្ពុជា ព្រមទាំងមានព្រះគុណូបការដ៏ធំទូលំទូលាយណាស់ ចំពោះជាតិសាសនា នឹងព្រះរាជបល្ល័ង្ក ជាពិសេស សម្តេចទាំងពីរព្រះអង្គទ្រង់បានជួយចលនាសង្គមរាស្ត្រនិយម ដែលជាចលនាសំរាប់បង្រួបបង្រួមជាតិឲ្យមានសាមគ្គីសាមគ្គាជាធ្លុង ១ ដើម្បីឲ្យមានសុភមង្គល នឹងឲ្យមានវឌ្ឍនាការដល់ប្រទេសជាតិទៀតផង អាស្រ័យហេតុនេះ បានជាសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះតំរិះថានៅពេលនេះហើយ ដែលត្រូវតែតែងតាំងថ្វាយព្រះឋានន្តរសក្តិជាទីព្រះសង្ឃរាជ ដោយមានព្រះរាជក្រិត្យលេខ ២៤ រ.វ. ចុះថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ ១៩៦៣ លើកព្រះឋានន្តរសក្តិជាទីសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ថ្វាយចំពោះព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ សម្តេចព្រះសង្ឃរាជថ្នាក់ទី ២ ថ្វាយសម្តេចព្រះសុធម្មាធិបតី ភុល-ទេស សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ។ សព្ទដែលត្រូវប្រើទៅកាន់ល្អងធូលីព្រះបាទទាំងពីរព្រះអង្គ គឺត្រូវប្រើក្នុងរាជសព្ទទាំងអស់ ព្រមទាំងមានសិទ្ធិត្រូវបានបុព្វសិទ្ធិប្រើប្រាស់ នូវព្រះទីនាំងកោដ្ឋៈពិសេស ផ្ចិតស្រួចពិសេស រង់ព្រះសិរពិសេស ទង់សម្រាប់ព្រះទីនាំងរថយន្តពិសេស ។

សូមទ្រង់ព្រះមេត្តាប្រោស

ថ្ងៃនេះ ជាថ្ងៃប្រកបដោយជោគជ័យសិរីមង្គលប្រសើរឯក ដែល

សម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋជាអម្ចាស់ ព្រះអង្គទ្រង់មានព្រះបរមរាជបញ្ជាឲ្យរាជសេវកាមាត្យឲ្យរៀបចំពិធីដ៏ឧឡារិកនៅនាវេលាវិច្ឆិកាយនេះ ដើម្បីថ្វាយនូវព្រះរាជឥស្សរិយយស ចំពោះសម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គដោយផ្ទាល់ព្រះហស្ត និងសូមថ្វាយព្រះពរសព្ទសាធុការ សូមសម្ដេចទាំងពីរព្រះអង្គ ទ្រង់បានប្រកបដោយព្រះសុខុមាលភាព និងព្រះវរ្ឈនភាពមានព្រះជន្មាយុយឺនយូរជានិរយព្រះវស្សា ដើម្បីសូមព្រះអង្គទ្រង់គង់ជាម្លប់ជាទីជ្រកកោនដ៏ត្រជាក់ត្រជុំនៃពុទ្ធមាមកជនទូទៅ ក្នុងព្រះរាជអាណាចក្ររៀងទៅ ។

( នៅមានត )

១ នេះលោកថា ចូរកុំគរ៉ ប្រចាំនឹងបុណ្យ
ដូចគេលើកក្អំ ធារធំពេកស៊ុន ខ្ទនឯងឥតគុណ
នាំវិនាសប្រាណ ។ កាលៈទេសៈ គំជំអនត្ថ
ប្រក្លូតពុំបាន បាត់ជាទី២ សម្ដីពុំក្បាន
ខាតធម៌កល្យាណ ទទេសូន្យសោះ ។
ឆេង-ត្រឹ

# សុន្ទរកថា

ដែលព្រះឃោសធម្ម កៅ·សិម

ចៅអធិការវត្តលង្កា ថ្លែងក្នុងឱកាសបុណ្យឆ្លងវិហារវត្តនេះ ថ្ងៃទី ១៩–៥–៦៤ ។

## សូមគោរព

ទូលព្រះបង្គំជាខ្ញុំ សូមនមស្ការ

សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជទី ១

សម្តេចព្រះសុគន្ធាធិបតី ព្រះសង្ឃរាជទី ២

ដោយសិរោត្តម ។

សូមថ្វាយព្រះពរ

សម្តេចព្រះមហាក្សត្រិយានី បរមបពិត្រ ព្រះមាតាជាតិ

សម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ

សូមគោរព

ព្រះតេជព្រះគុណ ព្រះពោធិវង្ស

ព្រះតេជព្រះគុណ ព្រះធម្មវង្សាធិបតី មេគណខេត្ត កំពង់ឆ្នាំង

លោកគ្រូព្រះអនុគណ ខេត្តតាកែវ ស្វាយរៀង . . . ។

សូមថ្វាយព្រះពរ-សូមចំរើនពរ

ទ្រង់-ឯកឧត្តម លោកជំទាវ លោកស្រី និងអស់លោកពុទ្ធបរិ-

ស័ព្វ ឧបាសក ឧបាសិកា ទាំងឡាយ ។

សូមទ្រង់ព្រះមេត្តាប្រោស

ខ្ញុំព្រះករុណា

អាត្មាភាព តាងនាមនៃគណៈកម្មាធិការចាត់ការបុណ្យ ពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ និងក្នុងនាមផ្ទាល់របស់អាត្មាភាព សូមព្រះរាជអភ័យ ព្រះរាជទាន ព្រះរាជវរោកាសថ្លែងអំណរគុណ ដ៏ធំក្រៃលែងចំពោះព្រះមហាករុណាធិគុណដ៏ខ្ពង់ខ្ពស់នៃសម្តេចទាំងពីរព្រះអង្គ ដែលទ្រង់ព្រះមេត្តាប្រោស ស្តេចយាងមកជាព្រះរាជាធិបតី ក្នុងឱកាសពិធីបុណ្យបញ្ចុះខណ្ឌសីមានិងឆ្លងព្រះវិហារថ្មី ព្រមទាំងឆ្លងឧបដ្ឋានសាលានៃវត្តលង្កានេះ ដើម្បីជានិធានកម្មនិងមហាកម្មដ៏ប្រសើរខ្ពង់ខ្ពស់បំផុត នាំឲ្យមានកិត្យានុភាពក្នុងព្រះពុទ្ធសាសនា ។ ខ្ញុំព្រះករុណាអាត្មាភាព សូមពណ៌នាថ្វាយដោយសេចក្តីសង្ខេប នូវដំណើរវិវត្តន៍នៃវត្តលង្កា និងកិច្ចកសាងព្រះវិហារនេះដូចតទៅ ៖

វត្តលង្កានេះ មានក្នុងប្រវត្តិនៃព្រះរាជពង្សាវតារថា: ព្រះបរមរាជាព្រះនាម ពញាយ៉ាត ទ្រង់បានយាងចេញពីទីទួល បាសាណ ដែលជាព្រះរាជវាំងចាស់ នៅឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល នៅថ្ងៃ៩ កើត ខែពិសាខ ឆ្នាំខាលឆស័ក ព.ស. ១៩៧៨ គ.ស. ១៤៣៤ ស្តេចមកគង់នៅភ្នំពេញនេះ នៅថ្ងៃ ១៥ កើត ខែពិសាខ ។ មាន

សេចក្ដីដំណាលថា « ព.ស. ១៩៨១ គ.ស. ១៤៣៥ ទ្រង់បានបញ្ជាឲ្យកសាងវត្តជាច្រើន មានវត្តភ្នំដូនពេញ ។

វត្ត កោះ

- លង្កា

- ព្រះពុទ្ធឃោសា ជាដើម

នៅទីជុំវិញភ្នំដូនពេញនោះ ។

ឯវត្តលង្កា ឋិតនៅទិសខាងកើតឆៀងឦសានភ្នំដូនពេញ ទ្រង់បានបញ្ញត្តឲ្យ ឈាមាក៏ដោយ ហៅថា វត្តលង្កា ។ លេចឮល្បីឈ្មោះប្រាកដឡើងតាំងពីសម័យជាន់នោះមក ដរាបដល់សម័យឥឡូវនេះ ។

វត្តលង្កា នេះ កាលដែលឋិតនៅភ្នំដូនពេញនោះ អស់រយៈកាល ៤៦០ ឆ្នាំ លុះដល់មកឆ្នាំកុរឯកស័ក ព.ស. ២៤៤១ គឺថ្ងៃទី១៩ ឧសភា គ.ស. ១៨៩៨ ទើបមានឧបសគ្គៈស្ទាក់ដំណើរ ដោយរាជការប្រូតិកតូរ៉ាត់បារាំងសែស បានបញ្ជាឲ្យរុះរើជញ្ជូនសម្ភារៈ នឹងព្រះបដិមាករ ចេញពីភ្នំដូនពេញ យកមកកសាងនៅបឹងកេងកង ឃុំលេខ ៤ ដែលជាសំយ៉ោយជាយក្រៅនៃព្រះរាជធានីទីក្រុង ក្នុងសម័យជាន់នោះ ដើម្បីយកកន្លែងនោះធ្វើជាមន្ទីរប៉ុយរ៉ូរបស់រាជការ ហើយបានប្រគេនបច្ច័យ ៤.០០០ រៀល ជាតម្លៃរុះរើ ដល់ព្រះញាណបវរវិជ្ជា អ៊ុក ជាចៅអធិការ ដើម្បីស្ថាបនាកេនឧបោសថ និងទីសេនាសនៈ ។

ឯទីវត្តតាំងមូល ក៏នៅមានសុទ្ធតែព្រៃពំងត្រស់ ដើមប្រពួយតូចធំ ស្មៅដុះណែនណាន់តាន់តាប់ដីក្រហេងក្រហូង ចុកជង្ហុកជ្រៅ ៗ គន់មើលទៅទិសខាងត្បូង ខាងលិច វាលល្ហេវល្ហ ដល់រដូវទឹកឡើងលិចព្រៃឈើតាំងនោះអស់រលីងទៅ ឃើញសុទ្ធតែទឹកសសំពោង រលកបែកផ្កាត្រែងបោលខ្លោល ៗ មក ខ្សែទឹករលកផ្ទក់ផ្ទើក ៗ គួរឲ្យស្រងេះស្រងោចលន្លោចចិត្តពន់ពេក ។

លុះចំណេរចរកាលតមកដល់ឆ្នាំច ទោស័ក ព.ស. ២៤៥៣ គ.ស. ១៩១០ លោកគ្រូចៅអធិការ គឺព្រះញាណបវរវិជ្ជា ខាត់ ដោយមានលោកអ្នកឧញ៉ា យោមរាជ ម៉ែន និងលោកជំទាវ ព្រាប ជាដើមជួយឧបត្ថម្ភ បានរុះរើកេងឧបោសថចាស់នោះ កសាងវិហារថ្មី គ្រឿងឈើប្រក់ក្បឿងឡើង អស់តម្លៃ ១០.២៤៥ រៀល ក៏នៅពុំទាន់ហើយស្រេច លោកក៏អនិច្ចធម្មទៅ តមកខាងក្រោយទៀត លោកគ្រូព្រះញាណបវរវិជ្ជា ល្វី-ឯម និងលោកជំទាវ ម៉ែន-ព្រាប ព្រមទាំងពុទ្ធបរិស័ទ ឧបាសក-សិកា បានធ្វើបុណ្យបញ្ចុះខណ្ឌសីមា ជាមហោឡារិកក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ជាអម្ចាស់ជីវិត ដោយមានលោកឡឺរ៉េស៊ីដង់ត៍ សុប៉េរីយ៉េរ៍ (Supérieur) ជំនាន់នោះព្រមទាំងអស់លោកកុង្ស៊ីសេនាបតីមន្ត្រីតូចធំ អ្នកមុខ អ្នកការជាច្រើនបានគាមវហហាមព្រះអង្គផង ដើម្បីជាកិត្តិយសដ៏ខ្ពង់ខ្ពស់ក្នុងឱកាសបុណ្យនោះ ។

( នៅមានត )

# អំពីព្រះនាមព្រះតេជព្រះគុណ

ដែលបានទទួលសញ្ញាប័ត្រ តាំងជាចៅអធិការ និងគ្រូសូត្រ ក្នុងវត្តនានា
ក្នុងព្រះរាជអាណាចក្រ (ត)

១០១– ព្រះតេជព្រះគុណ ម៉ែន-ហ៊ុន នាមធាយាសុវណ្ណបញ្ញាកេសរ កើតពី គ.ស. ១៨៩៦ អាយុ ៦៧ ឆ្នាំ វស្សា ៤៣ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តចុះ ឃុំលំពង់ ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ៣៤៨៥ ចុះថ្ងៃទី១៦.១.៦៣ ។

១០២–ព្រះតេជព្រះគុណ យង់-ញៀប នាមធាយានាគវីរយោ កើតពី គ.ស.១៩១៥ អាយុ ៤៨ ឆ្នាំ វស្សា ២៧ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តកំណប់ ឃុំចំបុំ ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣៤៨៦ ចុះថ្ងៃទី១៦.៣.៦៣ ។

១០៣–ព្រះតេជព្រះគុណ វ៉ែ-វ៉ន នាមធាយាទីបធម្មោ កើតពី គ.ស. ១៩៣០ អាយុ ៣៣ ឆ្នាំ វស្សា១២ បានទទួលតែងតាំង ជាចៅអធិការក្នុងវត្តមង្គលសាលវ័ន ឃុំខ្នារជើងធំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣៤៨៧ ចុះថ្ងៃទី ១៦.៣.៦៣ ។

១០៤– ព្រះតេជព្រះគុណ អ៊ុក-ទិត នាមធាយាវិសាលត្ថេរ កើតពី គ.ស.១៨៩៨ អាយុ ៦៥ឆ្នាំ វស្សា ៣៩ បានទទួលតែងតាំង ជាចៅអធិការក្នុងវត្តអម្ពផល ឃុំចុងកោះស្រុកមុខកំពូល ខេត្តកណ្ដាល លេខ

សញ្ញាប័ត្រ ៣៤៨៨ ចុះថ្ងៃទី ២៤ ៣.៦៣ ។

១០៥– ព្រះតេជព្រះគុណ ជុំ-វណ្ណថា នាមឆាយាជោតសរ កើតពី គ.ស. ១៩៣២ អាយុ ៣៩ ឆ្នាំ វស្សា ១៨ បានទទួលតែងតាំង ជាគ្រូសូត្រស្តាំគង់វត្តអម្ពផល ឃុំចុងកោះ ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៨៩ ចុះថ្ងៃទី ២៤.៣.៦៣ ។

១០៦– ព្រះតេជព្រះគុណ ធី-ឈិត នាមឆាយាញាណសារោ កើតពី គ.ស. ១៩២៩ អាយុ ៣៤ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំង ជាគ្រូសូត្រឆ្វេងគង់វត្តអម្ពផល ឃុំចុងកោះ ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៩០ ចុះថ្ងៃទី ២៤.៣.៦៣ ។

១០៧– ព្រះតេជព្រះគុណ ម៉ៅ-ឌុល នាមឆាយាសុវណ្ណកេសរោ កើតពីគ.ស. ១៩២៨ អាយុ ៣៥ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំង ជាចៅអធិការ គង់វត្តពពិស ឃុំព្រៃវែង ស្រុកព្រៃវែង ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៩១ ចុះថ្ងៃទី ២៤ ៣.៦៣ ។

១០៨– ព្រះតេជព្រះគុណ ប៉ែន-សេង នាមឆាយាសទ្ធម្មតេរ កើតពី គ.ស. ១៩២២ អាយុ ៤២ ឆ្នាំ វស្សា ២៣ បានទទួលតែងតាំង ជាចៅអធិការគង់វត្តអូរពេជ្រ ឃុំចម្បក ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣៤៩២ ចុះថ្ងៃទី ៣១ ៣.៦៣ ។

( នៅមានត )